សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបសន្តតិកម្មរបស់សហព័ទ្ធ
# ( ករណីកម្ពុជា-ជប៉ុន )

ស្រាវជ្រាវ ពីថ្ងៃទី០១ ខែមីនា ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **ភ. សមស័ក្តិ រចនា**

**សុខ តិរម្យ**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សុខ តិរម្យ** និង **ត.សមស័ក្តិ រចនា** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និង សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកយាយ** ដែលបានផ្តល់ការទូន្មានអោយចៅប្រកបដោយគន្លងធម៌មកដល់ពេលនេះ។

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌ពិសេសដែលបានផ្គត់ផ្គង់ទំនុកបំរុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិកា ស្មារតី និង ជួយទំនុកបម្រុងកូនឲ្យបានទទួលនូវការអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតមកដល់ពេលនេះ។

**លោកមា ម្តាយមីង បងស្រី** ដែលជួយទំនុកបម្រុងទាំងសម្ភារៈ និង ផ្នែកស្មារតីដោយផ្តល់នូវការលើកទឹកចិត្តដល់ខ្ញុំ ឲ្យខិតខំប្រឹងប្រែងរៀនសូត្រ រហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

**មជ្ឈមណ្ឌលអប់រំ និង ស្រាវជ្រាវច្បាប់ជាភាសាជប៉ុន** ដែលបានផ្តល់អាហារូបករណ៍សិក្សាភាសាជប៉ុន និង ច្បាប់ជាភាសាជប៉ុនអស់រយៈពេល៥ឆ្នាំដែលធ្វើឲ្យយើងខ្ញុំអាចធ្វើការស្រាវជ្រាវឯកសារជាភាសាជប៉ុនបាន ។

**ថ្នាក់ដឹកនាំ លោក លោកស្រីសាស្រ្តាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនដល់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ ទើបធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹង ដើម្បីទុកជាអាវុធដ៏មានប្រសិទ្ធភាពសម្រាប់កែលម្អជីវិតទៅថ្ងៃអនាគត។

ជាពិសេស លោកសាស្រ្តាចារ្យ **គង់ សុភ័ក្រ្ត** បីដូចជាអ្នកមានគុណទី២ ដែលបានប្រៀនប្រដៅសីលធម៌ក្នុងការរស់នៅ និង ជាសាស្រ្តាចារ្យប្រកបដោយគតិបណ្ឌិត ដែលបានបណ្តុះពុទ្ធិយើងខ្ញុំ និង បានចំណាយទាំងកម្លាំងកាយ ចិត្ត ផ្តល់ជាកិត្តិយសណែនាំ ក៏ដូចជាផ្តល់ជាគំនិតក្នុងការកែលំអរក្នុង ការសរសេរសារណានេះប្រកបដោយជោគជ័យ ដោយមិនគិតពីការនឿយហត់។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងពួងនៅលើលោកនេះ ជួយតាមថែរក្សាអស់ លោកអ្នកមានគុណទាំងឡាយ ឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

តាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច រួចមក យើងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនដោយរួមផ្សំជាមួយនឹងការស្រាវជ្រាវពីស្ថានភាពជាក់ស្តែងនៃសង្គមផងដែរ។ ក្នុងចំណោមមុខវិជ្ជា ដែលបានសិក្សានាពេលកន្លងមក យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យរដ្ឋប្បវេណី ដែលនាំឲ្យ យើងខ្ញុំ បានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "**ប្រៀបធៀបសន្តតិកម្មរបស់សហព័ទ្ធ ករណីកម្ពុជា-ជប៉ុន**" ធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ការសម្រេចជ្រើសយកប្រធានបទមួយនេះ គឺត្រូវបានទទួលការយល់ព្រម និង ជួយកែលម្អពីសំណាក់លោកសាស្ត្រចារ្យ **គង់ សុភ័ក្រ** ។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានធ្វើ ការតាក់តែងនូវស្នាដៃនេះឡើង ដោយយើងខ្ញុំ បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត សម្រិតសម្រាំងទៅលើខ្លឹមសារនៃប្រធានបទ ដើម្បីឲ្យខ្លឹមសារនៃប្រធានបទរបស់យើងខ្ញុំមានភាពច្បាស់លាស់ ក្បោះក្បាយគ្រប់ជ្រុងជ្រោយដើម្បីជាគុណប្រយោជន៍ពិតប្រាកដ។ យើងខ្ញុំ សង្ឃឹម និង ជឿជាក់ថាស្នាដៃមួយនេះពិតជាផ្តល់អត្ថប្រយោជន៍ និង ជាទុនក្នុងការពង្រីកពុទ្ធិគំនិត និង ចំណេះដឹកក្នុងការស្រាវជ្រាវពីគ្រប់បណ្តាមជ្ឈដ្ឋានអ្នកអានទាំងអស់។

ជាចុងបញ្ចប់ យើងខ្ញុំ សង្ឃឹមថាសារណានេះ នឹងអាចជួយកែលម្អចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយ ក៏ដូចជា ក្នុងការអនុវត្តពាក់ព័ន្ធនឹងសិទ្ធរបស់សហព័ទ្ធក្នុងសន្តតិកម្មនៅក្នុងសង្គមជាក់ស្តែង។ទោះជាយ៉ាងណាសារណានេះ ប្រាកដជាមានកំហុសឆ្គង ដែលមិនអាចជៀសវាងបាន ដែលត្រូវការជាចាំបាច់នូវការរិះគន់ ក្នុងន័យស្ថាបនា ពីសំណាក់អស់លោកសាស្ត្រចារ្យ រៀមច្បង និង អ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីឲ្យស្នាដៃនេះ ឲ្យកាន់តែមានសុក្រឹត្យភាព។

យើងខ្ញុំ រង់ចាំទទួលជានិច្ច នូវរាល់ការរិះគន់ទាំងឡាយដោយក្តីរីករាយ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ សញ្ញាណទូទៅនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន** ........ ៥

**ផ្នែកទី១៖ ប្រភពនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន** ........ ៩

១. ប្រភពនៃរបបសន្តតិកម្ម កម្ពុជា ........ ៩

១.១. ប្រភពជាតិនៃរបបសន្តតិកម្ម កម្ពុជា ........ ១០

១.១.១. ក្រមមតិក កម្ពុជា ........ ១០

១.១.២. ក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ឆ្នាំ១៩២០ ........ ១១

១.១.៣. ក្រមរដ្ឋប្បវេណីកម្ពុជាថ្មី ឆ្នាំ២០០៧ ........ ១២

១.២. ប្រភពអន្តរជាតិនៃរបបសន្តតិកម្ម កម្ពុជា ........ ១៣

២. ប្រភពនៃរបបសន្តតិកម្ម ជប៉ុន ........ ១៤

២.១. ប្រភពជាតិនៃរបបសន្តតិកម្ម ជប៉ុន ........ ១៥

២.១.១. ក្រមរដ្ឋប្បវេណីជប៉ុនសម័យមេជិ ឆ្នាំ១៨៩៨ ........ ១៥

២.១.២. វិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន សម័យស្យ៉ូវ៉ា ........ ១៦

២.២. ប្រភពអន្តរជាតិនៃរបបសន្តតិកម្ម ជប៉ុន ........ ១៧

**ផ្នែកទី២៖ ចរិតលក្ខណៈនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន** ........ ១៨

១. ផលប្រយោជន៍នៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន ........ ១៩

១.១. ផលប្រយោជន៍ឯកជននៃរបបសន្តតិកម្ម ........ ១៩

១.២. ផលប្រយោជន៍សាធារណៈនៃរបបសន្តតិកម្ម ........ ២០

២. អត្ថិភាព និង នត្ថិភាពនៃសិទ្ធិជាសន្តតិជន កម្ពុជា-ជប៉ុន ........ ២០

២.១. អត្ថិភាពនៃសិទ្ធិជាសន្តតិជន ....................................................................................២១

២.២. នត្ថិភាពនៃសិទ្ធិជាសន្តតិជន ....................................................................................២៣

២.២.១. អភ័ព្វបុគ្គល ....................................................................................២៣

២.២.២. ជនដែលត្រូវផ្ដាច់ចេញពីមតិក ....................................................................................២៥

២.២.៣ ករណីសន្តតិជនជាជនបរទេស ....................................................................................២៧

**ជំពូកទី២៖ ការវិវត្តនៃសិទ្ធិរបស់សហាព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជា-ជប៉ុន**......២៩

**ផ្នែកទី១៖ ការវិវត្តនៃសិទ្ធិរបស់សហាព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជា**.................... ៣០

១. លំដាប់របស់សហាព័ទ្ធក្នុងសន្តតិកម្ម កម្ពុជា ....................................................................................៣១

១.១. ការប្រែប្រួលនៃលំដាប់របស់សហាព័ទ្ធក្នុងសន្តតិកម្ម កម្ពុជា ............................ ៣១

១.១.១ លំដាប់សន្តតិកម្មរបស់សហាព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីកម្ពុជាចាស់....... ៣១

១.១.២. លំដាប់សន្តតិកម្មរបស់សហាព័ទ្ធផ្អែកតាមនីតិវិជ្ជមាន កម្ពុជា .................. ៣២

១.២. អត្ថន័យនៃសន្តតិជនជានិច្ច.................................................................................... ៣៣

២. ចំណែកមតិករបស់សហាព័ទ្ធ ករណីកម្ពុជា .................................................................................... ៣៤

២.១. សហាព័ទ្ធ និង បច្ឆាញាតិ .................................................................................... ៣៥

២.២. សហាព័ទ្ធ និង ឪពុកម្ដាយ.................................................................................... ៣៦

២.៣. សហាព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្ដាយ .............................៣៧

៣. សិទ្ធិរបស់សហាព័ទ្ធលើភាគបម្រុង ករណីកម្ពុជា....................................................................................៤១

៣.១ គោលគំនិតដែលផ្ដល់ឲ្យសហាព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុង......................៤២

៣.២. កម្រិតនៃភាគបម្រុងដែលសហាព័ទ្ធទទួលបាន .................................................... ៤៣

**ផ្នែកទី២៖ ការវិវត្តនៃសិទ្ធិរបស់សហាព័ទ្ធក្នុងរបបសន្តតិកម្ម ជប៉ុន**.................... ៤៦

១. លំដាប់របស់សហាព័ទ្ធក្នុងសន្តតិកម្ម ជប៉ុន ..... ៤៧
១.១. ការប្រែប្រួលនៃលំដាប់របស់សហាព័ទ្ធក្នុងសន្តតិកម្ម ជប៉ុន ..... ៤៨
១.១.១. លំដាប់សន្តតិកម្មរបស់សហាព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីជប៉ុនចាស់ ..... ៤៨
១.១.២. លំដាប់សន្តតិកម្មរបស់សហាព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីជប៉ុនថ្មី ..... ៤៩
១.២. អត្ថន័យនៃសន្តតិជនពិសេស ..... ៥០
២. ចំណែកមតិករបស់សហាព័ទ្ធ ករណីជប៉ុន ..... ៥០
២.១. សហាព័ទ្ធ និង បច្ឆាញាតិ ..... ៥១
២.២. សហាព័ទ្ធ និង ឪពុកម្តាយ ..... ៥៣
២.៣. សហាព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្តាយ ..... ៥៤
៣. សិទ្ធិរបស់សហាព័ទ្ធលើភាគបម្រុង ករណីជប៉ុន ..... ៥៨
៣.១. គោលគំនិតដែលផ្តល់ឲ្យសហាព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុង ..... ៥៩
៣.២. កម្រិតនៃភាគបម្រុងដែលសហាព័ទ្ធទទួលបាន ..... ៦០
**សេចក្តីសន្និដ្ឋាន** ..... ៦២
**អនុសាសន៍** ..... ៦៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**
- **ឧបសម្ព័ន្ធ ទី១ ៖** ក្រមមតិកកម្ពុជា ឆ្នាំ១៨៩១ ពាក់ព័ន្ធនឹង សន្តតិកម្ម
- **ឧបសម្ព័ន្ធ ទី២ ៖** ក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ឆ្នាំ១៩២០ ពាក់ព័ន្ធនឹង សន្តតិកម្ម
- **ឧបសម្ព័ន្ធ ទី៣ ៖** ក្រមរដ្ឋប្បវេណីកម្ពុជាថ្មី ឆ្នាំ២០០៧ ពាក់ព័ន្ធនឹង សន្តតិកម្ម
- **ឧបសម្ព័ន្ធ ទី៤ ៖** ក្រមរដ្ឋប្បវេណីជប៉ុនថ្មី ឆ្នាំ១៩៨០ ពាក់ព័ន្ធនឹង សន្តតិកម្ម

# សេចក្តីផ្តើម

មនុស្សយើងកើតមកតែងតែប្រកបរបររកទទួលទាន ដើម្បីចិញ្ចឹមជីវិត និងសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ហេតុដូចនេះ ទើបរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តទទួលស្គាល់នូវកម្មសិទ្ធិឯកជន[១] ក្នុងគោលបំណងធានាដល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗខិតខំប្រឹងប្រែងរកមកយ៉ាងលំបាកនោះ។ ពាក្យថាកម្មសិទ្ធិ គឺសំដៅទៅលើសិទ្ធិប្រើប្រាស់ អាស្រ័យផល កាន់កាប់ និងចាត់ចែង[២]។ មានន័យថាកម្មសិទ្ធិករ មានសិទ្ធិយ៉ាងទូលំទូលាយលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនទាំងក្នុងពេលបច្ចុប្បន្ន ទាំងពេលអនាគត ព្រមទាំងពេលទទួលមរណភាពផងដែរ។

កម្មសិទ្ធិករមានសិទ្ធិ កាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួនបានក្នុងពេលបច្ចុប្បន្ន ឬពេលអនាគតបាន ដោយឡែកនាពេលដែលគាត់ទទួលមរណភាព នោះទ្រព្យសម្បត្តិ របស់គាត់នឹងត្រូវធ្វើការផ្ទេរដែលគេហៅថាជាការផ្ទេរបេតិកភណ្ឌ[៣]ដោយមរណភាព ឬដែលពាក្យច្បាប់ហៅថា របបសន្តតិកម្ម។ សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន[៤]ទៅឲ្យសន្តតិជន[៥]ម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[៦]។ តួយ៉ាង ប្រវត្តិសន្តតិកម្មរបស់កម្ពុជាមិនមែនទើបតែបង្កើតឡើង នៅក្នុងសម័យបច្ចុប្បន្ននោះទេ។ របបសន្តតិកម្ម ត្រូវបានចាប់កំណើត តាំងពីសម័យហ្វូណនមកម៉្លេះ ដែលសម័យកាលនោះ ប្រជាជនកម្ពុជាបាន អនុវត្តប្រពៃណីសន្តតិកម្មដូចគ្នានឹងប្រទេសហ្វូណនដែរ[៧]។

---

[១] មាត្រា៥០ កថាខណ្ឌ២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានបញ្ញត្តថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន។

[២] មាត្រា១៣៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តថា កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត។

[៣] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២* (ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨), បេតិកភណ្ឌ គឺជា ទ្រព្យសម្បត្តិ ឬកេរ្តិ៍មតិកដែលមានជាប់តមកពីខាងឪពុក។

[៤] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ១១៧. ជនដែលបានស្លាប់ទៅហើយ។

[៥] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ១៤៥. ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

[៦] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១៤៣។

[៧] មជ្ឈមណ្ឌលឯកសារកម្ពុជា, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា. ២០០៥), ទំព័រ១៥។

ពោលគឺ ទំនៀមទម្លាប់ខ្មែរទាក់ទងនឹងសន្តតិកម្មមានប្រភពដំបូងបំផុតមកពីប្រពៃណីទំនៀមទម្លាប់របស់ហិណ្ឌូ។ កាលនោះ ពុំទាន់ឃើញមានច្បាប់ដែលកំណត់ពីការផ្ទេរបេតិកភណ្ឌដោយមូលហេតុមរណភាពជាក់ច្បាស់នោះទេ ពោលគឺការបែងចែកទ្រព្យសម្បត្តិរបស់អ្នកស្លាប់ ត្រូវបានធ្វើទៅតាមទំនៀមទម្លាប់ដែលបានអនុវត្តតៗគ្នា ដូចជាកំណត់យកកូនច្បងនៃគ្រួសារជាអ្នកស្នងមត៌កជាដើម ឬក៏ កំណត់យកកូនណាដែលតែងតែយកចិត្តទុកដាក់ មើលថែរក្សាខ្លួននៅពេលដែលខ្លួននៅរស់ ឬម៉្យាងវិញទៀត គេច្រើនកំណត់យកកូនពៅនៃគ្រួសារជាអ្នកស្នងមត៌កទៅវិញ។ និយាយជារួម គឺដោយសារនៅសម័យនោះ ពុំទាន់មានវត្តមាននៃច្បាប់ដែលកំណត់ពីរបបសន្តតិកម្ម ទើបប្រជាជនខ្មែរជំនាន់ដើមនិយមធ្វើទៅតាមទំនៀមទម្លាប់គ្រួសារនីមួយៗ។ លើសពីនេះ គួរឲ្យកត់សម្គាល់ផងដែរថា នាសម័យនោះហាក់ដូចជា មិនមានទំនៀមទម្លាប់ក្នុងការបែងចែកទ្រព្យសម្បត្តិទៅឲ្យបុគ្គលដែលជាសហព័ទ្ធរបស់មតកជននៅឡើយទេ គឺភាគច្រើន ឃើញមានតែការបែងចែកទ្រព្យសម្បត្តិទៅឲ្យទាយាទ[៨]របស់មតកជនតែប៉ុណ្ណោះ។ សហព័ទ្ធ ក្នុងន័យនេះសំដៅទៅលើ ប្តីប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ទ្ធនេះ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់[៩]។ ដោយសារតែការប្រកាន់ខ្ជាប់នូវផ្នត់គំនិត ដែលពុំមានច្បាប់ទម្លាប់ត្រឹមត្រូវនោះតែងតែបង្កនូវភាពអយុត្តិធម៌ចំពោះទាយាទផ្សេងៗទៀត នៅពេលដែល ម្ចាស់បណ្តាំប្រគល់មត៌កទៅឲ្យសន្តតិជនតែម្នាក់ ដែលជាហេតុបណ្តាលឲ្យ សន្តតិជនផ្សេងទៀតដែលមិនបានទទួលមត៌ក ទាំងដែលពួកគេមិនបានប្រព្រឹត្តកំហុសនោះ មានការអន់ចិត្ត ឬការច្រណែនឈ្នានីសជាដើម។ លុះដល់សម័យកាលក្រោយៗមក គឺសម័យព្រះបាទនរោត្តម យើងសង្កេតឃើញថាអ្នកដឹកនាំរបស់ខ្មែរ បានតាក់តែងនូវច្បាប់មួយចំនួន សម្រាប់អនុវត្តន៍ទៅលើទ្រព្យសម្បត្តិ ក៏ដូចជាផ្តល់សិទ្ធិឲ្យសហព័ទ្ធជាភរិយា មានសិទ្ធិទៅលើទ្រព្យសម្បត្តិនោះផងដែរ នៅក្នុងនោះមានដូចជា ក្រមមត៌កឆ្នាំ១៨៩១ និងក្រមទសភរិយាឆ្នាំ១៨៥៣ជាដើម។

តាមរយៈច្បាប់ទាំង២ខាងលើនេះ បានផ្តល់សិទ្ធិឲ្យសហព័ទ្ធជាភរិយា មានសិទ្ធិលើទ្រព្យសម្បត្តិក៏ពិតមែន តែហាក់ដូចជាមានលក្ខណៈមិនទាន់ពេញលេញនៅឡើយ គឺពុំទាន់មានមាត្រាណា ដែលផ្តល់សិទ្ធិឲ្យគាត់ មានទៅលើចំណែកមត៌ករបស់មតកជនទេ ពោលគឺពុំទាន់មានរបបសន្តតិកម្ម របស់សហព័ទ្ធទេ។ លុះដល់សម័យឆ្នាំ១៩២០ វត្តមាននៃក្រមរដ្ឋប្បវេណីចាស់បានលេចរូបរាងឡើងក្នុងប្រទេសកម្ពុជា ដែលច្បាប់នេះត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។ ច្បាប់នេះ បានចែងលម្អិតអំពីសន្តតិកម្ម ក៏ប៉ុន្តែស្ថានភាពសង្គមនៅពេលនោះពុំទាន់មានការទទួល

---

[៨] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២* (ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨), ទាយាទ គឺបុត្រ បុត្រី អ្នកដែលទទួលទ្រព្យសម្បត្តិ និងមត៌ក, អ្នកដែលត្រូវបន្តវង្សត្រកូល។

[៩] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១៥០។

ស្គាល់នូវសមភាពរវាងបុរស និងស្ត្រីនៅឡើយទេ។ លុះក្រោយមក នាសម័យឆ្នាំ១៩៩២ សង្កេតឃើញមាននូវ វត្តមានច្បាប់ថ្មីមួយទៀតគឺ ច្បាប់ភូមិបាល ដែលត្រូវបានអនុម័ត និងប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២។ ក្នុងច្បាប់នេះមានមាត្រាមួយចំនួនចែងអំពីសន្តតិកម្មផងដែរ ប៉ុន្តែ មាត្រាទាំងនោះត្រូវបានដកចេញទាំងស្រុង ពីបទបញ្ញត្តិដែលទាក់ទងនឹងសន្តតិកម្មនៃច្បាប់រដ្ឋប្បវេណីចាស់។ ដូចនេះ បទប្បញ្ញត្តិដែលទាក់ទងទៅនឹងសន្តតិកម្មរបស់សហាព័ន្ធនៅតែមិនមាននៅឡើយ។ រហូតដល់សម័យឆ្នាំ ២០០៧ វត្តមាននៃក្រមរដ្ឋប្បវេណីថ្មីបានលេចរូបរាងឡើង ក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដែលហៅកាត់ថា (JICA)។ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧ និងត្រូវប្រកាសឲ្យប្រើ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលច្បាប់នេះបានក្រសោបយកស្ទើគ្រប់ផ្នែកដែលពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណីដែលក្នុងនោះ បទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសន្តតិកម្មក៏ត្រូវបានបញ្ញត្តយ៉ាងលម្អិត ដែលមានកំណត់ចាប់ពីមាត្រា១១៩៥ ដល់ មាត្រា១៣០៤។ ក្នុងនោះក៏មានបទប្បញ្ញត្តិមួយចំនួនទាក់ទងទៅនឹងសន្តតិកម្មរបស់សហាព័ទ្ធផងដែរ។ បន្ថែមពីនេះ យើងឃើញមានការតាក់តែងឡើងនូវសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីទៅតាមគន្លឹនីមួយៗក្នុងឆ្នាំ២០១០ ក្នុងនោះក៏មានគន្លឹដែលទាក់ទងនឹងរបបសន្តតិកម្ម ដែលបានរៀបចំដោយគណៈកម្មការទទួលបន្ទុក ការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី។

ម៉្យាងវិញទៀត ដោយសារតែក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧របស់កម្ពុជា ត្រូវបានបង្កើតឡើងក្រោមជំនួយរបស់ប្រទេសជប៉ុន ទើបសង្កេតឃើញថាប្រព័ន្ធច្បាប់រដ្ឋប្បវេណីរបស់កម្ពុជា ភាគច្រើនមានភាពស្រដៀងគ្នាទៅនឹងប្រព័ន្ធច្បាប់រដ្ឋប្បវេណីនៃប្រទេសជប៉ុន។ ទន្ទឹមនឹងនេះ ប្រទេសជប៉ុនបច្ចុប្បន្នក៏ទទួលស្គាល់នូវរបបសន្តតិកម្មរបស់សហាព័ទ្ធផងដែរ ដោយមានចែងយ៉ាងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណីថ្មីនៃប្រទេសជប៉ុន ឆ្នាំ១៩៨០។ ហេតុដូចនេះ ការសិក្សាស្វែងយល់អំពីប្រព័ន្ធច្បាប់នៃប្រទេសទាំង២នេះ គឺពិតជាមានសារៈសំខាន់ សម្រាប់ធ្វើជាទន់ក្នុងការសិក្សា ប្រៀបធៀបរវាងប្រព័ន្ធច្បាប់របស់ប្រទេសខ្លួន ជាមួយនឹងអន្តរជាតិ ជាពិសេសគឺប្រទេសដែលជាសមាជិកអាស៊ានដែលអាចធ្វើជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវបន្តក្នុងនីតិគ្រួសារ។ ពោលគឺប្រធានបទនៃសារណាបញ្ចប់ការសិក្សានេះនឹងស្តីអំពី "ប្រៀបធៀបសន្តតិកម្មរបស់សហាព័ទ្ធ (ករណីកម្ពុជា-ជប៉ុន)" ។

ការលើកយកប្រធានបទស្តីពី "ប្រៀបធៀបសន្តតិកម្មរបស់សហាព័ទ្ធ (ករណីកម្ពុជា-ជប៉ុន)" មកតាក់តែងជាសារណាបញ្ចប់ការសិក្សា គឺក្នុងគោលបំណង ដើម្បីស្វែងយល់កាន់តែច្បាស់អំពីខ្លឹមសារនៃរបបសន្តតិកម្មតាមច្បាប់ ដោយផ្តោតសំខាន់លើសន្តតិកម្មរបស់សហាព័ទ្ធ ព្រមទាំងធ្វើការសិក្សាប្រៀបធៀបជាមួយករណីសិក្សាប្រទេសជប៉ុន ដើម្បីយល់ដឹងអំពី លក្ខណៈដូច និងខុសគ្នានៃ របបសន្តតិកម្មរបស់សហាព័ទ្ធ ក៏ដូចជាផ្តត់គំនិតក្នុងការផ្តល់សិទ្ធិឲ្យសហាព័ទ្ធចូលរួមក្នុងរបប

សន្តតិកម្ម។ ការបកស្រាយក្នុងសារណានេះគឺផ្អែកទៅតាម ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និង ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ជាមូលដ្ឋាន ព្រមទាំងលើកយកក្រមរដ្ឋប្បវេណីចាស់នៃប្រទេសទាំងពីរមកបញ្ចូលឲ្យកាន់តែងាយយល់ផងដែរ ថាតើរបបសន្តតិកម្មនៃប្រទេសកម្ពុជា និងជប៉ុន ទទួលរងនូវឥទ្ធិពលពីប្រទេសណាខ្លះ? ហើយចាប់ពីសម័យដើមរហូតដល់បច្ចុប្បន្ន របបសន្តតិកម្មមានការវិវត្តយ៉ាងដូចម្តេចខ្លះ? ម្យ៉ាងវិញទៀត ការកកើតឡើងនូវផ្នត់គំនិតដែលបានផ្តល់សិទ្ធិឲ្យបុគ្គលដែលជាសហព័ទ្ធអាចចូលរួមក្នុងរបបសន្តតិកម្ម មានប្រភពមកពីណា? លើសពីនេះ តើសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្មត្រូវបានការពារយ៉ាងដូចម្តេចខ្លះ? ហើយការការពារសិទ្ធិរបស់សហព័ទ្ធក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ខុសប្លែកពីការការពារសិទ្ធិរបស់សហព័ទ្ធក្នុងក្រមរដ្ឋប្បវេណីជប៉ុនយ៉ាងណាខ្លះ?

ដើម្បីឲ្យកាន់តែច្បាស់ និង ងាយស្រួលក្នុងការបកស្រាយទៅលើប្រធានបទ "ប្រៀបធៀបសន្តតិកម្មរបស់សហព័ទ្ធ(ករណីកម្ពុជា-ជប៉ុន)" ជាដំបូង យើងនឹងធ្វើការស្វែងយល់អំពីសញ្ញាណទូទៅនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន (ជំពូកទី១) និងការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្មកម្ពុជា-ជប៉ុន (ជំពូកទី២)។

# ជំពូកទី១

# សញ្ញាណទូទៅនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន

ជាទូទៅរាល់បុគ្គលគ្រប់ៗរូប តែងតែមាននូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយទ្រព្យសម្បត្តិទាំងនោះទៀតសោត គឺរាប់បញ្ចូលទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ យ៉ាងណាមិញ បើយើងក្រលេកមើលលើពាក្យថាទ្រព្យសម្បត្តិ និងពាក្យថាមតិក[១០]នោះគឺ វាមានន័យប្រហាក់ប្រហែលគ្នា ពោលគឺសំដៅទៅដល់ បណ្តុំនៃទ្រព្យសម្បត្តិទាំងអស់ របស់បុគ្គលនីមួយៗ។ ហើយនៅពេលដែលបុគ្គលនោះទទួលមរណភាពទៅនោះ ទ្រព្យសម្បត្តិទាំងអស់នឹងត្រូវផ្ទេរទៅឲ្យទាយាទរបស់ខ្លួន ឬបុគ្គលណាមួយ (ករណីមតកជន គ្មានទាយាទ) ដែលន័យច្បាប់ត្រូវបានគេហៅថា "របបសន្តតិកម្ម"។

មួយវិញទៀត នៅលើពិភពលោក របបសន្តតិកម្ម មានគោលការណ៍ពីរប្រភេទចម្បងៗ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មានន័យថា សន្តតិជនត្រូវទទួលស្នងមតិកតែម្តង មុននឹងធ្វើការបែងចែក ឬសងបំណុល ជាអាទិ៍ ដោយសន្តតិជនមានសិទ្ធិទទួលយកទាំងស្រុង[១១] ឬទទួលយកដោយមានកម្រិត[១២] ឬលះបង់សន្តតិកម្ម[១៣]។ លើសពីនេះទៅទៀត មានស្ថានភាពមួយចំនួន ដែលមានសហសន្តតិជន និងមានជនដែលបានទទួលទ្រព្យ ដោយប្រទានកម្ម ជាអាទិ៍ នៅពេលដែលមតកជននៅរស់ ហើយដើម្បីធ្វើឲ្យមានសមភាព ជាក់ស្តែង ទាមទារឲ្យមានមធ្យោបាយសម្រួលចំណែកមតិក[១៤] ដែលគាំទ្រដោយច្បាប់។ ដោយឡែក គោលការណ៍ជម្រះបញ្ជី គឺជាការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ហើយសន្តតិជន អាចស្នងមតិកបាន តែក្នុងករណីនៅសល់ទ្រព្យសកម្ម ប៉ុណ្ណោះ និងប្រសិនបើ

---

[១០] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១១៦. ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលបុគ្គលម្នាក់ (មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។

[១១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៩ បានបញ្ញតថា បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។

[១២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦ កថាខណ្ឌ១ បានបញ្ញត្តថា សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ។

[១៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦០ បានបញ្ញត្តថា បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ។

[១៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៣។

កាតព្វកិច្ចធ្ងន់ធ្ងរពេក ត្រូវប្រកាសក្ស័យធន ហើយនីតិវិធីនេះមានលក្ខណៈស្មុគស្មាញ ចំណាយសោហ៊ុយច្រើន ត្រូវការអ្នកច្បាប់ ចំណាយពេលវេលាច្រើន ដែលជាធម្មតា ប្រជាជនទូទៅគ្មានសល់ទ្រព្យសម្បត្តិ សម្រាប់ចំណាយធ្វើការជម្រះបញ្ជីនោះទេ ដោយអ្នកមានទ្រព្យអាចកំណត់ក្នុងមតកសាសន៍ ហេតុនេះ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ស្តីពីសន្តតិកម្ម គឺទទួលយក គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មកធ្វើជាមូលដ្ឋាន[១៥]។

ទន្ទឹមនឹងនេះដែរ នៅក្នុងសន្ធានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ របស់ប្រទេសកម្ពុជាក៏បានកំណត់និយមន័យទៅលើ ពាក្យសន្តតិកម្មថា គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជន[១៦]ទៅឲ្យសន្តតិជន[១៧]ម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[១៨]។ និយមន័យតាមច្បាប់នេះគឺផ្តោតជាសំខាន់ទៅលើការផ្ទេរទ្រព្យ សិទ្ធិ និងករណីយកិច្ច។ ប៉ុន្តែតាមពិតពាក្យ សន្តតិកម្មនេះមានន័យទូលំទូលាយជាងនេះ។ សន្តតិជន ឬទាយាទ អាចទទួលបានមិនត្រឹមតែទ្រព្យ សិទ្ធិ និងករណីយកិច្ចប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវ អត្ថប្រយោជន៍បន្ថែមមួយចំនួនទៀតពី មតកជន (អ្នកស្លាប់)។ មតិកទាំងនោះក៏អាចជាមុខរបរ អំណាចសេដ្ឋកិច្ច (ការដឹកនាំក្រុមហ៊ុន) អំណាចវប្បធម៌ និងអំណាចនយោបាយជាដើម[១៩]។ តាមរយៈនេះយើងអាចសន្មតបាន ថា ការធ្វើសន្តតិកម្មអាចធ្វើបានតាមវិធីពីរយ៉ាង គឺតាមរយៈលិខិតមតកសាសន៍[២០] ដោយការបង្ហាញ ឆន្ទៈរបស់មតកជន

[១៥] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៦, គន្ថីទី៨ ទី៩* ,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ១។

[១៦] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ធានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ធានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១១៧. ជនដែលបានស្លាប់ទៅហើយ។

[១៧] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ធានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ធានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១៩៥. ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

[១៨] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ធានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ធានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១៩៣។

[១៩] ជ័យ រិទ្ធី, *លក្ខខ័ណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់* (ភ្នំពេញ៖ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៥) ទំព័រ ១។

[២០] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ធានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ធានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១១៨. លិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍បន្ទាប់ពីមរណភាព។

និងតាមរយៈការកំណត់របស់ច្បាប់ (ករណីគ្មានលិខិតមតកសាសន៍)[២១]។ របបសន្តតិកម្ម ត្រូវបានចាប់ផ្តើមឡើងដោយមូលហេតុនៃមរណភាព [២២] ឬការទទួលការប្រកាសអំពីការបាត់ខ្លួន [២៣] របស់មតកជន។ គួរកត់សម្គាល់ផងដែរថា សន្តតិកម្មមិនអាចចាប់ផ្តើម ឬធ្វើទៅបាននោះទេ ខណៈពេលបុគ្គលដែលជាមតកជននៅមានជីវិតនៅឡើយ ទោះបីជាមតកជននោះបានធ្វើមតកសាសន៍រួចរាល់ក៏ដោយ។ ក៏ប៉ុន្តែ សន្តតិកម្មអាចនឹងចាប់ផ្តើម ឬនឹងអាចធ្វើទៅបានក្នុងករណី ដែលមានសាលក្រមស្តាពររបស់តុលាការ ដែលប្រកាសអំពីការបាត់ខ្លួនរបស់ជន ដែលនឹងត្រូវក្លាយទៅជាមតកជននោះ។

ដោយឡែក ចំពោះគោលការណ៍នៃសន្តតិកម្មនៅប្រទេសជប៉ុន ក៏ដូចទៅនឹងគោលការណ៍សន្តតិកម្មរបស់កម្ពុជាដែរ។ ពោលគឺ ប្រទេសជប៉ុន ក៏ទទួលយកនូវគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិដែរ[២៤]។ លើសពីនេះ របបសន្តតិកម្មនៃប្រទេសជប៉ុន នឹងត្រូវចាប់ផ្តើមទៅបាន លុះត្រាតែមានលក្ខខណ្ឌមរណភាពរបស់មតកជន[២៥]។ ក៏ប៉ុន្តែដោយយោងតាមឯកសារប្រវត្តិសាស្ត្រវិញ យើងសង្កេតឃើញថា នៅប្រទេសជប៉ុន ធ្លាប់កំណត់នូវលក្ខខណ្ឌផ្សេងទៀត ក្នុងការចាប់ផ្តើមសន្តតិកម្មក្រៅពីលក្ខខណ្ឌមរណភាពរបស់មតកជន គឺមានដូចជាការជាប់ពន្ធនាគារមួយជីវិតរបស់មតកជន (受刑) ការបួសជាបុព្វជិត (僧籍編入) និងការដកហូតសញ្ជាតិ (国籍喪失) ជាដើម[២៦]។ ក៏ប៉ុន្តែលក្ខខណ្ឌទាំងនោះ មិនត្រូវបានយកមកប្រើប្រាស់ជាមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម រហូតមកដល់សម័យបច្ចុប្បន្ននោះទេ គឺមានតែលក្ខខណ្ឌមរណភាពរបស់មតកជន តែប៉ុណ្ណោះដែលអាច

---

[២១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៥ កថាខណ្ឌទី២ បានបញ្ញត្តថា សន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន, សន្តតិកម្ម ដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន។

[២២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៥,កថាខណ្ឌ១ បានចែងថា សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន។

[២៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៣ បានចាត់ទុកជនដែលទទួលការប្រកាសអំពីការបាត់ខ្លួនថា ជននោះបានទទួលមរណភាព ដូច្នេះហើយសន្តតិកម្មត្រូវបានចាប់ផ្តើម។

[២៤] តាកាហាស៊ីតូម្ងកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យីហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២២៨។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、228 頁。

[២៥] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៨២។

[២៦] តាកាហាស៊ីតូម្ងកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យីហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២៣៤។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、234 頁。

ចាត់ទុកថាជាមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម។ មូលហេតុនៃ មរណភាពរបស់មតកជន ត្រង់កន្លែងនេះរាប់បញ្ចូលទាំង ការស្លាប់ដោយធម្មជាតិ（自然死亡）និងការប្រកាសអំពីការបាត់ខ្លួន[២៧]（失踪宣告）។

ការចាត់ទុកថាបានស្លាប់ដោយធម្មជាតិ នេះគឺត្រូវឆ្លងកាត់ការវិនិច្ឆ័យពីសំណាក់ វេជ្ជបណ្ឌិតជំនាញ រួចត្រូវឆ្លងកាត់ចុះបញ្ជីមរណភាព[២៨]រួចរាល់សិនទើបអាចចាប់ផ្តើមបើកសន្តតិកម្មបាន[២៩]។ លើសពីនេះ ករណីមានការសន្និដ្ឋាន ដោយមានហត្ថលេខាពីការិយាធិបតេយ្យ（官公吏）ដែលបានបញ្ជាក់ថា បុគ្គលណាម្នាក់បានស្លាប់ ដោយសារតែ គ្រោះធម្មជាតិ ដូចជា ទឹកជំនន់ រញ្ជួយដី ជាដើម នោះក៏អាចស្នើសុំឲ្យធ្វើសំបុត្រមរណភាពបានដែរ នេះត្រូវបានហៅថា ការស្លាប់ដោយការស្នើសុំ（認定死亡）[៣០]។

ផ្ទុយទៅវិញ ចំពោះករណីដែលបុគ្គលណាម្នាក់បានបាត់ខ្លួន ដោយមិនអាចសន្និដ្ឋានបានថានៅស្លាប់ ឬក៏នៅរស់ក្នុងរយៈពេល៧ឆ្នាំ ក៏ដូចជា បុគ្គលដែលបានបាត់ខ្លួនដោយ ក្រោយពីការលិចកប៉ាល់ ១ឆ្នាំ ដោយគ្មានដំណឹង នោះគឺអាចដាក់ពាក្យសុំទៅ តុលាការគ្រួសារ ចេញនូវការប្រកាសអំពីការបាត់ខ្លួនបាន[៣១]។ ក្រោយពីការប្រកាសអំពីបាត់ខ្លួន បុគ្គលដែលបានបាត់ខ្លួននោះ ត្រូវបានចាត់ទុកថា បានស្លាប់[៣២]ដូចនេះសន្តតិកម្មនឹងត្រូវចាប់ផ្តើម។ ម្យ៉ាងវិញទៀត របបសន្តតិកម្មជប៉ុន ក៏បានបែងចែកចេញជា ២ដែរ គឺ សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍ ដោយនៅប្រទេសជប៉ុន បានកំណត់យក សន្តតិកម្មតាមច្បាប់ជាមូលដ្ឋានគ្រឹះក្នុងការបែងចែកមតិកជាជាងតាមមតកសាសន៍[៣៣]។

ក្រោយពីយល់ពីសញ្ញាណទូទៅនៃរបបសន្តតិកម្មរបស់កម្ពុជា និងជប៉ុនរួចហើយនោះ យើងនឹងធ្វើការសិក្សាបន្ត ទៅលើប្រភពនៃរបបសន្តតិកម្មរបស់ប្រទេស ទាំងពីរផងដែរ ដោយនឹងធ្វើការបកស្រាយនៅក្នុងផ្នែកទី១ ខាងក្រោមនេះ។

[២៧] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៣១។

[២៨] ច្បាប់ស្តីពីអត្រានុកូលដ្ឋានជប៉ុន, ២២ ធ្នូ ឆ្នាំ១៩៤៧, មាត្រា៨៦។

[២៩] តាកាហាស៊ីតូម្ញូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យីហិកាគឺ, ឆ្នាំ២០០៩), ទំព័រទី២៣៤។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、234 頁。

[៣០] ច្បាប់ស្តីពីអត្រានុកូលដ្ឋានជប៉ុន,២២ ធ្នូ ឆ្នាំ១៩៤៧, មាត្រា៨៩។

[៣១] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០។

[៣២] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០។

[៣៣] ណូមីរ៉ា តូយ៉ូហ៊ីរ៉ុ, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១២), ១៦២។

## ផ្នែកទី១៖ ប្រភពនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន

ប្រភពនៃរបបសន្តតិកម្មនៃ ប្រទេសកម្ពុជា និងប្រទេសជប៉ុន គឺពុំមែនទើបតែមានវត្តមាននាសម័យបច្ចុប្បន្ននេះទេ តែគឺមានវត្តមានតាំងពីសម័យបុរាណកាលមកម្ល៉េះ គ្រាន់តែរូបភាព នៃរបបសន្តតិកម្ម នាសម័យនីមួយៗមានលក្ខណៈប្រែប្រួលទៅតាម ការវិវត្តនៃច្បាប់ ក៏ដូចជាទំនៀមទម្លាប់តាមសម័យកាលទាំងនោះ។ ទោះបីជា នៅសម័យដែលពុំទាន់មានច្បាប់ ក៏ដោយ ក៏យើងសង្កេតឃើញថា របបសន្តតិកម្មត្រូវបានគេធ្វើឡើងទៅតាម ប្រពៃណី ទំនៀមទម្លាប់ គ្រួសារ និងសង្គម។ លើសពីនេះទៅទៀត យើងក៏សង្កេតឃើញថា របបសន្តតិកម្មនៃប្រទេសទាំងនេះ បានយកលំនាំតាមប្រទេសដទៃមកធ្វើជាគម្រូ ក្នុងការបង្កើតច្បាប់ស្តីពីសន្តតិកម្មនេះ ឲ្យប្រកបទៅតាមស្តង់ដារជាតិ និង អន្តរជាតិផងដែរ។

ដូចនេះ ដើម្បីឲ្យកាន់តែជ្រាបកាន់តែច្បាស់នោះ យើងនឹងធ្វើការរៀបរាប់អំពី ប្រភពនៃរបបសន្តតិកម្ម នៃប្រទេសទាំងពីរ ដោយមានការបែងចែកចេញជាពីរកថាខណ្ឌ ដែលចំណុចទី១ នឹងសិក្សាអំពីប្រភពនៃរបបសន្តតិកម្មកម្ពុជា ហើយសិក្សាបន្តទៅលើ ចំណុចទី២ ដែលបកស្រាយអំពីប្រភពនៃរបបសន្តតិកម្មជប៉ុន។

### ១. ប្រភពនៃរបបសន្តតិកម្ម កម្ពុជា

ការផ្ទេរបេតិកភ័ណ្ឌដោយមរណភាព ឬដែលពាក្យច្បាប់ហៅថា "សន្តតិកម្ម" នៅប្រទេសកម្ពុជា មានប្រវត្តិចាប់តាំងពីសម័យបុរាណមកម្ល៉េះ គឺចាប់តាំងពីពេលដែលកើតមានគ្រួសារ និងសង្គម។ នៅសម័យមុនអង្គរ ដែលត្រូវបានចាត់ទុកជាសម័យប្រវត្តិសាស្ត្រសម្រាប់កម្ពុជា គឺពុំទាន់មានច្បាប់ស្តីពីសន្តតិកម្មសម្រាប់អនុវត្តនៅឡើយទេ។ ការបែងចែកទ្រព្យសម្បត្តិទៅឲ្យទាយាទ គឺគេធ្វើទៅតាមទំនៀមទម្លាប់ដែលបានអនុវត្តតៗគ្នាដូចជា កំណត់យកកូនច្បងនៃគ្រួសារជាអ្នកស្នងមតិកជាដើម។ ផ្អែកតាមឯកសារជាប្រវត្តិសាស្ត្រ បានបង្ហាញថា ស្តេចនាសម័យនោះតែងតែធ្វើសារបណ្តាំ ទុកមុនពេលដែលទ្រង់សោយទិវង្គត សម្រាប់ជ្រើសរើសរាជបុត្រារបស់ព្រះអង្គណាម្នាក់ឲ្យឡើងសោយរាជ្យបន្តពីព្រះអង្គ។ ចំពោះគ្រួសារមន្ត្រី នៅពេលដែលឪពុកបានទទួលមរណភាពកូនប្រុសរបស់មន្ត្រីនោះជា អ្នកស្នងតំណែងមន្ត្រី ព្រមទាំងគ្រប់គ្រងទ្រព្យសម្បត្តិបន្តពីឪពុកខ្លួន។ ឯគ្រួសាររាស្ត្រសាមញ្ញវិញ ក៏ប្រកាន់ទម្លាប់ដូចជាខ្សែរាជវង្ស និងគ្រួសារមន្ត្រីដែរ គឺឲ្យតម្លៃទៅលើអ្នកស្នងមតិកដែលជាកូនប្រុស។

ការផ្ទេរមតិកពីឪពុកទៅឲ្យកូនបន្តនោះ បានក្លាយទៅជាទំនៀមទម្លាប់សម្រាប់អនុវត្តនៅក្នុងសង្គម ហើយការអនុវត្តអ្វីមួយ ដែលពុំមានច្បាប់ទម្លាប់តែងតែបង្កនូវភាពអយុត្តិធម៌ចំពោះទាយាទផ្សេងទៀត នៅពេលដែលម្ចាស់បណ្តាំប្រគល់មតិកទៅឲ្យសន្តតិជនតែម្នាក់ រីឯសន្តតិជនផ្សេងទៀតមិនបានទទួលមតិក ទាំងដែលពួកគេមិនបានប្រព្រឹត្តកំហុស។

ខាងក្រោមនេះ គឺជាការបកស្រាយអំពី ប្រភពជាតិ (១.១) ព្រមទាំងប្រភពអន្តរជាតិ នៃរបបសន្តតិកម្មរបស់កម្ពុជា ថាតើរបបសន្តតិកម្មនៃប្រទេសកម្ពុជា មានការវិវត្ត និង ការប្រែប្រួលយ៉ាងដូចម្តេចខ្លះ?

## ១.១. ប្រភពជាតិនៃរបបសន្តតិកម្ម កម្ពុជា

ការបែងចែកទ្រព្យសម្បត្តិតាមសន្តតិកម្ម នៅកម្ពុជាបានបញ្ញត្តក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាជាយូរមកហើយ ដូចជាក្រមមតិក (១.១.១) ដែលមានចាប់តាំងមុនសម័យអាណាព្យាបាលបារាំងមកម្ល៉េះ។ ក្រោយមក យើងមានក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០ (១.១.២) ហើយក្រោយៗមកទៀត ទើបមានក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ (១.១.៣) ដែលយើងកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះដែលជាវិធានច្បាប់ចម្បងទាក់ទងទៅនឹងរបបសន្តតិកម្មនេះ ដោយយើងនឹងធ្វើការសិក្សាលម្អិតទៅលើចំណុចនីមួយៗ ដូចខាងក្រោមនេះ។

### ១.១.១. ក្រមមតិក កម្ពុជា

នាចុងសតវត្ស ១២៣៨ ត្រូវនឹងគ្រឹស្តសករាជ ១៨៩១ ក្នុងរជ្ជកាលព្រះបាទ នរោត្តម ក្រម មតិកត្រូវបានបង្កើតឡើង ដោយបែងចែកចេញជា៧០មាត្រា។ នៅក្នុងក្រមមតិកនេះ បានចែងយ៉ាងលម្អិតទាក់ទងទៅនឹងរបបសន្តតិកម្ម នៃប្រទេសកម្ពុជាដោយមានខ្លឹមសារដូចខាងក្រោម[៣៧]៖

- ទ្រព្យសម្បត្តិប្តី ឬ ប្រពន្ធដែលស្លាប់ទៅដោយឥតមានកូន ត្រូវចាត់ទុកជាទ្រព្យអារ ដែលត្រូវបញ្ចូលជាទ្រព្យហ្លួង
- បើអ្នកស្លាប់មានបំណោចបំណានក្នុងរាជការតែគ្មានមាតាបិតាបុត្រ ឬ ភរិយាទេនោះមតិកត្រូវប្រគល់ឲ្យទៅញាតិសណ្តាន
- មតិករបស់អ្នកស្លាប់ដែលមានបណ្តាសក្តិតែគ្មានបំណោចបំណាន ត្រូវបែងចែងដូចតទៅ៖

[៣៧] ហៃល ចំរើន, *កម្រងច្បាប់ខ្មែរពីបុរាណ* (បទបង្ហាញនៅសណ្ឋាគារសូហ្វីតែលភ្នំពេញ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៦), លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម, *កម្រងច្បាប់ខ្មែរពីបុរាណ* (ភ្នំពេញ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៦) ភាគ២។

- ទ្រព្យជាព្រះរាជទាន ត្រូវយកចូលព្រះឃ្លាំងហ្លួង
- ទ្រព្យដែលនៅសល់ ត្រូវទូទាត់សងបំណុល
- សល់ពីនេះ ត្រូវបែងចែកជា ៤ភាគស្មើគ្នា ឲ្យទៅព្រះឃ្លាំងហ្លួង ឪពុកម្តាយ ភរិយា កូនចៅ ផៅសន្តានដែលបានឲ្យថ្នាំចាំជម្ងឺ លើកខ្មោចស្រោចផ្លឹង។

- បើអ្នកស្លាប់គ្មានប្រពន្ធ កូន ឪពុកម្តាយ តែមានចៅផៅសន្តាន ទ្រព្យត្រូវចែកជា ៣ភាគ ដែល ២ភាគឲ្យចូលឃ្លាំងហ្លួង និង ១ភាគឲ្យទៅតែចៅផៅសន្តានដែលបានឲ្យថ្នាំចាំជម្ងឺ លើកខ្មោចស្រោចផ្លឹង
- បើអ្នកស្លាប់ ជាអ្នកមានបណ្តាសក្តិ ទ្រព្យត្រូវបែងចែកតាមជំពូកភរិយាទាំង៤ជំពូក [៣៥] គឺ ភរិយាស្ដីដណ្ដឹងមានខាន់ស្លាចំនួន ៣ភាគកន្លះ ភរិយាជារង្វាន់ព្រះរាជទានចំនួន ៣ភាគ ភរិយាបង្គំទូលសុំចំនួន ២ភាគកន្លះ និងនានាភរិយាចំនួន ២ភាគកន្លះ ក្នុងករណីភរិយាក្នុងជំពូកនីមួយៗរួមរស់ប្រកបរបររកស៊ីជាមួយគ្នា ចាប់ពី ៣ឆ្នាំឡើងទៅ នឹងបានឲ្យថ្នាំចាំជម្ងឺ បិទមាត់ ត្រឡប់ភ្នែក លើកខ្មោចស្រោចផ្លឹងឲ្យសពប្តីដូចៗគ្នា[៣៦]
- ចំណែកមតិកនៃ ភរិយា៤ជំពូក អាស្រ័យលើរយៈពេលរស់នៅជាមួយគ្នា គុណូបការកិច្ចចំពោះសពប្តី និងជំពូកនៃភរិយានីមួយៗ
- កូន ៥ជំពូកដែលគប្បីទទួលបានចំណែកមតិក។

### ១.១.២. ក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ឆ្នាំ១៩២០

ក្រមរដ្ឋប្បវេណីចាស់នៃប្រទេសកម្ពុជា គឺជាក្រមរដ្ឋប្បវេណីដំបូងដែលត្រូវបានបង្កើតឡើងនៅក្នុងសម័យកាលដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្រោមអាណានិគមនិយមបារាំង [៣៧] និង ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។ ប្រទេសកម្ពុជាបានធ្វើការតាក់តែងនូវក្រមរដ្ឋប្បវេណីនេះ ដោយមានមាត្រាសរុបចំនួន ១៣៦៥មាត្រា ក្រោមការផ្តល់ជំនួយពីបារាំង ដែលជាអាណាព្យាបាលតាំងពីសម័យមុនពេលបង្កើតរដ្ឋធម្មនុញ្ញ [៣៨] ទៅទៀត។ ក្រមនេះបានក្រសោបយកស្ទើគ្រប់ផ្នែកពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី ដែលក្នុងនោះ បទប្បញ្ញត្តិពាក់ព័ន្ធនឹងសន្តតិកម្មក៏ត្រូវ

[៣៥] ក្រមទសភរិយា ឆ្នាំ១៨៥៣ បានកំណត់ពី ភរិយាទាំង៤ជំពូក។

[៣៦] ក្រមមតិក ឆ្នាំ១៨៧៦, មាត្រា១២។

[៣៧] កម្ពុជាស្ថិតក្រោមអាណានិគមនិយមបារាំងអស់រយៈពេលជិត៩០ឆ្នាំ គឺចាប់ពីឆ្នាំ១៨៦៨ ដល់ឆ្នាំ១៩៥៨។

[៣៨] កម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញដំបូងបំផុតក្នុងប្រវត្តិសាស្ត្រក្នុងឆ្នាំ ១៩៤៧។

បានបញ្ញត្តយ៉ាងលម្អិតផងដែរ ចាប់ពីមាត្រា៤៨៦ ដល់មាត្រា៦២៦ ប៉ុន្តែស្ថានភាពសង្គមនាសម័យនោះ ពុំទាន់មានការទទួលស្គាល់នូវសមភាពរវាងបុរស និងស្ត្រីនៅឡើយទេ។

ជាក់ស្តែង ក្នុងក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០ នេះបានកំណត់ថា សហព័ទ្ធរបស់មតកជនអាចមានសិទ្ធិទទួលសន្តតិកម្មបានលុះត្រាតែ ករណី ដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ បងប្អូនបង្កើត និង សន្តតិជនជំនួស ជនទាំងនោះប៉ុណ្ណោះ។ ដូច្នេះ ក្នុងករណីដែលមានសន្តតិជនលំដាប់មុន សហព័ទ្ធរបស់មតកជនមានសិទ្ធិ ទទួលបានតែទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន រួមទាំងពាក់កណ្តាលនៃទ្រព្យសម្បត្តិរួមប៉ុណ្ណោះ។ ផ្ទុយមកវិញ ប្រសិនបើ សហព័ទ្ធក្លាយជាសន្តតិជននោះ សហព័ទ្ធនឹងទទួលសន្តតិកម្មទាំងអស់តែម្នាក់ឯង។ ទោះបីជាយ៉ាងណា នេះជាការបង្ហាញឲ្យឃើញថា សហព័ទ្ធត្រូវបានរឹតត្បិតចំពោះសិទ្ធិក្នុងសន្តតិកម្ម ដែលមានលទ្ធភាពតិចតួចបំផុត ក្នុងការទទួលបានឋានៈជាសន្តតិជន។

ទោះបីជា ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០ របស់កម្ពុជាត្រូវបានតាក់តែងឡើង ដោយមិនបានគោរពសមភាពរវាង បុរស និង ស្ត្រីក៏ដោយ ក៏ច្បាប់នេះហាក់ត្រូវបានតុលាការយកមកធ្វើជាមូលដ្ឋាននៃ ការសម្រេចសេចក្តីពាក់ព័ន្ធនឹងសន្តតិកម្មផងដែរ។ ពោលគឺ ច្បាប់នេះត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយរាល់ជម្លោះដែលទាក់ទងទៅនឹងមតិក។ ពោលគឺ ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ នេះគឺជាបច្ច័យមួយដ៏សំខាន់ក្នុងការអនុវត្ត និងដោះស្រាយបញ្ហាសន្តតិកម្ម នៅសម័យនោះរហូតដល់ឆ្នាំ ១៩៧៥។

### ១.១.៣. ក្រមរដ្ឋប្បវេណីកម្ពុជាថ្មី ឆ្នាំ២០០៧

សម័យកាលចេះតែទៅមុខ សង្គមក៏កាន់តែមានការវិវត្ត បញ្ហាថ្មីៗក៏តែងតែកើតមានឡើងធ្វើឲ្យច្បាប់ដែលបង្កើតនៅសម័យមុន មិនស្របទៅនឹងបញ្ហាដែលសង្គមកំពុងតែទទួល។ ពិនិត្យមកលើ ច្បាប់ស្តីពីសន្តតិកម្ម ដែលមានចែងនៅក្រមរដ្ឋប្បវេណីសង្គមចាស់ បើធៀបមកពេលបច្ចុប្បន្នឃើញថាមានភាពខ្វះចន្លោះច្រើន។

លុះដល់ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ កន្លងទៅនេះកម្ពុជាបានប្រកាស ឲ្យប្រើក្រមរដ្ឋប្បវេណីថ្មីរបស់ខ្លួនដែលបានចងក្រងរួចរាល់ ដែលក្នុងនោះ បានធ្វើនូវទំនើបកម្មមានលក្ខណៈបច្ចុប្បន្នភាពដោយគោរពនូវរាល់ គោលការណ៍ជាសកលស្របទៅតាម បច្ចេកវិទ្យាទំនើប ព្រមទាំងប្រតិបត្តិការអាជីវកម្មដែលចេះតែរីកចម្រើនឥតឈប់ឈរ ក្រោមការជ្រោមជ្រែង ពីរាជរដ្ឋាភិបាលជប៉ុន ដែលក្នុងនោះ បញ្ញត្តិស្តីពីសន្តតិកម្មត្រូវបានចែងយ៉ាងលម្អិត និង ច្បាស់លាស់ជាង បើប្រៀបទៅនឹងក្រម

មតិក ឆ្នាំ១៨៩១ និងក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩២០។ ជាពិសេសបើប្រៀបធៀបពីទំហំនៃសិទ្ធិរបស់សហព័ទ្ធចំពោះសន្តតិកម្មរវាង ក្រមរដ្ឋប្បវេណីចាស់ និង ក្រមរដ្ឋប្បវេណីថ្មី អាចឲ្យគេឃើញថាមានការវិវត្ត គួរឲ្យកត់សម្គាល់ជាច្រើន ដែលស្តែងពីការទទួលស្គាល់ ពីការចូលរួមរបស់សហព័ទ្ធទាំងសងខាង ជាពិសេសគឺសហព័ទ្ធជាស្ត្រីក្នុងទំនាក់ទំនងគ្រួសារ និងសន្តតិកម្ម ដោយសម្របទៅតាមសង្គមនាពេលបច្ចុប្បន្ន និងស្របទៅតាមរដ្ឋធម្មនុញ្ញទៀតផង។

ក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧នេះ មានភាពដូចគ្នានឹងក្រមរដ្ឋប្បវេណីចាស់ដែរ ទ្រព្យសម្បត្តិជាមតិករួមមាន ទ្រព្យសម្បត្តិដោយឡែករបស់មតកជន និង ពាក់កណ្តាលនៃទ្រព្យរួម។ ប៉ុន្តែដោយសារតែ មានការប្រែប្រួលនូវលំដាប់សន្តតិកម្មរបស់សហព័ទ្ធ ចំណែកមតិករបស់សហព័ទ្ធក្នុងក្រមរដ្ឋប្បវេណីថ្មី មានការកើនឡើងច្រើនជាង បើប្រៀបធៀបនឹងក្រមរដ្ឋប្បវេណីចាស់។ ក្នុងក្រមរដ្ឋប្បវេណីថ្មីនេះ ចំណែកមតិករបស់ សហព័ទ្ធត្រូវបានកំណត់ទៅតាមលំដាប់ដែលសហព័ទ្ធនោះត្រូវទទួលសន្តតិកម្មជាមួយសន្តតិជនផ្សេងទៀត។

បន្ទាប់ពីបានសិក្សាទាក់ទងទៅនឹងប្រភពជាតិនៃរបបសន្តតិកម្មរបស់កម្ពុជា រួចហើយ យើងនឹងធ្វើការសិក្សាបន្ថែមទៅលើ ប្រភពអន្តរជាតិ (១.២) នៃរបបសន្តតិកម្មរបស់កម្ពុជាវិញម្តង ថាតើរបបសន្តតិកម្ម បានទទួលឥទ្ធិពលពីប្រទេសណាខ្លះ?

### ១.២. ប្រភពអន្តរជាតិនៃរបបសន្តតិកម្ម កម្ពុជា

របបនៃកាផ្ទេរបេតិកភណ្ឌរបស់ប្រទេសកម្ពុជា ដែលយើងហៅថា របបសន្តតិកម្មនេះ ត្រូវបានគេទទួលស្គាល់ថា បានទទួលឥទ្ធិពលមកពីប្រទេសបារាំង តាមរយៈការបង្កើតឲ្យមាននូវ ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ និងមួយទៀតគឺប្រទេសជប៉ុន តាមរយៈនៃការចងក្រងនូវក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ របស់កម្ពុជា ដែលមានរូបភាពដូចខាងក្រោមនេះ៖

ដូចបានបង្ហាញខាងលើរួចមកហើយថា ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩២០ របស់កម្ពុជាយើង ត្រូវបានទទួលរងឥទ្ធិពលពី ក្រមនៃប្រទេសបារាំង ដោយយើងសង្កេតឃើញថា ក្រមសង្គមចាស់របស់យើង នៅតែមានភាពរឹតត្បិត នៅឡើយចំពោះសហព័ទ្ធដែលនៅរស់ ជាពិសេសគឺសហព័ទ្ធជាស្ត្រីតែម្តង។ តែទោះជាយ៉ាងណាក៏ដោយ ក៏ក្រមសង្គមចាស់នៅតែមានអានុភាព អនុវត្តទៅលើជម្លោះទាក់ទងទៅនឹងមតិកនាសម័យនោះផងដែរ។

ម្យ៉ាងវិញទៀត ដូចដែលធ្លាប់បានលើកឡើងខាងលើ ក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧ របស់កម្ពុជាត្រូវបានតាក់តែងឡើងដោយទទួលឥទ្ធិពលពីខាងក្រមរដ្ឋប្បវេណីរបស់ ប្រទេសជប៉ុន ហេតុ

ដូចនេះហើយបទប្បញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីថ្មី ដែលរួមមានទាំង លំដាប់នៃសន្តតិកម្ម តាមច្បាប់របស់សហព័ទ្ធផងនោះ ក៏ត្រូវបានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនផង ដែរ។ លើសពីនេះ ទស្សនៈដែលចាត់ទុកថា សហព័ទ្ធត្រូវក្លាយទៅជាសន្តតិជនជានិច្ចជាដើមនេះ ក៏ ត្រូវបានយកលំនាំតាម ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនដែរ ។

ក្រោយពីបានយល់ច្បាស់ពីប្រភពជាតិ និងអន្តរជាតិនៃរបបសន្តតិកម្មកម្ពុជាហើយ យើង នឹងធ្វើការពន្យល់អំពីប្រភពនៃរបបសន្តតិកម្មជប៉ុន (ចំណុចទី២) វិញម្តង ថាតើមានលក្ខណៈខុស ប្លែកពី ប្រភពនៃរបបសន្តតិកម្ម កម្ពុជាយ៉ាងដូចម្តេចខ្លះ?

## ២. ប្រភពនៃរបបសន្តតិកម្ម ជប៉ុន

របបសន្តតិកម្មនៅប្រទេសជប៉ុន មានការប្រែប្រួលជាច្រើនសម័យកាល គឺដំបូងឡើយ នៅ សម័យរីហ្ស៊ឺរ្យូ (律朝時代) នាចន្លោះពាក់កណ្តាលសតវត្សទី៧ និង ទី១០ ដោយសារតែមានការ បែងចែកវណ្ណៈ ទើបនៅសម័យនោះប្រកាន់ផ្នត់គំនិត ឲ្យកូនប្រុសច្បងជាអ្នកកាន់កាប់ទ្រព្យសម្បត្តិ របស់គ្រួសារទាំងមូល។ ក៏ប៉ុន្តែ ក្នុងករណីដែលមានបណ្តាំមតិក (មតកសាសន៍) នោះពួកគេនឹងធ្វើ សន្តតិកម្មរួមគ្នា។ ដោយឡែក នៅក្នុងវណ្ណៈ កសិករ ឈ្មួញ ជាដើមនោះ គឺគេមិនប្រកាន់យកការធ្វើ សន្តតិកម្មដោយកូនច្បងនោះទេ។ ក៏ប៉ុន្តែ លុះដល់ក្រោយ សម័យខាមាគុរ៉ា (鎌倉時代) ចន្លោះឆ្នាំ ១១៨៥ ដល់ ឆ្នាំ១៣៣៣ ប្រព័ន្ធច្បាប់សក្តិភូមិ ក៏បានចាប់ផ្តើម។ បន្ទាប់មកទៀត នៅសម័យអេដុ (江戸時代) នាចន្លោះឆ្នាំ១៨០៣ ដល់ឆ្នាំ១៨៦៨ ច្បាប់របស់ត្រកូលកងទ័ព (武家法) ត្រូវបាន បង្កើតឡើង ហើយប្រព័ន្ធសន្តតិកម្មដោយកូនច្បង ក៏ត្រូវបានគ្របដណ្តប់ទូទាំងប្រទេសជប៉ុនតែ ម្តង។ លុះចូលដល់សម័យមេជិ (明治時代) ចន្លោះឆ្នាំ១៨៦៨ ដល់១៩១២ ច្បាប់ ស្តីពីសន្តតិកម្ម របស់ប្រទេសជប៉ុនដំបូងបង្អស់ត្រូវបានបង្កើតឡើង[១៨]។ លើសពីនេះ របបសន្តតិកម្មរបស់ប្រទេស ជប៉ុន ក៏ត្រូវបានរងឥទ្ធិពលពីប្រទេសជិតខាងផងដែរ។ ដើម្បីឲ្យកាន់តែច្បាស់យើង នឹងធ្វើការបក ស្រាយអំពី ប្រភពជាតិ (២.១) និងប្រភពអន្តរជាតិ (២.២) នៃរបបសន្តតិកម្មរបស់ប្រទេសជប៉ុនដូច ខាងក្រោមនេះ។

[១៨] តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យ៉ឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២២៨។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、228 頁。

## ២.១. ប្រភពជាតិនៃរបបសន្តតិកម្ម ជប៉ុន

ការបែងចែកទ្រព្យសម្បត្តិតាមសន្តតិកម្ម នៅជប៉ុនបានបញ្ញត្តក្នុងប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនជាយូរមកហើយ ដូចជា ក្រមរដ្ឋប្បវេណីសម័យមេជិ ឆ្នាំ១៨៩៨ (២.១.១) ។ ក្រោយមក ឃើញមានវិសោធនកម្មក្រមរដ្ឋប្បវេណី សម័យស្យូវ៉ា (២.១.២) ហើយក្រោយៗមកទៀត ទើបមានក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ១៩៨០ (២.១.៣) ដែលបាននឹងកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ ដែលជាវិធានច្បាប់ចម្បងៗទាក់ទងនឹងរបបសន្តតិកម្មនេះ ដូចនេះយើងនឹងធ្វើការសិក្សាលម្អិតទៅលើ ចំណុចនីមួយៗ ដូចខាងក្រោមនេះ។

### ២.១.១. ក្រមរដ្ឋប្បវេណីជប៉ុនសម័យមេជិ ឆ្នាំ១៨៩៨

នាឆ្នាំ ១៨៩៨ ក្រមរដ្ឋប្បវេណីដំបូងបង្អស់របស់ប្រទេសត្រូវបានចងក្រងឡើងរួចរាល់ និងត្រូវបានប្រកាសឲ្យប្រើជាស្ថាពរ ដែលត្រូវបានគេហៅថា ជាក្រមរដ្ឋប្បវេណីសម័យមេជិ។ ក្រមនេះត្រូវបានចងក្រងឡើង ដោយយកប្រព័ន្ធច្បាប់ត្រកូលកងទ័ពមកធ្វើជាលំនាំ ពោលគឺបានកំណត់ជាស្រេច នូវរបបសន្តតិកម្មដោយកូនច្បង។ ពីព្រោះថា គោលគំនិតសំខាន់នៃក្រមរដ្ឋប្បវេណីសម័យមេជិនេះ ត្រូវបង្កើតឡើងដោយកំណត់ថា ប្រជាជនទាំងអស់ត្រូវតែឋិតនៅក្រោមការឃុំគ្រង របស់គ្រួសារមួយ ហើយនៅក្នុងគ្រួសារនីមួយៗ ត្រូវតែមានមេគ្រួសារម្នាក់ដែលជាអ្នកកាន់កាប់រាល់ទ្រព្យសម្បត្តិ ក៏ដូចជាការចាត់ចែងផ្សេងៗនៅក្នុងគ្រួសារទាំងអស់។ ឧទាហរណ៍៖ មេគ្រួសារមានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការសម្រេចទៅលើរឿងអាពាហ៍ពិពាហ៍របស់កូនចៅ ព្រមទាំងការសុំកូនផ្សេងៗ ចូលមកក្នុងគ្រួសាររបស់ខ្លួន។ មានន័យថា ប្រសិនបើគ្មានការយល់ព្រមពីមេគ្រួសារទេ គឺអាពាហ៍ពិពាហ៍នឹងមិនអាចកើតឡើងបានទេ[៤០]។

ចំណែកឯរបបសន្តតិកម្មដោយកូនច្បងនេះ គេអាចហៅបានម៉្យាងទៀតបានថា សន្តតិកម្មតាមរបបមេគ្រួសារនិយម（家督相続）។ របបសន្តតិកម្ម នាសម័យនោះបានបែងចែកលំដាប់សន្តតិជន ដូចតទៅ៖ កូនប្រុសច្បង ជាសន្តតិជនលំដាប់ទី១, កូនដែលមានខាន់ស្លា ត្រូវបានក្លាយជាសន្តតិជនលំដាប់ទី២, និងកូនដែលមានអាទិភាពជាងគេ (កូនប្រុស) ត្រូវក្លាយជាសន្តតិជន

[៤០] តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២២៩។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、229 頁。

លំដាប់ទី៣[៤១]។ ឧទាហរណ៍ កូនប្រុសឥតខាន់ស្លា មានអាទិភាពជាង កូនស្រីដែលមានខាន់ស្លា។ លើសពីនេះទៅទៀត សន្តតិកម្មតាមរបបមេគ្រួសារនិយមនេះ ការស្លាប់ ការដកហូតសញ្ជាតិ ការចូលនិវត្តន៍ និងការជាប់ពន្ធនាគារមួយជីវិត គឺត្រូវបានគេចាត់ទុកជាមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម[៤២]។

### ២.១.២. វិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន សម័យស្យូវ៉ា

លុះដល់សម័យតៃស្យូ (大正時代) ចន្លោះឆ្នាំ១៩១២ ដល់ ឆ្នាំ១៩២៦ ការពិភាក្សាអំពីការវិសោធនកម្ម ទៅលើច្បាប់ស្តីពីសន្តតិកម្មរបស់ប្រទេសជប៉ុន ត្រូវបានដំណើរការទៅយ៉ាងរលូន។ លុះដល់សម័យស្យូវ៉ា (昭和時代) ចន្លោះឆ្នាំ១៩២៦ ដល់ ឆ្នាំ១៩៨៩ វិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ ១៩២៧ ក៏ត្រូវបានប្រកាសជាសាធារណៈ ដោយនឹងកំណត់យកការកែប្រែទៅរកវិធានច្បាប់មួយ ដែលសមស្របទៅតាមស្ថានភាពគ្រួសារជាក់ស្តែង។ ក៏ប៉ុន្តែ ការធ្វើវិសោធកម្មដែលល្អជាងនេះទៅទៀត គឺនៅឆ្នាំ១៩៤៧ សម័យស្យូវ៉ាដដែល គឺជាការធ្វើវិសោធនកម្មដោយសម្របទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុន ដោយបានលុបបំបាត់ចោលនូវ របបសន្តតិកម្មមេគ្រួសារនិយមទាំងស្រុងតែម្តង ដោយសម្រេចឲ្យមានការធ្វើសន្តតិកម្មរួមគ្នា ព្រមទាំងបញ្ញត្តឲ្យសហព័ទ្ធដែលនៅរស់មានសិទ្ធិធ្វើសន្តតិកម្ម រួមគ្នាជាមួយសហសន្តតិជនដទៃទៀត[៤៣]។ លុះក្រោយមកទៀត នៅឆ្នាំ១៩៦៧ ក៏បានធ្វើការកំណត់បន្ថែមទាក់ទងទៅនឹង ការប្រកាសអំពីការបាត់ខ្លួន[៤៤] ការសន្មតជាមុនអំពីការស្លាប់[៤៥] សន្តតិជនជំនួស[៤៦] ការបោះបង់សន្តតិកម្ម[៤៧] និងការបែងចែកមត៌កទៅឲ្យជនដែលមាននិស្ស័យពិសេស ក្នុងករណីអវត្តមានសន្តតិជន[៤៨]ជាដើមផងដែរ។ សម័យកាលចេះតែវិវត្តទៅមុខ លុះដល់ឆ្នាំ១៩៨០ ក្រមរដ្ឋប្បវេណីក៏បានកែប្រែទៅលើចំណុចមួយចំនួនផ្សេងទៀត ដូចជាៈ

[៤១] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៧០។

[៤២] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៦៤។

[៤៣] តាកាហាស៊ីតូម្ងកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យីហិកាគឹ, ឆ្នាំ ២០០៩), ទំព័រទី២២៩។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、229 頁。

[៤៤] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៣០។

[៤៥] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៣២។

[៤៦] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៨៨៧។

[៤៧] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៩៣៩។

[៤៨] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៩៥៨។

ការបន្ថែមចំណែកមត៌ករបស់សហព័ទ្ធ ការកម្រិតនូវសិទ្ធិជាសន្តតិជនជំនួសរបស់បងប្អូនបង្កើត ក៏ដូចជាភាគនៃភាគបម្រុងផងដែរ[៥៩]។

ក្រោយពីបានសិក្សាទាក់ទងទៅនឹង ប្រភពជាតិ នៃរបបសន្តតិកម្មរបស់ជប៉ុន រួចមក បន្ទាប់មកទៀត យើងនឹងធ្វើការសិក្សាបន្ថែមទៅលើ ប្រភពអន្តរជាតិ (២.២) នៃរបបសន្តតិកម្មរបស់ជប៉ុនវិញម្តង ថាតើរបបសន្តតិកម្ម បានទទួលឥទ្ធិពលពីប្រទេសណាខ្លះ?

## ២.២. ប្រភពអន្តរជាតិនៃរបបសន្តតិកម្ម ជប៉ុន

របបសន្តតិកម្មនៃប្រទេសជប៉ុន ត្រូវបានទទួលឥទ្ធិពល ពីប្រទេសជាច្រើនដូចជា ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ និងប្រទេសអង់គ្លេស ដោយមានរូបភាពដូចខាងក្រោម៖

ច្បាប់ស្តីពីសន្តតិកម្មនៃប្រទេសជប៉ុន ត្រូវបានចាប់កំណើត ដោយទទួលរងនូវឥទ្ធិពលពីក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំងដែលជា ក្រមច្បាប់សរសេរ ដោយឈរលើ គោលជំហរនៃផ្នត់គំនិតនៃបដិវត្តន៍ប្រជាជន ហើយក៏ជាក្រមច្បាប់មួយក្នុងចំណោម ក្រមច្បាប់ស្តីពីសន្តតិកម្ម ក្នុងសម័យទំនើបនៃលោកខាងលិចផងដែរ។ ក៏ប៉ុន្តែ ឆ្លងកាត់នូវនីតិវិធីបង្កើតច្បាប់ស្តីពីសន្តតិកម្ម ក្នុងអំឡុងឆ្នាំ ១៨៩៨ (សម័យមួយនៃប្រទេសជប៉ុន សម័យមេជិ) សង្កេតឃើញថា មានការទាមទារ ឲ្យកំណត់នូវអត្ថន័យ នៃច្បាប់ស្តីពីសន្តតិកម្មជប៉ុនថា សិទ្ធិអំណាចក្នុងការគ្រប់គ្រងគ្រួសារទាំងមូល ព្រមទាំងទ្រព្យសម្បត្តិរបស់គ្រួសារទាំងអស់ ត្រូវប្រគល់ទៅឲ្យ កូនប្រុសច្បងដែលមានខាន់ស្លាកាន់កាប់ដោយឯករាជ្យ ដែលគេហៅថាជា សន្តតិកម្មតាមរបបមេគ្រួសារនិយម។ ហេតុដូចនេះទើបនាំឲ្យមានចរឹកលក្ខណៈផ្ទុយគ្នាពី ច្បាប់ស្តីពីសន្តតិកម្មរបស់បារាំងបន្តិចបន្តួច ទោះបីជា បញ្ញត្តិស្តីពីសន្តតិកម្មតាមច្បាប់ ដូចគ្នាទាំងស្រុងក៏ដោយ។ លុះដល់ ឆ្នាំ ១៩៤៧ (សម័យមួយនៃប្រទេសជប៉ុន សម័យស្យូវ៉ា) ច្បាប់ស្តីសន្តតិកម្មជប៉ុន ត្រូវបានវិសោធនកម្ម ដោយបានសម្រេចលុបចោលនូវ បញ្ញត្តិស្តីពីសន្តតិកម្មមេគ្រួសារ ដោយបន្ថែមមកវិញនូវ បញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍ ដែលយើងអាចហៅថា សន្តតិកម្មតាមបណ្តាំ។ ក្រោយពីការឆ្លងកាត់ ការធ្វើវិសោធនកម្ម ច្បាប់ស្តីពីសន្តតិកម្ម ជប៉ុនក្នុងឆ្នាំ ១៩៤៧ នេះមក គួរឲ្យកត់សម្គាល់ផងដែរថា គោលការណ៍គ្រឹះ និង អត្ថន័យដូចគ្នាទាំងស្រុង។ មានន័យថា ច្បាប់ស្តីពីសន្តតិកម្មជប៉ុន ចាស់ និង ច្បាប់ បារាំងបានទទួលយកនូវគោលការណ៍ទាំង៣ ដូចគ្នា គឺ គោលការណ៍ទទួលមត៌ក ដោយការបញ្ចូល (包括継承主義) (ដើមឡើយ បុគ្គលដែលត្រូវទទួលមត៌ក ពុំមានសិទ្ធិតាមច្បាប់ ក្នុងការទទួលសន្តតិកម្ម តែទទួលបានការផ្តល់សិទ្ធិពី មតកជនតាមរយៈមតកសាសន៍ ឬ បណ្តាំ) ព្រមទាំង គោលការណ៍ទទួលមត៌ក

[៥៩] តាកាហាស៊ីតូម្ញកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិ និងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២២៩។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、229 頁。

ដោយស្វ័យប្រវត្តិ (当然継承主義) (ករណីបុគ្គលណាម្នាក់ត្រូវបានក្លាយជា សន្តតិជន តាមការកំណត់របស់ច្បាប់) ។

លើសពីនេះ ច្បាប់ស្តីពីរបបសន្តតិកម្ម របស់ជប៉ុន ក៏ត្រូវបានបញ្ញត្តឡើង ដោយយកលំនាំតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី របស់ប្រទេសអាល្លឺម៉ង់ផងដែរ។ ប៉ុន្តែ ដោយសារ ក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់ ត្រង់បញ្ញត្តិស្តីពី គោលការណ៍ សន្តតិកម្មតាមមតិកសាសន៍ ត្រូវបានទទួលឥទ្ធិពលមកពីច្បាប់រ៉ូមាំង ដូចនេះគឺត្រូវបានគេយកលំនាំតាម ចំណុចដែលពាក់ព័ន្ធមួយចំនួន តែប៉ុណ្ណោះ។ ចំពោះគោលការណ៍ សន្តតិកម្មតាមមតកសាសន៍ គឺត្រូវបានយកលំនាំតាមប្រទេសអង់គ្លេស ដោយហេតុថា នាសតវត្សន៍ ទី ១៩ សម័យវីតូរៀន (Victorian Era) គឺច្បាប់នៃប្រទេសអង់គ្លេស មានការជឿនលឿនខ្លាំងជាងគេ ដូច្នេះ ហើយទើបផ្ទត់គំនិតនៃការយកច្បាប់របស់ប្រទេសអង់គ្លេសមកធ្វើជា គម្រូក្នុងការបង្កើត ច្បាប់ស្តីពីសន្តតិកម្ម ត្រង់បញ្ញត្តិសន្តតិកម្មតាមមតិកសាសន៍នេះមានប្រសិទ្ធភាព[៥០]។

ខាងក្រោមនេះ គឺការសិក្សាទៅលើចរិតលក្ខណៈនៃរបបសន្តតិកម្មករណីកម្ពុជា-ជប៉ុន ដែលនឹងបកស្រាយនៅក្នុងផ្នែកទី២។

## ផ្នែកទី២៖ ចរិតលក្ខណៈនៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន

របបសន្តតិកម្មនៃប្រទេសកម្ពុជា និង ជប៉ុនមានចរិតលក្ខណៈចាប់បង្ខំផង និង មានលក្ខណៈអនុវត្តតាមឆន្ទៈរបស់បុគ្គលឯកជនផង។ ករណីដែលថា របបសន្តតិកម្មមានលក្ខណៈចាប់បង្ខំនោះ គឺដោយហេតុថា សន្តតិជន ឬទាយាទ របស់មតកជនមិនអាចធ្វើទៅតាមការទាមទារ ឬ កែតម្រូវលំដាប់នៃសន្តតិកម្មដែលច្បាប់បានកំណត់នោះទេ។ ម្យ៉ាងវិញទៀត ចំណែកមតិកដែលសន្តតិជននៅក្នុងលំដាប់នីមួយៗត្រូវទទួលបាននោះ ក៏មិនអាចធ្វើការតវ៉ាបាននោះទេ ពោលគឺច្បាប់បានកំណត់យ៉ាងណាត្រូវអនុវត្តតាមដាច់ខាត។ដោយឡែក របបសន្តតិកម្មមានចរិតលក្ខណៈអនុវត្តតាមឆន្ទៈរបស់បុគ្គលនោះ គឺដោយហេតុថា ទោះបីជាសន្តតិជនមិនអាចធ្វើការតវ៉ាអំពី ចំណែកមតិកបានក៏ពិតមែន ប៉ុន្តែ ច្បាប់ទទួលស្គាល់ថាសន្តតិជនមានសិទ្ធិធ្វើការទាមទារភាគនៃវិភាគទាន ដែលខ្លួនបានចូលរួមដើម្បីទំនុកបម្រុងចំពោះមតកជន ក៏ដូចជាបានចូលរួមបង្កើន ឬរក្សាទ្រព្យសម្បត្តិរបស់មតកជន [៥១] ។ លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណី ក៏បានអនុញ្ញាតិឲ្យសន្តតិជនធ្វើការ

[៥០] អ៊ីតូហ្គីហ៊ិកុ, *នីតិរដ្ឋប្បវេណី ភាគទី៤ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី៣, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ២០១១), ទំព័រទី១២២។ 伊藤義彦『 民法 4 親族・相続』第 3 版 （有斐閣、2011 年）、122 頁。

[៥១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៦។

សម្រេចចិត្ត បោះបង់សន្តតិកម្ម[៥២] ឬយល់ព្រមទទួលដោយផ្នែក[៥៣] ឬទាំងស្រុង[៥៤] គឺក្នុងគោលបំណង ដើម្បីការពារជីវភាពរបស់សន្តតិជននោះ កុំឲ្យជួបការក្ស័យធន ដោយសារការទទួលយកការអនុវត្ត កាតព្វកិច្ចបន្តពីមតកជនច្រើនលើសលប់ពេក ពីព្រោះយើងដឹងហើយថា ការទទួលស្នងបន្តនូវទ្រព្យ សម្បត្តិរបស់ មតកជន គឺមិនត្រឹមតែទ្រព្យសកម្មប៉ុណ្ណោះទេ តែថែមទាំង ទ្រព្យអកម្មរបស់មតកជន ដែលបន្សល់ទុកពេលដែលទទួលមរណភាពផងដែរ។

ក្រោយពីបានយល់ដឹងអំពី ចរិតលក្ខណៈនៃរបបសន្តតិកម្មរបស់កម្ពុជា និងជប៉ុន រួចយើង នឹងធ្វើការសិក្សាបន្ថែមទៅលើ ផលប្រយោជន៍នៃរបបសន្តតិកម្ម របស់កម្ពុជា និង ជប៉ុន (កថាខណ្ឌ ទី១) ដូចខាងក្រោមនេះ៖

## ១. ផលប្រយោជន៍នៃរបបសន្តតិកម្ម កម្ពុជា-ជប៉ុន

ផលប្រយោជន៍នៃរបបសន្តតិកម្ម ត្រង់កន្លែងនេះ គឺសំដៅទៅលើ ផលប្រយោជន៍សម្រាប់ ឯកជន ដែលធ្វើការបកស្រាយនៅក្នុង ចំណុចទី១.១ និង ផលប្រយោជន៍សម្រាប់សាធារណៈ គឺត្រូវ បានបកស្រាយនៅក្នុង ចំណុចទី១.២ ដូចខាងក្រោមនេះ ដោយផ្តោតទៅលើ ករណីកម្ពុជា និង ជប៉ុន។

### ១.១. ផលប្រយោជន៍ឯកជននៃរបបសន្តតិកម្ម

ចរិកលក្ខណៈនៃសន្តតិកម្ម ទាំងកម្ពុជា និង ជប៉ុន គឺត្រូវបានធ្វើឡើងដើម្បីធានា និងគោរព លើកទឹកចិត្ត ព្រមទាំង ការពារផលប្រយោជន៍របស់បុគ្គលឯកជនឲ្យស្របទៅនឹងផលប្រយោជន៍ សាធារណៈ។ បានសេចក្តីថាចរិកលក្ខណៈរបស់សន្តតិកម្មគឺដើម្បីការពារផលប្រយោជន៍ស្របច្បាប់ របស់មតកជននូវទ្រព្យសម្បត្តិទាំងឡាយដើម្បីកុំប្រាស់ចាកនឹងឆន្ទៈរបស់ខ្លួន។ កម្មសិទ្ធិដែលត្រូវ ផ្ទេរគឺជា កម្មសិទ្ធិរបស់មតកជន ដូច្នេះច្បាប់ត្រូវការពារកុំឲ្យធ្លាក់ទៅលើដៃអ្នកផ្សេង។ រាល់ការផ្ទេរ ទាំងអស់ គឺត្រូវតែស្របនឹងទម្រង់មតកសាសន៍ (ករណីមតកជនបានធ្វើការបង្ហាញឆន្ទៈក្នុងការបែង ចែកទ្រព្យសម្បត្តិរបស់គាត់) និងត្រូវស្របទៅតាមបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន (ករណី មិនមានការបង្ហាញឆន្ទៈតាមរយៈមតកសាសន៍) ជាដើម ដោយមិនអនុញ្ញាតិឲ្យមានការផ្ទុយទៅនឹង

[៥២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦០។
[៥៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៦។
[៥៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៥៤។

ប្រយោជន៍សាធារណៈឡើយ ប៉ុន្តែក្នុងករណីដែលមានភាពផ្ទុយនឹងប្រយោជន៍សាធារណៈដោយប្រការណាមួយនោះ គឺត្រូវបដិសេធចោល។

## ១.២. ផលប្រយោជន៍សាធារណៈនៃរបបសន្តតិកម្ម

ក្រោយពីបានសិក្សាទាក់ទងទៅនឹង ផលប្រយោជន៍ឯកជននៃរបបសន្តតិកម្មរួចមក យើងនឹងសិក្សាបន្ថែមទៅលើផលប្រយោជន៍សាធារណៈដែលបានមកពីរបបសន្តតិកម្ម។ យើងបានដឹងហើយថា អ្វីទាំងអស់ដែលមតកជនខិតខំរកមកដើម្បីជាប្រយោជន៍របស់គ្រួសារគាត់ បើសិនជាគាត់រកមកដើម្បី លក់ ឬក៏ ឲ្យទៅគេ គឺមិនចាំបាច់រកមកនោះទេ ដែលជាហេតុនាំឲ្យច្បាប់ស្តីពីសន្តតិកម្មប្រទេសកម្ពុជាយើងផ្តល់សិទ្ធិទៅឲ្យទាយាទរបស់មតកជន ត្រូវក្លាយជា សន្តតិជនបន្តកេរមតិកទាំងនោះ។ ដោយឡែក ដោយសារសម័យកាលចេះតែវិវត្តទៅមុខ ការគិតរបស់មនុស្សក៏មានភាពទូលំទូលាយជាងមុន ដោយពួកគាត់ បានចែករំលែកនូវចិត្តគំនិតរបស់ពួកគាត់ចំពោះផលប្រយោជន៍សាធារណៈផងដែរ។ ក្នុងន័យនេះគឺអ្នកដែលទ្រព្យសម្បត្តិច្រើន មួយចំនួនបានលះបង់ទ្រព្យសម្បត្តិជាច្រើនដើម្បីជាប្រយោជន៍សាធារណៈ ប្រយោជន៍សង្គមកិច្ចជាដើម ដោយជួយស្តារ និងអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងករណីនេះ ទើបក្នុងច្បាប់កម្ពុជាពុំមានបញ្ញត្តិរាំងចំពោះការផ្ទេរទ្រព្យសម្បត្តិរបស់មតកជនដើម្បីផលប្រយោជន៍សាធារណៈឡើយ។

ក្រោយពីបានយល់ដឹងពី ផលប្រយោជន៍នៃរបបសន្តតិកម្ម នៃប្រទេសកម្ពុជា និងជប៉ុន រួចហើយ យើងនឹងសិក្សាបន្តទៅលើចំណុចទី២ខាងក្រោមនេះ ដែលនឹងសិក្សាទៅលើ អត្ថិភាព និងនត្ថិភាពនៃសិទ្ធិជាសន្តតិជន ករណី កម្ពុជា និង ជប៉ុន។

## ២. អត្ថិភាព និង នត្ថិភាពនៃសិទ្ធិជាសន្តតិជន

អត្ថិភាព[៥៥]នៃសិទ្ធិជាសន្តតិជនក្នុងន័យនេះ គឺចង់សំដៅទៅលើបុគ្គលណាខ្លះដែលមានសិទ្ធិក្នុងការទទួលបន្តនូវមតិកតាមរយៈរបបសន្តតិកម្ម។ ចំណែកនត្ថិភាពនៃសិទ្ធិជាសន្តតិជនវិញ គឺចង់សំដៅទៅលើបុគ្គល ក្រៅពីបុគ្គលដែលមានអត្ថិភាពនៃសិទ្ធិជាសន្តតិកម្ម មានន័យថា គឺជាបុគ្គលដែលមិនមានលក្ខណៈសម្បត្តិត្រឹមត្រូវតាមច្បាប់ ក្នុងការទទួលស្នងនូវមតិក តាមរយៈសន្តតិកម្ម។

តើបុគ្គលណាខ្លះ ដែលអាចទទួលបាននូវ អត្ថិភាពនៃសិទ្ធិជាសន្តតិជន? ផ្ទុយទៅវិញ តើបុគ្គលណាខ្លះទៀត ដែលមិនអាចទទួលបាននូវសិទ្ធិជាសន្តតិជន? ដើម្បីឲ្យកាន់តែច្បាស់ យើងនឹង

[៥៥] សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ, *សន្ធានុក្រម ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០*, ទំព័រ១៩, អត្ថិភាព. ភាពដែលមាន។ ឧ. អត្ថិភាព នៃព្រះអាទិទេព។ ឧ. អស់អត្ថិភាព គឺអស់ជីវិត។

ធ្វើការបកស្រាយ អំពីអត្ថិភាពនៃសិទ្ធិជាសន្តតិជន (២.១) និង នត្ថិភាពនៃសិទ្ធិជាសន្តតិជន (២.២) ដោយ យើងនឹងធ្វើការសិក្សាទៅលើ ករណីប្រទេសកម្ពុជា និងករណីប្រទេសជប៉ុន។

### ២.១. អត្ថិភាពនៃសិទ្ធិជាសន្តតិជន

រាល់បុគ្គលដែលមានសិទ្ធិក្នុងការទទួលយកសន្តតិកម្ម ទាល់តែបុគ្គលនោះបំពេញលក្ខខណ្ឌមួយចំនួន ដែលលក្ខខណ្ឌនោះផ្តោតជាសំខាន់ទៅលើអត្ថិភាព។ ដើម្បីក្លាយជាសន្តតិជន ជននោះត្រូវតែមានអត្ថិភាព មានន័យថាមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម [៥៦]។ ក្នុងករណីនេះ បុគ្គលនោះអាចទទួលសន្តតិកម្មបាន។ ការតម្រូវឲ្យមានអត្ថិភាព គឺជីវិតរស់នៅនេះវាពាក់ព័ន្ធទៅនឹងបុគ្គលភាពគតិយុត្ត ព្រមទាំងគោលការណ៍នៃបេតិកភណ្ឌ ពោលគឺមានតែបុគ្គលទេដែលអាចមានបេតិកភណ្ឌ ហេតុនេះចាំបាច់ឲ្យបុគ្គលនោះត្រូវមានជីវិតរស់នៅ។

ក្នុងក្របខ័ណ្ឌនេះ រូបវន្តបុគ្គល [៥៧]ម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះនៅពេលទទួលមរណភាព[៥៨]។

ថ្វីបើក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ច្បាស់លាស់អំពីការតម្រូវឲ្យសន្តតិជន ជាជនដែលមានជីវិតរស់នៅ ក៏ប៉ុន្តែមានបញ្ហាប្រឈមមួយចំនួន ដែលនឹងចោទឡើងពាក់ព័ន្ធការទទួលស្គាល់នៃការចាប់ផ្តើម និងការបញ្ចប់ជីវិតផងដែរ។

តាមគោលការណ៍ខាងលើ ដើម្បីទទួលបានសមត្ថភាពពេញលេញជារូបវន្តបុគ្គល លុះត្រាតែទារកនោះ កើតមក មានជីវិត ហើយអាចរស់បាន។ ប៉ុន្តែទារកនៅក្នុងគភ៌ ក៏អាចក្លាយជាសន្តតិជនបានដែរ។ ករណីនេះអនុញ្ញាតិឲ្យទារក ដែលមានកំណើតនៅពេលក្រោយ អាចទទួល

---

[៥៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៩ បានបញ្ញត្តថា

១. មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិកម្ម ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន។

២. ទោះមានបញ្ញត្តដូចកថាខណ្ឌទី១ ខាងលើនេះក៏ដោយបញ្ញត្តិនៃកថាខណ្ឌទី២ និងទី៣ នៃមាត្រា៩ (ទារកក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះទារកដែលនៅក្នុងគភ៌។

[៥៧] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ១២៧. មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។

[៥៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៨។

មត៌កដោយសន្តតិកម្មនោះបាន[៥៩]។ តាមខ្លឹមសារនៃមាត្រា ៩ និង មាត្រា១១៤៩ នៃក្រមរដ្ឋប្បវេណី ទារក ដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន។ ដោយឡែក ចំពោះការទទួលស្គាល់នៃការស្លាប់ ឬ មរណភាព ក៏ជាបញ្ហាដែលគួរតែពិចារណាផងដែរក្នុងករណីដែលបុគ្គលអវត្តមាន (មាត្រា ៣៧ និង មាត្រាបន្តបន្ទាប់ទៀតនៃក្រមរដ្ឋប្បវេណី) ដូចជាករណីដែលបុគ្គលដែលនឹងត្រូវក្លាយជាសន្តតិជន ត្រូវបានទទួលការប្រកាសអំពីការបាត់ខ្លួន នោះបុគ្គលនោះនឹងត្រូវចាត់ទុកថាបានស្លាប់[៦០]។ ដូចនេះ ទើបការប្រើប្រាស់យន្តការសន្តតិកម្មជំនួសអាចសមស្របទៅនឹង ករណីការប្រកាសអំពីការបាត់ខ្លួន ពីព្រោះបុគ្គលនោះត្រូវបានចាត់ទុកថាបានស្លាប់។

ក្នុងករណីប្រទេសជប៉ុនវិញ បានកំណត់ថា សន្តតិជនគឺជាអ្នកដែលទទួលបន្ត ឬស្នងសិទ្ធិ និងករណីយកិច្ចរបស់មតកជន តាមច្បាប់ ឬតាមឆន្ទៈ ដោយបុគ្គលដែលអាចក្លាយជាសន្តតិជន (ជនដែលត្រូវបានសន្មតថាជាសន្តតិជន)[៦១]។ ដោយឡែក តើបុគ្គលណាខ្លះដែលនឹងត្រូចបានសន្មត ថាជាសន្តតិជននោះ យើងនឹងធ្វើការសិក្សាដូចតទៅនេះ៖

ទោះបីជាបុគ្គលណាម្នាក់ត្រូវបានគេសន្មតជាសន្តតិជនក៏ដោយ ក៏បុគ្គលនោះ ត្រូវគោរពនូវ លក្ខខណ្ឌមួយចំនួនដែរ។ ចំពោះលក្ខខណ្ឌទាំងនោះ នៅប្រទេសជប៉ុន ក៏មិនខុសពីលក្ខខណ្ឌ ដូចដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាប៉ុន្មានដែរ ដូចជាមានជីវិតរស់នៅ នាពេលចាប់ ផ្តើម សន្តតិកម្ម មិនមែនជាអភ័ព្វបុគ្គល និងមិនមែនជាជនដែលត្រូវបានផ្តាច់មត៌កជាអាទិ៍។ ពោល គឺ សន្តតិកម្មអាចត្រូវធ្វើឡើងបានតែចំពោះបុគ្គល ដែលមានជីវិតរស់នៅ នៅពេលដែលចាប់ផ្តើម សន្តតិកម្មតែប៉ុណ្ណោះ[៦២]។ ដូចនេះ ក្នុងករណីដែលមតកជន និងជនដែលត្រូវសន្មតថាជា សន្តតិជន បានទទួលមរណភាពព្រមគ្នា ឬក្នុងករណីដែលត្រូវសន្មតថា បានទទួលមរណភាព (ឧទាហរណ៍ ៖ ការប្រកាសការបាត់ខ្លួន[៦៣]) ព្រមគ្នា នោះទោះបីជាជននោះត្រូវបានសន្មតថាជា សន្តតិជនហើយក៏

---

[៥៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩។

[៦០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៣។

[៦១] អ៊ីតូហ្គីហ៊ិកុ, *នីតិរដ្ឋប្បវេណី ភាគទី៤ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី៣, (រោងពុម្ព យ៉ឺហិកាគឺ, ឆ្នាំ២០១១), ទំព័រទី១២៩។ 伊藤義彦『民法 4 親族・相続』第 3 版 （有斐閣、2011 年）、129 頁。

[៦២] តាកាហាស៊ីតូម្ញកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យ៉ឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២២៩។ 高橋朋子『民法 7 親族・相続』第 2 版 （有斐閣、2009 年）、229 頁。

[៦៣] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៣០ កថាខណ្ឌ២ និងមាត្រា៣១។

ដោយ ប៉ុន្តែ ដោយសារតែជននោះមិនបានបំពេញលក្ខខណ្ឌមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្ម ដូច្នេះមិនអាចធ្វើសន្តតិកម្មបានឡើយ[៦៤]។

ខាងក្រោមនេះយើងនឹងធ្វើការសិក្សាបន្តទាក់ទងទៅនឹងនត្ថិភាពនៃសិទ្ធិជាសន្តតិជន (២.២) ដូចតទៅ៖

## ២.២. នត្ថិភាពនៃសិទ្ធិជាសន្តតិជន

យើងបានដឹងរួចហើយអំពី ជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយជាសន្តតិជនបានលុះត្រាតែ បុគ្គលនោះមានជីវិតរស់នៅ ហើយមានវត្តមាននៅពេលចាប់ផ្តើមសន្តតិកម្ម។ ដោយឡែកយើងពុំទាន់បានដឹងនៅឡើយទេ ថាតើបុគ្គលណាខ្លះដែលបាត់បង់សិទ្ធិក្នុងការក្លាយជាសន្តតិជន ដើម្បីមករួមចែកចំណែកមតិករបស់មតកជន។ នៅក្នុងនោះដែរ យើងដឹងថា មាន អភ័ព្វបុគ្គល (២.២.១) ជនដែលត្រូវបានផ្តាច់ចេញពីមតិក (២.២.២) និងករណីពិសេស គឺករណីសន្តតិជនជាជនបរទេស (២.២.៣) ។ ដូចនេះ យើងនឹងធ្វើការសិក្សាលម្អិតទៅលើបុគ្គលនីមួយៗ ថាតើពួកគេជាបុគ្គល ដែលមានលក្ខណៈសម្បត្តិដូចម្តេច ដោយយើងនឹងធ្វើការសិក្សាទៅលើ ករណីប្រទេសកម្ពុជា និងករណីប្រទេសជប៉ុន។

### ២.២.១. អភ័ព្វបុគ្គល

អភ័ព្វបុគ្គល [៦៥] ជាជនដែលបាត់បង់សិទ្ធិក្នុងការទទួលសន្តតិកម្មរបស់ជនដែលខ្លួនបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរដាក់មតកជន ឬអាចនិយាយបានម៉្យាងទៀតថាជាបុគ្គលដែលមិនអាចទទួលលក្ខណៈសម្បត្តិជាសន្តតិជន តាមរយៈការដកហូតសិទ្ធិ ដោយសារតែទង្វើខុសច្បាប់របស់បុគ្គលនោះ បើទោះបីជា បុគ្គលនោះជារូបវន្តបុគ្គលដែលនៅរស់ក៏ដោយ។ តាមន័យនេះ បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ[៦៦]៖

[៦៤] តាកាហាស៊ីតូម្ញកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី២៣០។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、230 頁。

[៦៥] ទីស្តីការគណៈរដ្ឋមន្ត្រី, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ១៩០. បុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន។

[៦៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥០។

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬដោយប្រយោល ក្តី។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង លើកលែងករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើលុបចោល ឬ បានកែប្រែនូវមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គម្រាមកំហែង។

ឃ-បុគ្គលដែលបានឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ បានលាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។

នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ក៏បានបញ្ញត្តទាក់ទងទៅនឹង អភ័ព្វបុគ្គលដែរ។ ជនដែលត្រូវបានចាត់ទុកជា អភ័ព្វបុគ្គលក្នុងក្រមជប៉ុន គឺសំដៅទៅលើជនទាំងឡាយណាដែលគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយសារតែបាន ប្រព្រឹត្តិនូវអំពើចម្បងៗទាំងពីខាងក្រោមនេះ[៦៧]៖

ក-ជនដែលបានធ្វើឃាត មតកជន សន្តតិជនលំដាប់មុន និងសន្តតិជនលំដាប់ស្មើគ្នា[៦៨]។

ខ-ជនដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន[៦៩]។

លើសពីនេះរាល់ការប្រព្រឹត្តិនូវអំពើដូចខាងលើនេះ គឺមិនគិតទៅលើ កំហុស ឬចេតនានោះទេ គឺថាឲ្យតែមានអំពើទាំងនោះបានកើតឡើង នោះបុគ្គលដែលបានធ្វើវា ដោយប្រយោលក្តី ឬ ដោយផ្ទាល់ក្តី នឹងត្រូវចាត់ទុកជាអភ័ព្វបុគ្គល ហើយពុំមានសិទ្ធិមកទទួលយកចំណែកមតិករបស់

[៦៧]ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩១។

[៦៨] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩១, ចំណុចទី១ ទី២។

[៦៩] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩១,ចំណុចទី៣ ដល់ទី៥។

មតកជនបានទេ។ យ៉ាងណាមិញ ចំពោះសកម្មភាពខុសច្បាប់ខាងលើនេះ បានកើតឡើងក្រោយពេលបើកសន្តតិកម្មនោះ (ឧទាហរណ៍៖ ការលាក់ទុកនូវលិខិតមតកសាសន៍) ក៏ដោយជនដែលបានប្រព្រឹត្តិអំពើនោះ ត្រូវបានសន្មតថាមិនមែនជា សន្តតិជនតាំងពីដំបូង ដូចនេះសិទ្ធិក្នុងសន្តតិកម្មទាំងអស់របស់ជននោះ នឹងត្រូវមោឃភាពចោល[៣០]។

## ២.២.២. ជនដែលត្រូវផ្តាច់ចេញពីមត៌ក

នៅក្នុងសង្គមមនុស្សកាតព្វកិច្ចដឹងគុណ កតញ្ញូតាធម៌ គឺជាកិច្ចការដែលមនុស្សគ្រប់រូបត្រូវប្រព្រឹត្តិ និងប្រតិបត្តិតាមដូចជាធម៌សម្រាប់មនុស្សជាតិមួយ។ ក្នុងករណីនេះ បុគ្គលដែលរមិលគុណដែលមិនមានធម៌កតញ្ញូនេះ អាចត្រូវបានកាត់កាល់ផ្តាច់ពីមត៌កដោយហេតុថា មតកជនបានសំដែងឆន្ទៈដោយផ្ទាល់តែម្តង ហើយការសំដែងឆន្ទៈនេះមានអានុភាពទៅបានទាល់តែមានការសម្រេចពីតុលាការ[៣១]។

ការសម្តែងឆន្ទៈរបស់មតកជននេះ អាចធ្វើឡើងតាមរយៈការដាក់ពាក្យប្តឹងដោយផ្ទាល់ទៅតុលាការ ឬតាមរយៈមតកសាសន៍៖

ក-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឲ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះមិនឲ្យទទួលសន្តតិកម្មបាន[៣២]។

ខ-ដោយឡែក មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមរយៈមតកសាសន៍បានដែរ។ ក្នុងករណីនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវនៅក្រោយពេលដែលមតកសាសន៍នោះ បានបង្កើតអានុភាព។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព[៣៣]។

សរុបមក ការសម្រេចផ្តាច់មត៌កពីបុគ្គលណាម្នាក់ អាចត្រូវធ្វើបានទាល់តែមតកជនមានមូលហេតុ និងមូលដ្ឋានច្បាស់លាស់តាមច្បាប់កំណត់ ដោយហេតុថាបុគ្គលដែលត្រូវបានផ្តាច់មត៌ក

---

[៣០] អ៊ីតូហ្គីហ៊ិកុ, *នីតិរដ្ឋប្បវេណី ភាគទី៤ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី៣, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ២០១១), ទំព័រ១២៩។ 伊藤義彦『 民法 4 親族・相続』第 3 版 （有斐閣、2011 年）、129 頁。

[៣១] ជ័យ រិទ្ធី, *លក្ខខណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់*(ភ្នំពេញ៖ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៥), ទំព័រ ៩។

[៣២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥១, កថាខណ្ឌ ១។

[៣៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥២។

អាចធ្វើការតវ៉ានឹងការផ្ដាច់នេះបាន ក្នុងករណីការផ្ដាច់មត៌កមិនមានមូលហេតុត្រឹមត្រូវ[៧៤]។ តាមន័យនេះ នៅពេលប្ដឹងទៅតុលាការដោយមតកជនកាលនៅរស់ ឬ ការកំណត់ពីការផ្ដាច់មត៌កតាមរយៈលិខិតបណ្ដាំ ត្រូវបញ្ជាក់ពីមូលហេតុនោះ។ អនុលោមតាមបញ្ញត្តិមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី មតកជនអាចផ្ដាច់មត៌កបាន បើជនដែលត្រូវបានសន្មតថា ជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តិនូវសកម្មភាពដែលបានកំណត់ដូចខាងក្រោមនេះ៖

ក-បើបានធ្វើបាបចំពោះមតកជន

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្ដែមិនមកថែទាំ

ឃ-បើត្រូវបានទទួលសាលក្រម ឬសាលដីកាផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់ ជាអាទិ៍។

ដូចនេះ ប្រសិនបើ អភ័ព្វបុគ្គលនៃសន្តតិកម្ម ឬបុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន ឬ បុគ្គលដែលត្រូវបានផ្ដាច់ពីសន្តតិកម្ម ឬខាងលើនេះ កំពុងកាន់កាប់មត៌កបុគ្គលនោះត្រូវបានចាត់ថាជាអ្នកកាន់កាប់ទុច្ចរិត គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម[៧៥]។

លើសពីនេះ នៅប្រទេសជប៉ុនក៏ដូចគ្នា ការផ្ដាច់មត៌កចេញពីបុគ្គលណាម្នាក់គឺត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈរបស់មតកជន ពេលគាត់នៅមានជីវិត។ ពោលគឺ ជនដែលត្រូវបានផ្ដាច់ចេញពីមត៌ក គឺជាជនដែលត្រូវបានគេដកហូតសិទ្ធិចេញពីសន្តតិកម្ម តាមរយៈឆន្ទៈរបស់មតកជន[៧៦]។ បើយោងតាម ការនិយមធ្វើសន្តតិកម្មតាមមតកសាសន៍នៃច្បាប់រ៉ូម៉ាំង （ローマ法の遺言相続主義） វិញ ប្រសិនបើគ្មានការបង្ហាញឆន្ទៈតាមមតកសាសន៍ ថាបុគ្គលណាមួយត្រូវបានផ្ដាច់ចេញពីមត៌កនោះទេ ការផ្ដាច់មត៌កណាម្នាក់នឹងមិនកើតឡើងឡើយ[៧៧]។ ចំណែកឯ ក្រមរដ្ឋប្បវេណីរបស់ជប៉ុន

[៧៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥១, កថាខណ្ឌ ២ បានបញ្ញត្តថា ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារការផ្ដាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការផ្ដាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្ដីដែកបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ។

[៧៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៣។

[៧៦] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩៣។

[៧៧] អ៊ីតូហ្គីហ៊ិកុ, *នីតិរដ្ឋប្បវេណី ភាគទី៤ ស្ដីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី៣, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ២០១១), ទំព័រ១៣០។ 伊藤義彦『 民法 4 親族・相続』第 3 版 （有斐閣、2011 年）、130 頁。

វិញ ក៏បានបញ្ញត្តផងដែរថា ការផ្តាច់បុគ្គលណាម្នាក់ចេញពីសន្តតិកម្ម ត្រូវតែមានការបង្ហាញឆន្ទៈរបស់មតកជន នឹងត្រូវរង់ចាំការសម្រេចសេចក្តីពីតុលាការផងដែរ[៧៨]។

### ២.២.៣. ករណីសន្តតិជនជាជនបរទេស

យោងតាមមាត្រា៦នៃក្រមរដ្ឋប្បវេណី រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។ ចំពោះករណីសិទ្ធិជនបរទេស[៧៩]វិញ មាត្រា៧ បានកំណត់ថា ជនបរទេសមិនអាចទទួលបាននូវសិទ្ធកាន់កាប់មួយចំនួន ដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ។ ក្នុងបរិបទនៃរបបសន្តតិកម្ម ច្បាប់របស់ប្រទេសកម្ពុជាបានហាមប្រាមមិនឲ្យសន្តតិជនជាជនជាតិបរទេស ទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ[៨០]។ ក្នុងន័យនេះ គឺសន្តតិជនដែលពុំមានសញ្ជាតិខ្មែរ មិនអាចទទួលសន្តតិកម្មជាដីធ្លីបានឡើយ បើសន្តតិជនទាំងអស់ពុំមានសញ្ជាតិខ្មែរនោះទេ ដីធ្លីដែលជាចំណែកនៃមតិក ត្រូវក្លាយជានីតិបុគ្គលមតិក[៨១] ដោយសន្តតិជនទាំងនោះ អាចលក់ដីធ្លីក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមតិក ក្នុងអំឡុងពេល ៣ខែ គិតចាប់ពីថ្ងៃដែលសន្តតិជនទាំងនោះយល់ព្រមទាំងស្រុង ឬ មានកម្រិត ហើយថ្លៃលក់ដីធ្លីនោះ នឹងក្លាយជាមតិក នាំឲ្យនីតិបុគ្គលមតិកត្រូវរលត់។ បើមិនបានចាត់ចែងដីធ្លីនោះ នៅក្នុងអំឡុងពេល៣ខែ នោះទេ កម្មសិទ្ធិដីធ្លីនោះត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្តបន្ទាប់ ដែលមានសញ្ជាតិខ្មែរ ហើយនីតិបុគ្គលមតិកត្រូវបានចាត់ទុកថាគ្មានអត្ថិភាព[៨២]។ ហើយបើសន្តតិជនលំដាប់បន្ទាប់គ្មានសញ្ជាតិខ្មែរនោះទេ នាំឲ្យ

---

[៧៨] ក្រមរដ្ឋប្បវេណីជប៉ុន, ១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩៣។

[៧៩] ច្បាប់ស្តីពីអន្តោប្រវេសន៍, ១៩៩៤, មាត្រា២ បានចាត់ទុកជនបរទេសជនណាដែលគ្មានសញ្ជាតិខ្មែរ ដោយគ្មានរើសអើង ទោះបីជនទោះមានសញ្ជាតិ ជំនឿ សាសនា ឬ ដើមកំណើតណាក៏ដោយ។

[៨០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៥, កថាខណ្ឌ ១ បានបញ្ញត្តថា បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ។

[៨១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៩០ បានបញ្ញត្តថា ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មតិកនោះត្រូវក្លាយជា នីតិបុគ្គលមតិក។

[៨២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៥។

នត្ថិភាពនៃសន្តតិជន ដែលធ្វើឲ្យដីធ្លីនោះ ក្លាយជាដីធ្លីគ្មានម្ចាស់ និងចុងក្រោយធ្លាក់ជាទ្រព្យសម្បត្តិរដ្ឋ[៨៣]។

ដោយឡែក ចំពោះករណីសន្តតិជនជាជនបរទេសនេះ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ពុំមានបញ្ញត្តិណាបានចែងលម្អិតទេ។

[៨៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៣០០ បានបញ្ញតថា មត៌កដែលមិនបានចាត់ចែង តាមបញ្ញត្តិមាត្រា១២៩៩ ខាងលើត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ។

# ជំពូកទី២

# ការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជា-ជប៉ុន

នៅពេលមតកជនបានទទួលមរណភាព[៤៤] ឬបានទទួលការប្រកាសអំពីការបាត់ខ្លួន[៤៥] នោះ សន្តតិកម្មនឹងត្រូវចាប់ផ្តើមឡើង ពោលគឺច្បាប់មិនទទួលស្គាល់សន្តតិកម្ម ពេលដែលមតកជននៅរស់រានមានជីវិតនៅឡើយនោះទេ។ នៅក្នុងវិស័យសន្តតិកម្ម ចំពោះគោលដៅនៃការការពារចំពោះសហព័ទ្ធដែលនៅរស់ គឺសំដៅទៅរកសហព័ទ្ធជាស្ត្រី ព្រោះមានហេតុផលមួយចំនួនដែលអាចឲ្យគេយល់បានថា ទៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ ភាគច្រើនណាស់ដែលបុរសជាប្តីទទួលមរណភាពមុនប្រពន្ធរបស់ខ្លួន។ មូលហេតុទាំងនោះមានដូចជា ៖ (ទី១) ក្នុងទំនៀមទម្លាប់របស់កម្ពុជាតាំងពីសម័យដើមមក ភាគច្រើនបំផុតដែលស្ត្រីតែងតែរៀបការជាមួយបុរស ដែលមានអាយុច្រើនជាងខ្លួន។ ទំនៀមទម្លាប់នៃការអនុវត្តនេះ អាចឲ្យគេយល់បានតាមរយៈ "ច្បាប់ក្រមង៉ុយ" របស់ព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ដែលក្នុងនោះមានឃ្លាមួយចំនួនបានសរសេរថា *"កុំយកប្តីប្អូន ថោកពាសីខ្លួន រកស៊ីមិនធូរ គេហៅថាឯង សមហៅគេពូ ច្រើនខ្ជិលមូទូ ម៉េះម៉ស់នឹងល្បែង វាច្រើនមើលងាយ ហៅស្តីនិយាយ ហៅហាងហៅឯង ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង ឯងមើលងាយជេរ"*[៤៦]។ ម្យ៉ាងវិញទៀត ក្នុងសម័យបច្ចុប្បន្ន ទំនៀមទម្លាប់នេះហាក់នៅតែមានការអនុវត្តជាបន្តបន្ទាប់។ បើគេពិនិត្យមើលនៅក្នុងលទ្ធផលជំរឿនឆ្នាំ១៩៩៨ បានឲ្យដឹងថា អាយុមធ្យមនៅពេលរៀបការរបស់បុរស ស្មើនឹង២៤,២ ហើយអាយុរៀបការរបស់ស្ត្រី ស្មើនឹង២២,៥។ រីឯ ក្នុងលទ្ធផលជំរឿនក្នុងឆ្នាំ២០០៨ វិញ អាយុមធ្យមនៅពេលរៀបការរបស់បុរស ស្មើនឹង២៥,៦ ហើយអាយុរៀបការរបស់ស្ត្រីស្មើនឹង ២៣,៣[៤៧]ដែលនេះបង្ហាញឲ្យឃើញថា រហូតមកដល់បច្ចុប្បន្ននេះ អាយុមធ្យមនៅពេលរៀបការរបស់បុរស និង ស្ត្រីនៅតែមានភាពមិនស្មើគ្នា។ (ទី២) មូលហេតុដែលធ្វើឲ្យសហព័ទ្ធជាបុរសស្លាប់មុនស្ត្រី ព្រោះកត្តាអាយុជាមធ្យមរវាងបុរស និងស្ត្រីមានភាពមិនស្មើគ្នា។ ហេតុនេះ នៅពេលដែលស្ត្រីរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរស ដែលមានអាយុច្រើនជាងខ្លួនស្រាប់ នោះកត្តាដែលបុរសដែលមានអាយុច្រើនជាងខ្លួនស្រាប់នោះ ជាហេតុដែលបុរសទទួលមរណភាពមុនប្រពន្ធមាន

---

[៤៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៥។

[៤៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤៣។

[៤៦] ពុទ្ធសាសនបណ្ឌិត្យ, *ច្បាប់ក្រមង៉ុយ*(ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ២០០៥), ១៨។

[៤៧]វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ, ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ (ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ, ២០០៩), ៦០។

លទ្ធភាពកាន់តែខ្ពស់។ (ទី៣) មូលហេតុចុងក្រោយនោះគឺ កត្តាសុខភាពរបស់បុរស ដែលងាយប្រឈមនឹងជម្ងឺជាងស្ត្រី។ នៅក្នុងបណ្ដាប្រទេសជាច្រើនលើពិភពលោក ដែលក្នុងនោះរួមមានទាំងប្រទេសកម្ពុជាផងនោះ ជាទូទៅ បុគ្គលជាបុរសតែងតែចូលចិត្តការជួបជុំ ទទួលទានគ្រឿងស្រវឹង ជក់បារី ជាដើមដែលសុទ្ធសឹងតែជាទង្វើនាំឲ្យប៉ះពាល់ដល់សុខភាព បង្កនូវជម្ងឺ ដែលជាហេតុធ្វើឲ្យសុខភាពរបស់បុរសធ្លាប់ចុះទ្រុឌទ្រោម និង ងាយប្រឈមនឹងការស្លាប់ក្នុងអត្រាខ្ពស់ជាងស្ត្រី។ ហេតុនេះ ក្នុងករណីដែលសហព័ទ្ធជាស្ត្រីនៅរស់តែម្នាក់ឯង នោះបន្ទុកដ៏ធ្ងន់នៅក្នុងគ្រួសារនឹងធ្លាក់ទៅលើសហព័ទ្ធរូបនោះ ដែលត្រូវទាមទារ ឲ្យមានការយកចិត្តទុកដាក់ពីសំណាក់ច្បាប់។

ដោយសារតែមូលហេតុខាងលើ តើការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធ ក្នុងរបបសន្តតិកម្មកម្ពុជា (ផ្នែកទី១) មានការប្រែប្រួលទៅជាយ៉ាងណាខ្លះ ប្រសិនបើប្រៀបធៀបទៅនឹងក្រមមតិកចាស់ ក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ជាមួយនឹងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧។ ដោយឡែក តើក្រមរដ្ឋប្បវេណីរបស់ជប៉ុន មានការកែក្រៃយ៉ាងណាដែរ ដើម្បីឲ្យការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម ជប៉ុន (ផ្នែកទី២) សមស្របទៅនឹងសម័យបច្ចុប្បន្ននោះ។

## ផ្នែកទី១៖ ការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជា

ក្រមមតិកចាស់របស់កម្ពុជា បានកំណត់ជាគោលការណ៍ថា មតិករបស់ខ្មោចដែលនៅសល់បន្ទាប់ពីថ្វាយហ្លួងវិញ នូវអ្វីដែលហ្លួងប្រទានឲ្យនោះ ត្រូវបានបែងចែកដូចតទៅ៖ មួយចំណែកទៅហ្លួង មួយចំណែកទៅឪពុកម្ដាយ មួយចំណែកទៅកូន និងមួយចំណែកទៅភរិយា។

ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ដែលរងឥទ្ធិពលខ្លាំងពីច្បាប់បារាំង (បន្ទាប់ពីបារាំងទទួលបានសិទ្ធិធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់របស់កម្ពុជានោះ) បានកំណត់សិទ្ធិរបស់ប្រពន្ធ ជាលំដាប់សន្តតិជននៅក្រោយគេបង្អស់មុនឈានដល់រដ្ឋ ពោលគឺត្រូវប្រគល់មតិកឲ្យទៅសាច់សារលោហិត កូន ឪពុកម្ដាយ បងប្អូនបង្កើត និងញាតិការនៃមតកជន ទៅតាមលំដាប់។ ក្នុងករណីដែលមិនមានជនដូចបានរៀបរាប់ខាងលើ ទើបសន្តតិកម្មនោះអាចធ្លាក់មកដល់ប្រពន្ធបាន។ ប្រពន្ធក្នុងន័យនេះ គឺសំដៅទៅលើប្រពន្ធដើម មានខាន់ស្លា (មានអាពាហ៍ពិពាហ៍) ហើយមិនទាន់លែងលះ។ ចំពោះប្រពន្ធចុង អាចមានជម្រើសដោយបន្តរស់នៅ ជ្រកកោនជាមួយគ្នានឹងប្រពន្ធដើម ឬ ចាកចេញ ដោយមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ចមួយចំនួន។

ចំណែកឯក្រមរដ្ឋប្បវេណីបច្ចុប្បន្នរបស់កម្ពុជា បាននាំមកនូវការវិវត្តយ៉ាងខ្លាំង គួរឲ្យកត់សម្គាល់ ដោយបានផ្ដល់សិទ្ធិដល់សហព័ទ្ធ (ប្ដី ឬ ប្រពន្ធ) នៃមតកជនដែលនៅរស់ ថាជា

"សន្តតិជនជានិច្ច" ពោលគឺអាចទទួលមតិកបានគ្រប់កាលៈទេសៈ។ ដូចនេះយើងអាចសន្និដ្ឋានបានថា សិទ្ធិរបស់សហព័ទ្ធក្នុងសន្តតិកម្មកម្ពុជា ពិតជាមានការវិវត្តខ្លាំងមែនទែន ដោយសម្របទៅតាមសម័យទំនើបកម្មនាពេលបច្ចុប្បន្ននេះយ៉ាងពិតប្រាកដមែន។

ដើម្បីការពារសហព័ទ្ធក្នុងករណី ដូចបានលើកឡើងខាងលើ ច្បាប់បានកំណត់នូវវិធានជាមូលដ្ឋានស្តីពីទម្រង់នៃការអនុវត្តសន្តតិកម្ម ក្នុងគោលដៅរក្សាឲ្យបាននូវសិទ្ធិរបស់សហព័ទ្ធ ដែលបានកំណត់នូវលំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម (១) យ៉ាងជាក់លាក់។

### ១. លំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម កម្ពុជា

ចំពោះសន្តតិកម្មតាមច្បាប់ លំដាប់សន្តតិកម្ម គឺជាការកំណត់អំពីសិទ្ធិអាទិភាពក្នុងការទទួលបាននូវមតិក។ មានន័យថា ក្នុងករណីដែលមតកជនមិនបានធ្វើមតកសាសន៍ ដើម្បីចាត់ចែងទ្រព្យសម្បត្តិជាមតិករបស់ខ្លួនទេនោះ សន្តតិជនតាមច្បាប់ដែលស្ថិតក្នុងលំដាប់មុន មានសិទ្ធិទទួលយកទ្រព្យសម្បត្តិមួយផ្នែក ឬ ទាំងអស់ក្នុងករណីដែលមានអត្ថិភាព ឬ នត្ថិភាពនៃសន្តតិជនផ្សេងទៀតតាមការកំណត់ជាមុនដោយច្បាប់។ ដូចបានលើកឡើងរួចមកហើយថា ក្នុងចំណោមសន្តតិជនទាំងអស់ សហព័ទ្ធក៏ជាសន្តតិជនម្នាក់ ដែលត្រូវបានកំណត់ដោយច្បាប់ផងដែរ។ លំដាប់នៃសន្តតិកម្មរបស់សហព័ទ្ធ ត្រូវបានកំណត់ទៅតាមស្ថានភាពសង្គមដែលប្រែប្រួល ពីសម័យកាលមួយទៅសម័យកាលមួយ។ ដូចនេះ យើងនឹងធ្វើការសិក្សាស្វែងយល់អំពី ការប្រែប្រួលនៃលំដាប់របស់សហព័ទ្ធ ក្នុងសន្តតិកម្មកម្ពុជា (១.១) ឲ្យបានក្បោះក្បាយ។

### ១.១. ការប្រែប្រួលនៃលំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម កម្ពុជា

ដូចធ្លាប់បានរៀបរាប់ខាងលើ នៅក្នុងប្រវត្តិសាស្ត្រនៃច្បាប់ស្តីពីសន្តតិកម្មរបស់កម្ពុជា លំដាប់សន្តតិកម្មរបស់សហព័ទ្ធ មានការប្រែប្រួល បើប្រៀបធៀបរវាងក្រមរដ្ឋប្បវេណីចាស់ (១.១.១) និងនីតិវិជ្ជមាន(១.១.២)។ ដូចនេះដើម្បីឲ្យកាន់តែច្បាស់លើការប្រែប្រួលនេះ យើងនឹងធ្វើការបកស្រាយទៅតាមលំដាប់នីមួយៗជាបន្តបន្ទាប់ដូចខាងក្រោមៈ

#### ១.១.១ លំដាប់សន្តតិកម្មរបស់សហព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីកម្ពុជាចាស់

ក្រៅពីក្រមរដ្ឋប្បវេណីបច្ចុប្បន្ន នៅក្នុងទម្លាប់នៃការអនុវត្តច្បាប់ដែលចែងពីសន្តតិកម្ម ដែលមានបញ្ញត្តិអំពីសិទ្ធិរបស់សហព័ទ្ធក្នុងសន្តតិកម្មនោះ គឺមានតែក្រមរដ្ឋប្បវេណីចាស់ ១៩២០ ដែលទទួល ឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំងប៉ុណ្ណោះ ដែលអាចធ្វើការសិក្សាបាន។ ក្រមរដ្ឋប្បវេណីចាស់បានចែង នូវបញ្ញត្តិជាច្រើនទាក់ទងនឹងសន្តតិកម្ម ក្នុងនោះលំដាប់សន្តតិកម្មដែលឥតបណ្តាំ គឺ

ត្រូវបានយកមកអនុវត្តដោយគោរពទៅតាមលំដាប់ជាបន្តបន្ទាប់ ដោយគិតចាប់ពី បច្ឆាញាតិផ្ទាល់នៃខ្មោច ត្រូវជាសន្តតិជនលំដាប់ទី១[៤៨]។ បើខ្មោចនោះគ្មានកូនទេ សន្តតិកម្មត្រូវបានទៅឪពុកម្តាយនៃខ្មោច[៤៩](សន្តតិជនលំដាប់ទី២)។ បើខ្មោចនោះឥតកូន ឥតឪពុក ឥតម្តាយទេ សន្តតិកម្មត្រូវបានបែងចែកជាពីរភាគគឺ មួយភាគត្រូវបានទៅលើ បុព្វញាតិខាងឪពុក ឯមួយភាគទៀតត្រូវបានទៅបុព្វញាតិខាងម្តាយ[៥០] (សន្តតិជនលំដាប់ទី៣)។ មួយវិញទៀត បើខ្មោចនោះឥតកូនចៅ ឥតបុព្វញាតិ សន្តតិកម្មត្រូវបានទៅបងប្អូនប្រុសស្រីដែលមានឪពុកម្តាយជាមួយគ្នា[៥១](សន្តតិជនលំដាប់ទី៤)។ ជាចុងក្រោយ ប្រពន្ធរបស់ខ្មោចអាចមានសិទ្ធិទទួលសន្តតិកម្មបានលុះត្រាតែក្នុងករណី ដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ បងប្អូនបង្កើត និងសន្តតិជនជំនួសជននោះតែប៉ុណ្ណោះ[៥២]។ លក្ខខណ្ឌនេះអាចបង្ហាញឲ្យឃើញថា សហព័ទ្ធ គឺមានលទ្ធភាពតិចតួចបំផុត ក្នុងការទទួលបាននូវឋានៈជាសន្តតិជន ដើម្បីទទួលបានទ្រព្យសម្បត្តិដែលជាមតិករបស់មតកជន។

### ១.១.២. លំដាប់សន្តតិកម្មរបស់សហព័ទ្ធផ្អែកតាមនីតិវិជ្ជមានកម្ពុជា

នៅប្រទេសកម្ពុជា ប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានអនុម័តជាគោលការណ៍[៥៣]។ នីតិវិជ្ជមានដែលបានរំលេចឡើងនៅក្នុងចំណុចទី២ នៃកថាខណ្ឌទី១ខាងលើ នេះគឺមានបំណងចង្អុលទៅក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលបានតាក់តែងស្របទៅតាមចរន្តនៃសកលភាវូបនីយកម្ម ពោលគឺជាច្បាប់ដែលបានធ្វើនូវទំនើបកម្ម មានលក្ខណៈបច្ចុប្បន្នភាព គោរពនូវរាល់គោលការណ៍ជាសកលស្របទៅតាមបច្ចេកទេសទំនើប និងប្រតិបត្តិការអាជីវកម្មដែលចេះតែរីកចម្រើនឥតឈប់ឈរ។ ក្នុងចំណោមបទប្បញ្ញត្តិទាំងនោះ សន្តតិកម្មក៏មានការប្រែប្រួលយ៉ាងច្រើនផងដែរ ជាពិសេសលំដាប់របស់សហព័ទ្ធនៅក្នុងសន្តតិកម្ម។ ក្រមរដ្ឋប្បវេណីថ្មី បានគោរពទៅតាមទស្សនៈសមភាពរវាងបុរស និង ស្ត្រី ដោយបានទទួលស្គាល់សហព័ទ្ធរបស់មតកជនជា "សន្តតិជនជានិច្ច" ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ[៥៤]។ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ ក្នុងករណី

---

[៤៨] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា៩៩៣។

[៤៩] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា៩៩៤។

[៥០] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា៩៩៥។

[៥១] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា៩៩៦។

[៥២] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា៩៩៧។

[៥៣] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៥ គន្ថីទី៧*,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ៣២។

[៥៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១។

ដែលជននោះជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ ជាបុគ្គលដែលត្រូវបានផ្តាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ។ ដូច្នេះ ក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀត ក្រៅពីសហព័ទ្ធត្រូវជាសន្តតិជនដែរ នោះសហព័ទ្ធត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។ មានន័យថា ក្រៅពីសហព័ទ្ធ ប្រសិនបើមានសន្តតិជនផ្សេងទៀតក្នុងលំដាប់ទីប៉ុន្មាន សហព័ទ្ធត្រូវទទួលសន្តតិកម្ម ជាលំដាប់ដូចគ្នានឹងសន្តតិជននោះ។

ឧទាហរណ៍៖ ក្នុងករណីដែលមតកជនមានកូន [៥៥] និងសហព័ទ្ធ នោះសហព័ទ្ធត្រូវទទួលសន្តតិកម្មដោយមានលំដាប់ដូចគ្នានឹងកូន។

ម្យ៉ាងទៀត ប្រសិនបើមតកជនគ្មានសន្តតិជនលំដាប់ទី១ ដល់លំដាប់ទី ៣[៥៦] ទេ សហព័ទ្ធនឹងត្រូវទទួលបានសន្តតិកម្មតែម្នាក់ឯង។

ដូចបានរៀបរាប់ខាងលើ ក្រមរដ្ឋប្បវេណីថ្មីរបស់ប្រទេសកម្ពុជា បានផ្តល់សិទ្ធឲ្យសហព័ទ្ធរបស់មតកជន ក្លាយជាសន្តតិជនជានិច្ច។ តើអត្ថន័យនៃ ពាក្យសន្តតិជនជានិច្ចនេះ មានន័យយ៉ាងណានោះ យើងនឹងធ្វើការបកស្រាយបន្ថែមលម្អិត នៅក្នុងចំណុចទី២ ដូចខាងក្រោមនេះ៖

### ១.២. អត្ថន័យនៃសន្តតិជនជានិច្ច

សន្តតិកម្មរបស់សហព័ទ្ធ គឺជាសិទ្ធិដែលសហព័ទ្ធត្រូវទទួលបាននូវចំណែកមតិកពីសហព័ទ្ធម្ខាងទៀតរបស់ខ្លួនដែលបានស្លាប់ (មតកជន) តាមការកំណត់របស់ច្បាប់ ដោយក្នុងនោះ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានទទួលស្គាល់សហព័ទ្ធរបស់មតកជនក្លាយជាសន្តតិជនដែលត្រូវចូលមករួមចំណែកមតិកទៅតាមលំដាប់នីមួយៗ ដោយផ្តល់សិទ្ធិឲ្យគាត់ក្លាយជាសន្តតិជនជានិច្ច[៥៧]។ សន្តតិជនជានិច្ច មានន័យថា អត្ថិភាពនៃសន្តតិជនផ្សេងទៀត ឬ លំដាប់នៃសន្តតិកម្ម មិនត្រូវបានគេយកមកពិចារណា នៅក្នុងករណីនេះឡើយ ដោយតម្រូវឲ្យ

---

[៥៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦. កូនដែលជាសន្តតិជនលំដាប់ទីមួយនេះ ត្រូវបានរាប់បញ្ចូលទាំងកូនបង្កើត និង កូនសុំ ហើយត្រូវទទួលបានចំណែកមតិកស្មើៗគ្នា។

[៥៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦០. សន្តតិជនដែលមានលំដាប់ទី៣ គឺមានបងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។ ប្រសិនបើបងប្អូនបង្កើតមានចំនួនច្រើននាក់ ម្នាក់ៗត្រូវបានចំណែកមតិកភាគស្មើៗគ្នា។ ប៉ុន្តែ ចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬ មានតែម្តាយម្ខាងដូចគ្នា ត្រូវមាន ១ភាគ២ នៃចំណែកមតិករបស់បងប្អូនដែលមានឪពុកនិងម្តាយសងខាង។

[៥៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១. បានចាត់ទុកថាសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។

សហាព័ទ្ធមានលំដាប់ដូចគ្នា (ប៉ុន្តែចំណែកមត៌កគឺមិនស្មើគ្នានោះទេ) ដើម្បីគោរពគោលការណ៍សមភាពរវាង បុរស នឹង ស្ត្រី។ ពាក្យថា "ជានិច្ច" នៅក្នុងក្រមរដ្ឋប្បវេណីថ្មី មានន័យថា គ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងៗទៀត ព្រមទាំងលំដាប់សន្តតិកម្មនោះទេ គឺឲ្យតែសហាព័ទ្ធរបស់មតកជននៅមានជីវិតនាពេលចាប់ផ្តើមសន្តតិកម្ម ហើយមិនត្រូវបានចាត់ទុកថាជាអភ័ព្វបុគ្គល ឬត្រូវបានផ្តាច់ចេញពីមត៌ក នោះសហាព័ទ្ធនឹងត្រូវចាត់ទុកជាសន្តតិជន[៥៨]។ ករណីពិសេស ប្រសិនបើមតកជនមានតែសហាព័ទ្ធ តែពុំមានកូនចៅ ឬ សាច់ញាតិដទៃទៀត នោះមត៌ករបស់មតកជននោះនឹងត្រូវធ្លាក់លើសហាព័ទ្ធទាំងអស់តែម្តង។ ផ្ទុយទៅវិញ ប្រសិនបើមានសន្តតិជនដទៃទៀតនោះសហាព័ទ្ធដែលជា សន្តតិជនជានិច្ច ត្រូវចូលមករួមចំណែកមត៌កតាមការកំណត់របស់ច្បាប់។ ប៉ុន្តែប្រសិនបើសហាព័ទ្ធជា អភ័ព្វបុគ្គល ឬជាបុគ្គលដែលត្រូវផ្តាច់ចេញពីសន្តតិកម្មនោះសហាព័ទ្ធក៏មិនអាចចូលមករួមចំណែកនៃមត៌កបានដែរ។

ដូចធ្លាប់បានលើកឡើងខាងលើ ក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជាត្រូវបានតាក់តែងឡើងដោយទទួលឥទ្ធិពលពីខាងក្រមរដ្ឋប្បវេណីរបស់ ប្រទេសជប៉ុន ហេតុដូចនេះហើយបទប្បញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីថ្មី ដែលរួមមានទាំងលំដាប់នៃសន្តតិកម្មតាមច្បាប់របស់សហាព័ទ្ធផងនោះ ក៏ទទួល ឥទ្ធិពលពីក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនផងដែរ។

ដោយឡែក យើងនិងធ្វើការសិក្សាបន្ថែមទៅលើ ចំណែកមត៌ករបស់សហាព័ទ្ធដែលនឹងត្រូវទទួលបាន (២) ថាតើមានការកំណត់យ៉ាងដូចម្តេចខ្លះ ក៏ដូចជាមានការប្រែប្រួលបែបណាខ្លះ បើប្រៀបធៀបទៅនឹងចំណែកមត៌កដែលបានកំណត់នៅក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាយើង។

### ២. ចំណែកមត៌ករបស់សហាព័ទ្ធ ករណីកម្ពុជា

លំដាប់សន្តតិកម្ម ដែលត្រូវបានកំណត់ដោយច្បាប់មានអានុភាព ចំពោះចំណែកមត៌ករបស់សន្តតិជនរបស់មតកជន ដែលក្នុងនោះរួមមានទាំងសហាព័ទ្ធផងដែរ។ ដោយសារតែមានការទទួលស្គាល់ផ្សេងគ្នានូវ លំដាប់សន្តតិកម្មរបស់សហាព័ទ្ធក្នុងសន្តតិកម្ម អាស្រ័យហេតុនេះ ចំណែកមត៌ករបស់សហាព័ទ្ធ ក៏មានការប្រែប្រួល ទៅតាមសម័យកាលនៃការបង្កើតច្បាប់ពាក់ព័ន្ធនឹងសន្តតិកម្មផងដែរ។

[៥៨] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៦ គន្ថីទី៨ ទី៩*,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ២០។

ចំណែកមតិករបស់សហព័ទ្ធ មានការប្រែប្រួលទៅតាមប្រភេទនៃសន្តតិជនផ្សេងៗទៀត។ ខាងក្រោមនេះ គឺជាការបង្ហាញពីភាពខុសគ្នានូវចំណែកមតិករបស់សហព័ទ្ធក្នុងករណីសហព័ទ្ធ និង បច្ឆាញាតិ (២.១) និង ករណីសហព័ទ្ធ និង ឪពុកម្តាយ (២.២) ព្រមទាំងករណីសហព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្តាយ (២.៣) ដោយស្របតាមនីតិវិជ្ជមាន ពោលគឺក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ដោយលើកជាឧទាហរណ៍មកធ្វើការបកស្រាយ ដើម្បីឲ្យកាន់តែមានភាពងាយស្រួល។ លើសពីនេះ យើងក៏បានភ្ជាប់មកជាមួយនឹងតារាងសង្ខេបនៃចំណែកមតិកក្នុងករណីមានសហព័ទ្ធជាសន្តតិជនផងដែរ។

### **២.១. សហព័ទ្ធ និង បច្ឆាញាតិ**

យោងតាមបញ្ញត្តមាត្រា ១១៦២ (ក) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា "បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗរបស់មតកជននោះ និងត្រូវទទួលចំណែកមតិកស្មើគ្នា" ។

ឧទាហរណ៍ៈ មតកជន មានសហព័ទ្ធ កូនបង្កើតពីរនាក់ និងកូនសុំម្នាក់។ ក្នុងករណីនេះយើងសង្កេតឃើញថា មតកជនបានបន្សល់នូវសហព័ទ្ធ និងកូននីមួយៗដែលជាបច្ឆាញាតិផ្ទាល់របស់ខ្លួន នោះសហព័ទ្ធ និង បច្ឆាញាតិរបស់មតកជនត្រូវទទួលបានចំណែកមតិកស្មើៗគ្នា។ ដោយសារតែសន្តតិជនមាន៤នាក់នោះទ្រព្យសម្បត្តិរបស់មតកជនត្រូវបែងចែកជា ៤ចំណែកស្មើៗគ្នា ដោយចំណែករបស់សហព័ទ្ធ ស្មើចំណែកកូនទី១ ស្មើចំណែកកូនទី២ ស្មើចំណែកកូនសុំ គឺស្មើនឹង ១/៤ (មួយភាគបួន) នៃមតិក សរុបទាំងអស់។




ក្នុងករណីនេះ សន្តតិកម្មជំនួសក៏ត្រូវបានអនុវត្តផងដែរ ដោយសន្តតិជនជំនួសមានសិទ្ធិមកចែកចំណែកដែលសន្តតិជននោះទទួលបាន។

ឧទាហរណ៍៖ មតកជន និង សហព័ទ្ធមានកូន៤នាក់។ យើងដឹងថានៅពេលចាប់ផ្តើមបើកសន្តតិកម្ម កូនទី១បានទទួលមរណភាព ចំណែកកូនទី២ បានក្លាយជាអភ័ព្វបុគ្គល រីឯកូនទី៣ត្រូវមតកជនផ្តាច់ចេញពីមត៌ក។ ករណីនេះ កូនទី១ ទី២ និង ទី៣មិនអាចទទួលបានចំណែកមត៌កទេ។ ប៉ុន្តែ កូនទី១មានកូន ៣នាក់ គឺ $ក_{១}$ $ក_{២}$ និង $ក_{៣}$ ចំណែកកូនទី២មានកូន១នាក់គឺ $ខ_{១}$ និង កូនទី៣មានកូន២នាក់គឺ $គ_{១}$ និង $គ_{២}$។ ករណីនេះ ចំណែកមត៌កត្រូវបែងចែងជា ៥ចំណែកស្មើគ្នា ដោយ៖

- សហព័ទ្ធ ត្រូវបានចំណែកមត៌ក ១/៥ (មួយភាគប្រាំ)
- កូនទី៤ ត្រូវបានចំណែកមត៌ក ១/៥(មួយភាគប្រាំ)
- ចំណែមត៌ក ១/៥ របស់កូនទី១ ត្រូវចែកទៅកូន៣នាក់ គឺ $ក_{១}$ $ក_{២}$ និង $ក_{៣}$ នោះ $ក_{១}$ $ក_{២}$ និង $ក_{៣}$ ត្រូវទទួលបានចំណែក ១/១៥ (មួយភាគដប់ប្រាំ) ស្មើៗគ្នា
- ចំណែកមត៌ក ១/៥ (មួយភាគប្រាំ)របស់កូនទី២ ត្រូវបានទៅកូនតែម្នាក់របស់គាត់គឺ $ខ_{១}$ ទាំងស្រុង នោះ$ខ_{១}$ ត្រូវទទួលបានចំណែក ១/៥ (មួយភាគប្រាំ)
- ចំណែក១/៥ (មួយភាគប្រាំ)របស់កូនទី៣ ត្រូវចែកទៅកូន២នាក់ គឺ $គ_{១}$ និង $គ_{២}$ នោះ $គ_{១}$ និង $គ_{២}$ នឹងត្រូវទទួលបានចំណែក ១/១០ (មួយភាគដប់) ស្មើៗគ្នា។




### ២.២. សហព័ទ្ធ និង ឪពុកម្តាយ

បើសហព័ទ្ធ និង ឪពុកម្តាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១/៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុកម្តាយ ត្រូវជា ២/៣ (ពីរភាគ៣)។ ប៉ុន្តែ បើឪពុកម្តាយ

របស់មតកជនតែម្នាក់នៅរស់ ឪពុកម្ដាយនោះ និង សហាព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា[៩៩] គឺ១/២ (មួយភាគពីរ)។ ក្នុងករណីពិសេស ដែលមតកជនមានឪពុកម្ដាយច្រើន នោះចំណែកមត៌ករបស់សហាព័ទ្ធត្រូវជា ១/៣ (មួយភាគបី) ដដែល ឯចំណែករបស់ឪពុកម្ដាយត្រូវចែកនឹងចំណែកដែលនៅសល់ ដោយម្ដាយឪពុកម្នាក់ៗត្រូវទទួលបានចំណែកស្មើៗគ្នា។

ឧទាហរណ៍៖ មតកជនមានម្ដាយ ឪពុក និង ឪពុកចិញ្ចឹម ព្រមទាំងសហាព័ទ្ធ។ នោះទ្រព្យសម្បត្តិរបស់មតកជននឹងត្រូវធ្វើការបែងចែកដូចតទៅ៖

- សហាព័ទ្ធ ត្រូវទទួលបានចំណែកមត៌ក ១/៣ (មួយភាគបី) ដោយស្វ័យប្រវត្តិ
- ចំណែកមត៌ក ២/៣ (ពីរភាគបី) ដែលនៅសល់ត្រូវយកមកបែងចែកជា ៣ចំណែកស្មើគ្នាទៅឲ្យ ម្ដាយ ឪពុក និង ឪពុកចិញ្ចឹម នោះចំណែកមត៌ករបស់ពួកគាត់នីមួយៗ ត្រូវស្មើនឹង ២/៩ (ពីរភាគប្រាំបួន)។




## ២.៣. សហាព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្ដាយ

ក្នុងករណីដែលសហាព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយ (ជីដូនជីតា) ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ របស់មតកជន ជាសន្តតិជន នោះចំណែកមត៌ករបស់សហាព័ទ្ធ ត្រូវជា១/២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសត្រូវជា ១/២ (មួយភាគពីរ)។ មានន័យថាសហាព័ទ្ធរបស់មតកជនត្រូវបានចំណែក ១/២ (មួយភាគពីរ) តែម្ដង

[៩៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦២ ចំណុច ខ។

ហើយចំណែក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវយកមកបែងចែកឲ្យសហាសន្តតិជនផ្សេងទៀត ដែលជាបងប្អូនបង្កើត ឬ បុព្វញ្ញាតិក្រៅពីឪពុកម្តាយ[១០០]។

ឧបមាថា៖ បើម្តាយ និង ឪពុករបស់មតកជនបានទទួលមរណភាព តែនៅមានជីដូនជីតានោះ សហព័ទ្ធរបស់មតកជន ត្រូវចែកចំណែកជាមួយ ជីដូនជីតាទាំងសងខាងដែលមាន ដោយធ្វើការបែងចែកចំណែកមតិកដូចខាងក្រោម៖

- សហព័ទ្ធ ត្រូវទទួលបានចំណែកមតិក ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ
- ចំណែកមតិក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវយកមកបែងចែកជា ៤ចំណែកឲ្យទៅជីដូនជីតាទាំងសងខាង នោះចំណែកមតិកដែលពួកគាត់ម្នាក់ៗត្រូវទទួលបាន ស្មើនឹង ១/៨ (មួយភាគប្រាំបី)។




ដោយឡែក ករណីដែលសហព័ទ្ធរបស់មតកជន ជាមួយនឹងបងប្អូនបង្កើតរបស់មតកជនជាសន្តតិជននោះចំណែកមតិករបស់សហព័ទ្ធត្រូវជា ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ រីឯចំណែកមតិក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវចែកឲ្យបងប្អូនបង្កើតរបស់មតកជនស្មើៗគ្នា។

ឧបមាថា៖ មតកជន មានបងប្អូនបង្កើត២នាក់ និង បងប្អូនរួមឪពុក១នាក់ ព្រមទាំងសហព័ទ្ធ និង ស្រីកំណាន់ម្នាក់។ នោះទ្រព្យសម្បត្តិរបស់មតកជន នឹងត្រូវបែងចែកដូចខាងក្រោម៖

- សហព័ទ្ធ ត្រូវទទួលបានចំណែកមតិក ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ

[១០០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦២ ចំណុច គ។

- ចំណែក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវបែងចែកឲ្យ បងទី១ បងទី២ និង បងប្អូនរួមឪពុករបស់មតកជន គឺប្អូនទី៤។ ប៉ុន្តែ ប្អូនទី៤ ជាបងប្អូនរួមតែឪពុកជាមួយមតកជន នោះប្អូនទី៤ ត្រូវទទួលបានចំណែកពាក់កណ្តាល នៃចំណែកដែល បងទី១ និង បងទី២ត្រូវទទួលបានតែប៉ុណ្ណោះ[១០១]។ ដូចនេះ បងទី១ និង បងទី២ ត្រូវទទួលបានចំណែកមតិក ១/៥ (មួយភាគប្រាំ) ស្មើគ្នា ហើយប្អូនទី៤ត្រូវទទួលបានចំណែក ១/១០ (មួយភាគដប់)។
- ដោយឡែក ស្រីកំណាន់ដែលជាម្តាយរបស់ប្អូនទី៤ គឺពុំមានសិទ្ធិមកទទួលចំណែកមតិករបស់មតកជនបានឡើយ សូម្បីតែមួយភាគ លើកលែងតែមានលិខិតបណ្តាំ។




នៅក្នុងករណីសន្តតិកម្មជំនួស ត្រូវអនុវត្តដូចគ្នាផងដែរ ដោយសន្តតិជនជំនួសមានសិទ្ធិមកចែកចំណែកដែលសន្តតិជននោះទទួលបានតែប៉ុណ្ណោះ។

តាមរយៈគំនូសតាងខាងក្រោម យើងដឹងថាម្តាយ និង ឪពុករបស់មតកជនបានស្លាប់។ ហើយមតកជនមានបងប្អូនរួមម្តាយឪពុក ២នាក់ និង បងប្អូនរួមតែឪពុកម្នាក់ ព្រមទាំងសហាព័ទ្ធ ។ ដូចនេះ ទ្រព្យរបស់មតកជន នឹងត្រូវបែងចែកទៅឲ្យសហាព័ទ្ធ និង បងប្អូនទាំង៣របស់មតកជន។ ប៉ុន្តែ នៅថ្ងៃបើកសន្តតិកម្ម យើងបានដឹងថាបងទី១ របស់មតកជនបានទទួលមរណភាព ដោយមានកូន២នាក់ ទន្ទឹមនឹងនេះដែរ ប្អូនទី៤របស់មតកជន ត្រូវបានក្លាយជាអភ័ព្វបុគ្គលដោយមានកូន២នាក់ដែរ។ ដូចនេះ ការបែងចែកទ្រព្យសម្បត្តិរបស់មតកជន នឹងត្រូវគណនាដូចខាងក្រោម៖

- សហាព័ទ្ធ ត្រូវទទួលបានចំណែកមតិក ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ

---

[១០១]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦០ កថាខណ្ឌទី២ វាក្យខ័ណ្ឌ២ បានបញ្ញត្តថា ចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១/២ (មួយភាគពីរ) នៃចំណែកមតិករបស់ បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា។

- ចំណែកមត៌ក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវបែងចែកទៅឲ្យ បងទី១ បងទី២ និង ប្អូនទី៤។ ក៏ប៉ុន្តែ ដោយសារតែ បងទី១បានទទួលមរណភាព ឯប្អូនទី៤ត្រូវបានក្លាយជាអភ័ព្វបុគ្គល។ ដូចនេះ ពួកគេទាំងពីរពុំមានសិទ្ធិមកទទួលចំណែកមត៌កបានទេ ដោយចំណែកមត៌ករបស់ពួកគេត្រូវផ្ទេរទៅឲ្យសន្តតិជនជំនួស គឺ ក១ ក២ ខ១ និង ខ២ ដែលត្រូវជាកូនរបស់ពួកគាត់។ ដូចនេះចំណែកមត៌ករបស់ បងទី២ ក១ ក២ខ១ និង ខ២ នឹងត្រូវបែងចែកដូចខាងក្រោមៈ
  - ចំណែកមត៌ករបស់បងទី២ ត្រូវទទួលបានត្រូវជា ១/៥ (មួយភាគប្រាំ)
  - ក១ និង ក២ ជាសន្តតិជនជំនួសដែលត្រូវទទួលចំណែក ១/៥ (មួយភាគប្រាំ) របស់បងទី១ នោះចំណែករបស់ពួកគេនីមួយៗ ត្រូវជា ១/១០ (មួយភាគដប់) ស្មើៗគ្នា។
  - ខ១ និងខ២ ជាសន្តតិជនជំនួសដែលត្រូវទទួលចំណែក ១/១០ (មួយភាគដប់) របស់បងទី១ នោះចំណែករបស់ពួកគេនីមួយៗ ត្រូវជា ១/២០ (មួយភាគម្ភៃ) ស្មើៗគ្នា។



***ខាងក្រោមនេះជាតារាងសង្ខេបនៃចំណែកមត៌កក្នុងករណីមានសហព័ទ្ធជាសន្តតិជន៖***

<table>
<tr><td rowspan="2">សហព័ទ្ធ និង កូន</td><td colspan="4">សហព័ទ្ធ និង បុព្វញាតិផ្ទាល់</td><td colspan="2" rowspan="2">សហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬ បងប្អូនបង្កើត ឬ សន្តតិជនជំនួសបងប្អូនបង្កើត</td></tr>
<tr><td colspan="2">សហព័ទ្ធ និងឪពុកម្តាយ</td><td colspan="2">សហព័ទ្ធ និងឪពុក ឬម្តាយ</td></tr>
<tr><td rowspan="2">សហព័ទ្ធ និង កូន ត្រូវទទួលបាន ចំណែកមត៌ក ស្មើៗគ្នា។</td><td>សហព័ទ្ធ</td><td>ឪពុកម្តាយ</td><td>សហព័ទ្ធ</td><td>ឪពុក/ម្តាយ</td><td>សហព័ទ្ធ</td><td>សន្តតិជនផ្សេងទៀត</td></tr>
<tr><td>១ ភាគ ៣</td><td>២ ភាគ ៣</td><td>១ ភាគ ២</td><td>១ ភាគ ២</td><td>១ ភាគ ២</td><td>១ ភាគ ២</td></tr>
</table>

ក្រោយពីសិក្សាពី ចំណែកមត៌ករបស់សហព័ទ្ធ រួចមក យើងនឹងធ្វើការសិក្សាបន្តទៅលើសិទ្ធិរបស់សហព័ទ្ធលើភាគបម្រុង ដែលនឹងត្រូវបកស្រាយក្នុងចំណុចទី៣ ខាងក្រោមនេះ៖

### ៣. សិទ្ធិរបស់សហព័ទ្ធលើភាគបម្រុង ករណីកម្ពុជា

របបភាគបម្រុង គឺជារបបធានាមួយភាគនៃចំណែកមត៌កកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់។ ភាគបម្រុង គឺជាសិទ្ធផ្តាច់មុខ និងក្រៅបេតិកភណ្ឌរបស់មតកជនដែលជាម្ចាស់សិទ្ធិ មានន័យថា សិទ្ធិនេះមិនអាចត្រូវបានរឹបអូស ឬ ចាត់ចែងដោយការលក់ ឬ ដូរបាននោះទេ។ ក្រមរដ្ឋប្បវេណី បានបង្កើតនូវរបបភាគបម្រុង ដែលធ្វើឲ្យមានការរឹតត្បឹតមួយផ្នែកនូវសេរីភាពនៃការធ្វើមតកសាសន៍របស់មតកជន។ ប្រសិនបើផ្អែកទៅលើ ការគោរពឆន្ទៈរបស់បុគ្គលម្នាក់ៗ គេគប្បីទទួលស្គាល់នូវសេរីភាពរបស់បុគ្គលក្នុងការចាត់ចែងទ្រព្យសម្បត្តិ ទាំងពេលនៅរស់ទាំងក្រោយពេលទទួលមរណភាព ប៉ុន្តែ គេក៏គួរតែផ្តល់កិច្ចការពារផងដែរ ចំពោះគ្រួសារដែលធ្លាប់ទទួលការឧបត្ថម្ភពីមតកជន និង ចំពោះសេចក្តីសង្ឃឹមរបស់សន្តតិជនតាមច្បាប់ ដែលរំពឹងថាខ្លួននឹងបានទទួលបន្តទ្រព្យសម្បត្តិនោះ។ ហេតុដូច្នេះហើយ មត៌កមួយផ្នែករបស់មតកជន ត្រូវទុកជាភាគបម្រុង ដើម្បីធានាចំពោះសន្តតិជននូវការទទួលបាន។ ទោះជាយ៉ាងណា ច្បាប់មិនបានដាក់កំហិតដល់សន្តិជនតាមច្បាប់ ដោយមានរារាំង ក្នុងការបោះបង់នូវសិទ្ធិរបស់ខ្លួនក្នុងការទទួលយកចំណែកភាគបម្រុងនោះទេ។ បើគេថ្លឹងថ្លែងអំពីសេរីភាពរបស់មតកជន និង សិទ្ធិរបស់សន្តតិជននោះ អាចយល់បានថា ទោះបីជាបុគ្គលឯកជន មានសិទ្ធិសម្រេចដោយសេរីនូវជោគវាសនា លើទ្រព្យសម្បត្តិរបស់ខ្លួនក៏ដោយ ក៏សិទ្ធិនេះមិនផ្តោតសំខាន់ដល់សិទ្ធិរបស់សន្តតិជនតាមច្បាប់ដែល

ជាញាតិលោហិតរបស់មតកជន ក្នុងការទាមទារនូវចំណែកភាគបម្រុងនោះឡើយ។ ប៉ុន្តែ ទោះបីជាត្រូវបានធានាឲ្យមានភាគបម្រុងក៏ដោយ ក៏មិនមែនមានន័យថា ករណីនៃអច្ច័យទានលើទ្រព្យសម្បត្តិទាំងអស់ ឬ ប្រទានកម្មដែលបុគ្គលបានធ្វើ មុននឹងទទួលមរណភាព ត្រូវអស់សុពលភាពភ្លាមៗដែរនោះទេ។ ចំពោះភាគបម្រុងដែលត្រូវបានបំពាន អ្នកមានសិទ្ធិលើភាគបម្រុងនោះ អាចទាមទារឲ្យធ្វើការកាត់បន្ថយនូវអច្ច័យទាន និង ទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្ម ត្រឹមកម្រឹតដែលចាំបាច់ដើម្បីបង្គ្រប់ភាគបម្រុងនោះ សំដៅប្រមូលមតិកមកវិញ ដោយយោងតាមការអនុវត្តនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ សហព័ទ្ធរបស់មតកជន ត្រូវបានទទួលស្គាល់ជាសន្តតិជនទាំងក្នុងក្រមរដ្ឋប្បវេណីចាស់[១០២] និង ក្រមរដ្ឋប្បវេណីថ្មី[១០៣]ដែលការទទួលស្គាល់នេះអាចឲ្យគេយល់បានថា សហព័ទ្ធក៏មានសិទ្ធិទទួលភាគបម្រុង ដែលកំណត់ដោយច្បាប់ផងដែរ។

ខាងក្រោមនេះ គឺជា គោលគំនិតដែលច្បាប់កម្ពុជាផ្តល់ឲ្យសហព័ទ្ធទទួលបាននូវសិទ្ធិលើភាគបម្រុងដែលនឹងត្រូវបកស្រាយក្នុងចំណុច ៣.១ ។

## ៣.១ គោលគំនិតដែលផ្តល់ឲ្យសហព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុង

ដូចដែលបានបកស្រាយនៅក្នុងចំណុច ៣ ខាងលើ ភាគបម្រុងគឺជារបបមួយដែលគេបង្កើតឡើងក្នុងគោលបំណង ដើម្បីធានានូវចំណែកមតិកកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់។ ដោយយោងតាមច្បាប់រដ្ឋប្បវេណីរបស់កម្ពុជា បានកំណត់ឲ្យ បុព្វញាតិផ្ទាល់ និង បច្ឆាញាតិផ្ទាល់នៃមតកជនក្លាយជា សន្តតិជនដែលមានសិទ្ធិលើភាគបម្រុង។ នៅក្នុងនោះដែរ សហព័ទ្ធរបស់មតកជន ក៏ត្រូវបានច្បាប់ផ្តល់ឲ្យមានសិទ្ធិលើភាគបម្រុងផងដែរ[១០៤]។ ចំពោះគោលគំនិតដែលផ្តល់ឲ្យសហព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុងនេះ បើយើងគិតតាមស្ថានភាពជាក់ស្តែង យើងអាចសន្និដ្ឋានបានថា ដោយសារតែសហព័ទ្ធ គឺជាបុគ្គលដែលតែងតែនៅ ជិតដិតនឹងមតកជនបំផុត ហើយក៏ជាបុគ្គលដែលតែងតែ មើលថែរក្សាមតកជនពេលដែលនៅរស់។ ដូចនេះ វាពិតជាសមហេតុផលណាស់ ដែលច្បាប់គួរតែផ្តល់ឲ្យបុគ្គលដែលជាសហព័ទ្ធ មានសិទ្ធិលើភាគបម្រុង។ និយាយជារួមមក សហព័ទ្ធ គឺជាបុគ្គលដែលត្រូវទទួលបានការការពារពីសំណាក់ច្បាប់។ ដោយ

[១០២] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០,មាត្រា៩៩៧. បានទទួលស្គាល់ប្រពន្ធដើមមានខាន់ស្លា ជាសន្តតិជនក្នុងករណីមតកជនគ្មានបច្ឆាញាតិ បុព្វញាតិ និង បងប្អូនបង្កើត។

[១០៣]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១. បានទទួលស្គាល់សហព័ទ្ធ ជាសន្តតិជនជានិច្ច។

[១០៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣០។

ម្យ៉ាងទៀត ប្រសិនបើយើងវិភាគតាម ច្បាប់បច្ចុប្បន្នវិញ ពោលគឺ ក្រមរដ្ឋប្បវេណីកម្ពុជា នោះគឺ យោងតាមបញ្ញត្តិមាត្រា ១១៦១ គឺសហព័ទ្ធត្រូវបានផ្តល់ឲ្យក្លាយជា សន្តតិជនជានិច្ច នោះយើងអាចសន្និដ្ឋានបានថា ដោយសារតែសហព័ទ្ធ គឺជាសន្តតិជនជានិច្ច ទើបសហព័ទ្ធគួរតែទទួលបានសិទ្ធិក្នុងការទាមទារនូវភាគបម្រុងតាមសមាមាត្រដែលបានកំណត់ដោយច្បាប់នេះ។ លើសពីនេះ យើងអាចនិយាយបានថា ការរំពឹងរបស់សហព័ទ្ធក្នុងការទទួលបាននូវសន្តតិកម្ម គឺមានច្រើន ដោយសារតែសហព័ទ្ធ គឺជាសន្តតិជនជានិច្ចដែលអាចចូលមកទទួលយក មតិករបស់មតកជន បានគ្រប់កាលៈទេសៈ ដូចនេះការផ្តល់សិទ្ធិឲ្យសហព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុង គឺពិតជាសមហេតុផលណាស់ ។

ដោយឡែក ខាងក្រោមនេះយើងនឹងសិក្សាបន្ត ថា តើសហព័ទ្ធអាចទទួលបាន នូវភាគបម្រុងក្នុងកម្រិតណា? (៣.២) ហើយមានភាពខុសប្លែកគ្នាយ៉ាង បើប្រៀបធៀបទៅនឹងកម្រិតដែលសន្តតិជនផ្សេងទៀត ត្រូវទទួលបាន? ក្នុងនោះដែរយើងនឹងបកស្រាយប្រៀបធៀបទៅនឹង ច្បាប់កម្ពុជាចាស់ផងដែរ ដើម្បីឲ្យកាន់តែយល់ច្បាស់ ពីកម្រិតភាគបម្រុងរបស់សហព័ទ្ធ មានការវិវត្តទៅជាយ៉ាងណា? ដោយភ្ជាប់ជាមួយនឹងតារាងសង្ខេបផងដែរ។

### ៣.២. កម្រិតនៃភាគបម្រុងដែលសហព័ទ្ធទទួលបាន

សិទ្ធិរបស់សហព័ទ្ធលើភាគបម្រុងដែលកំណត់ដោយច្បាប់មានការវិវត្តខ្លាំង ចំពោះការការពារដែលមាននៅក្នុងក្រមរដ្ឋប្បវេណីថ្មី បើប្រៀបធៀបជាមួយនឹងក្រមរដ្ឋប្បវេណីចាស់។ នៅក្នុងក្រមរដ្ឋប្បវេណីចាស់ សិទ្ធិរបស់ ប្តី និង ប្រពន្ធក្នុងរបបអាពាហ៍ពិពាហ៍ មិនទាន់គោរពបាននូវសមភាពរវាងបុរស និង ស្ត្រីនៅឡើយទេ។ ច្បាប់នេះ បានទទួលស្គាល់តែប្រពន្ធដើមមានខាន់ស្លា និងបច្ឆាញាតិផ្ទាល់របស់មតកជនប៉ុណ្ណោះ ដែលអាចទទួលសិទ្ធិទាមទារភាគបម្រុងបាន។ ថ្វីត្បិតតែសហព័ទ្ធ ជាប្រពន្ធត្រូវបានទទួលស្គាល់ថាជាសន្តតិជនក៏ដោយ ក៏ច្បាប់បានបង្ហាញពីវិសមភាពចំពោះសិទ្ធិទាមទារលើភាគបម្រុង ក្នុងមាត្រា ៥៣៧ នៃច្បាប់នេះដែរ។ មាត្រានេះកំណត់ថា "ប្តីមិនអាចផ្តាំឲ្យបន្ថយភាគនៃទ្រព្យសម្បត្តិដែលត្រូវបានមកប្រពន្ធឲ្យតិចជាង ១ ភាគ ៣ បានទេ រីឯប្រពន្ធមិនអាចផ្តាំ ឲ្យបន្ថយភាគច្រើននៃទ្រព្យសម្បត្តិដែលត្រូវបានទៅប្តីឲ្យតិចជាង ២ ភាគ ៣ បានឡើយ"។ តាមរយៈការការពារនៃច្បាប់នេះ ជនដែលទទួលផលប្រយោជន៍ពីភាគម្រុង ដែលរួមមានសហព័ទ្ធ ទី១ ឬ បច្ឆាញាតិដែលនៅរស់ អាចប្តឹងទៅតុលាការដើម្បីទាមទារសុំឲ្យបន្ថយនូវចំណែកមតិកដែលកំណត់ដោយមតកសាសន៍បាន ក្នុងករណីដែលមតកសាសន៍នោះ ធ្វើឲ្យខូចសិទ្ធិចំពោះ

ភាគបម្រុង ដែលត្រូវបានការពារដោយច្បាប់ ក្នុងរយៈពេល ៣ ខែ គិតតាំងពីថ្ងៃមរណភាពនៃមតកជន។

ចំណែកឯក្រមរដ្ឋប្បវេណីថ្មីវិញ សិទ្ធិរបស់សហព័ទ្ធចំពោះភាគបម្រុង មានការវិវត្តគួរឲ្យកត់សម្គាល់។ ក្នុងច្បាប់នេះ ក្នុងចំណោមសន្តតិជនដែលកំណត់ដោយច្បាប់ មានតែបច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជនទេ ដែលជាអ្នកមានសិទ្ធិលើភាគបម្រុង[១០៥]។ មានន័យថា ក្រៅពីបងប្អូនបង្កើតរបស់មតកជន និង ជនទទួលសន្តតិកម្មជំនួសបងប្អូនបង្កើត គឺសន្តតិជនផ្សេងទៀត ដែលក្នុងនោះមានទាំងសហព័ទ្ធផងនោះ ជាអ្នកមានសិទ្ធិលើភាគបម្រុង។ ចំណែកភាគបម្រុងដែលកំណត់ដោយច្បាប់នេះ រួមមាន៖ ក្នុងករណីដែលមានតែឪពុកម្តាយ ឬ ជីដូនជីតារបស់មតកជនប៉ុណ្ណោះ ជាសន្តតិជននោះ ចំណែកភាគបម្រុង គឺស្មើនឹង ១ ភាគ ៣ នៃមតិក តែក្នុងករណី ដែលបច្ឆាញាតិផ្ទាល់ ឬ សហព័ទ្ធរបស់មតកជនជាសន្តតិជននោះចំណែកភាគបម្រុងគឺស្មើនឹង ១ ភាគ ២ នៃមតិក[១០៦]។ ដូចនេះក្នុងករណីដែលសន្តតិជន មានសិទ្ធិលើភាគបម្រុង មានទាំងសហព័ទ្ធ និង សន្តតិជននៃភាគបម្រុងផ្សេងទៀតនោះ ការកំណត់ចំណែកភាគបម្រុង គឺ ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន ហើយត្រូវធ្វើការបែងចែក ដូចក្នុងករណីបែងចែកចំណែកមតិកដែរ។ ពោលគឺ ក្នុងករណីដែលសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជនជាសន្តតិជននោះ សហព័ទ្ធត្រូវទទួលមួយចំណែកនៃភាគបម្រុង ស្មើនឹងចំណែករបស់បច្ឆាញាតិឯទៀត។ ម្យ៉ាងវិញទៀត ក្នុងករណីដែលសហព័ទ្ធ និង ឪពុកម្តាយរបស់មតកជនជាសន្តតិជន នោះសហព័ទ្ធនឹងទទួលបាន ១ ភាគ ៣ នៃចំណែកភាគបម្រុង។ ជាងនេះទៅទៀត បើសហព័ទ្ធរួមជាមួយតែ ឪពុក ឬ តែម្តាយរបស់មតកជន សហព័ទ្ធត្រូវទទួលបានចំណែកពាក់កណ្តាល ហើយករណីដែលសហព័ទ្ធត្រូវទទួលមតិករួមជាមួយជីដូនជីតារបស់មតកជន នោះសហព័ទ្ធត្រូវទទួលបានពាក់កណ្តាល ចំណែកឯជីដូនជីតារបស់មតកជន ក៏ត្រូវទទួលបានចំណែកនៃភាគបម្រុងស្មើនឹងពាក់កណ្តាលដូចគ្នាដែរ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជន និង សហព័ទ្ធជាសន្តតិជន[១០៧]នោះភាគបម្រុងរបស់សហព័ទ្ធ គឺ ១ ភាគ ២ នៃមតិកតែម្តង។ ដូច្នេះ ក្នុងករណីដែលមានការបំពានភាគបម្រុងរបស់ខ្លួន សហព័ទ្ធអាចទាមទារមកវិញ នូវទ្រព្យសម្បត្តិមួយចំនួន ដែលត្រូវយកជាកម្មវត្ថុនៃការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុង ដែលក្នុងនោះរួមមាន ទ្រព្យសម្បត្តិដែលបានធ្វើអច្ច័យទាន និង

[១០៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣០។

[១០៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, ចំណុច ក មាត្រា១២៣០។

[១០៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, ចំណុច ខ កថាខណ្ឌទី១ មាត្រា១២៣០។

ទ្រព្យសម្បត្តិដែលបានកំណត់ថាជា ចំណែកមតិកផ្អែកតាមមតកសាសន៍ ព្រមទាំងផលប្រយោជន៍ពិសេស[១០៨] និង ប្រទានកម្ម[១០៩]ដែលបានចែង ក្នុងមាត្រា ១២៣២ នៃក្រមរដ្ឋប្បវេណីថ្មី។

***ខាងក្រោមនេះគឺជាតារាងសង្ខេបកម្រិតនៃភាគបម្រុងធៀបនឹងមតិកក្នុងករណីមាននិងគ្មានសហព័ទ្ធ ៖***

| **សន្តតិជន** | **វត្តមានសហព័ទ្ធ** | **អវត្តមានសហព័ទ្ធ** |
|---|---|---|
| កូន | សហព័ទ្ធ = ១ ភាគ ៤<br>កូន = ១ ភាគ ៤ | កូន = ១ ភាគ ២ |
| ឪពុក និង ម្ដាយ | សហព័ទ្ធ = ១ ភាគ ៦<br>ឪពុក និង ម្ដាយ = ១ ភាគ ៣ | ឪពុក និង ម្ដាយ = ១ ភាគ ៣ |
| ឪពុក ឬ ម្ដាយ | សហព័ទ្ធ = ១ ភាគ ៤<br>ឪពុក ឬ ម្ដាយ = ១ ភាគ ៤ | ឪពុក ឬ ម្ដាយ = ១ ភាគ ៣ |
| ជីដូន ជីតា | សហព័ទ្ធ = ១ ភាគ ៤<br>ជីដូន ជីតា = ១ ភាគ ៤ | ជីដូន ជីតា = ១ ភាគ ៣ |
| បងប្អូនបង្កើត | សហព័ទ្ធ = ១ ភាគ ២<br>បងប្អូនបង្កើត = 0 | បងប្អូនបង្កើត = 0 |

បន្ទាប់ពីបាន បកស្រាយយ៉ាងលម្អិតអំពី ការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្មកម្ពុជាដូចបានរៀបរាប់ខាងលើ យើងនឹងស្វែងយល់បន្ត អំពីការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម របស់ប្រទេសជប៉ុន (ផ្នែកទី២) វិញម្ដង។

[១០៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦៣. ផលប្រយោជន៍ពិសេស ដែលត្រូវយកមកបូកដើម្បីគណនាភាគបម្រុង សំដៅទីលើទ្រព្យដែលត្រូវបានធ្វើប្រទានកម្មទៅឲ្យសន្តតិជន។

[១០៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៣២. ប្រទានកម្មនេះ ជាប្រទានកម្មដែលជាមូលដ្ឋានក្នុងការកំណត់ភាគបម្រុង។ ជាគោលការណ៍ ប្រទានកម្មដែលបានធ្វើអំឡុងពេល១ឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្មជាកម្មវត្ថុនៃ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ប៉ុន្តែ ក្នុងករណីដែលភាគីទាំងសងខាងបានដឹងថាប្រទានកម្មនឹង បណ្ដាលឲ្យមានការខូតខាតដល់ជនដែលមានសិទ្ធិលើភាគបម្រុង នោះមិនចាំបាច់មានការកម្រិតនូវអំឡុងពេលដូចនេះឡើយ ពោលគឺគ្រប់ករណីទាំងអស់នេះ នឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

## ផ្នែកទី២៖ ការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម ជប៉ុន

នៅប្រទេសជប៉ុន នាសម័យមេជិ ទម្រង់នៃសន្តតិកម្មបានកើតមានឡើងផ្សេងៗគ្នា។ ក្រមរដ្ឋប្បវេណីសម័យមេជិ ឆ្នាំ១៨៨៩ បានកំណត់ថា ត្រូវបានអនុវត្តនៅក្នុងរបបមេគ្រួសារជាធំ (徳川家康) គឺនៅពេលដែលមេគ្រួសារទទួលមរណភាព ជាគោលការណ៍ កូនប្រុសច្បងដែលមានខាន់ស្លា ត្រូវចូលខ្លួនមកទទួលគ្រប់គ្រងផ្ទះបន្ត[១១០]។ រីឯករណីមរណភាពរបស់សមាជិកផ្សេងទៀត ក្រៅពីមេគ្រួសារ គេកំណត់យករបបសន្តតិកម្មដែលឲ្យ បច្ឆាញាតិនៃញាតិលោហិតខ្សែរផ្ទាល់ ជាអាទិ៍ធ្វើសន្តតិកម្មរួមគ្នា[១១១]។ យើងសង្កេតឃើញថាច្បាប់ស្តីពីសន្តតិកម្ម នាសម័យនោះមានការរឹតត្បិតចំពោះសិទ្ធិរបស់សហព័ទ្ធនៃមតកជន ដោយសារតែការប្រកាន់យកនូវរបបមេគ្រួសារនិយមនេះ គឺមានតែកូនប្រុសច្បងដែលមានខាន់ស្លាតែប៉ុណ្ណោះ ទើបមានសិទ្ធិមកទទួលយកចំណែកមតិក ដែលមតកជនបានបន្សល់ទុកក្រោយពេលស្លាប់[១១២]។

លុះក្រោយមក នាឆ្នាំ១៩៤៧ ក្រមរដ្ឋប្បវេណីជប៉ុន បានធ្វើវិសោធនកម្ម ដោយបានផ្តល់សិទ្ធឲ្យសហព័ទ្ធរបស់មតកជនដែលនៅរស់ អាចទទួលយកនូវចំណែកមតិក ស្របទៅតាមច្បាប់កំណត់ ដោយឲ្យគាត់ចូលមកធ្វើសន្តតិកម្មរួមគ្នា ជាមួយនឹងកូន និង ញាតិលោហិតផ្សេងទៀតរបស់មតកជន[១១៣]។

ដោយឆ្លងកាត់នូវ ការធ្វើវិសោធនកម្ម ឆ្នាំ១៩៤៧ រួចមក ឃើញថា គន្លឹះដែលមានចែងពីសន្តតិកម្មក្នុងជំពូកនៃសន្តតិកម្មតាមច្បាប់ សិទ្ធិរបស់សហព័ទ្ធត្រូវបានចែងយ៉ាងលម្អិត និង មានភាពច្បាស់លាស់សម្រាប់ដល់ការអនុវត្ត ដែលធ្លាប់មាននៅក្នុងក្រមរដ្ឋប្បវេណីចាស់[១១៤]។ សន្តតិកម្មដែលត្រូវមានអានុភាព ហើយគ្មានមតកសាសន៍ ត្រូវអនុវត្តទៅតាមការកំណត់ដោយច្បាប់[១១៥]។ សន្តតិកម្មតាមច្បាប់ ត្រូវបានតាក់តែងឡើង ដោយគិតទៅដល់យុត្តិធម៌រវាងញាតិដែលត្រូវបាន

---

[១១០] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៧០។

[១១១] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៧១។

[១១២] តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឹ, ឆ្នាំ ២០០៩), ទំព័រទី២២៩។ 高橋朋子『民法 7 親族・相続』第 2 版 （有斐閣、2009 年）、229 頁。

[១១៣]ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩០។

[១១៤] ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២១ មិថុនា ឆ្នាំ១៨៩៨។

[១១៥] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៩០០។

កំណត់ថាជា សន្តតិជន។ ក្នុងនោះដែរ សហព័ទ្ធក៏ត្រូវបានចាត់ទុកថាជាញាតិផងដែរ នៅក្នុងក្រមរដ្ឋប្បវេណីថ្មី[១១៦]។

នៅបណ្តាប្រទេសជាច្រើន ពុំបានទទួលស្គាល់សហព័ទ្ធជាញាតិនោះទេ ប៉ុន្តែតាមក្រមរដ្ឋប្បវេណីជប៉ុន បានពិចារណាលើការអនុវត្តជាប្រពៃណី នៅប្រទេសជប៉ុន ក្រមរដ្ឋប្បវេណីថ្មីបានទទួលស្គាល់សហព័ទ្ធជាញាតិ[១១៧]។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីរបស់កម្ពុជាយើង ក៏មានចែងកំណត់ថា សហព័ទ្ធគឺជាញាតិ[១១៨] ដូចទៅនឹងក្រមរដ្ឋប្បវេណីជប៉ុនផងដែរ ដោយសារបញ្ញត្តិនៃក្រមកម្ពុជាយើងភាគច្រើន គឺបានយកលំនាំតាមក្រមជប៉ុន។ ភាពជាញាតិរបស់សហព័ទ្ធនេះ គឺបានផ្តល់អានុភាពតាមផ្លូវច្បាប់ជាច្រើនដល់សហព័ទ្ធ ដែលចំណុចនេះបានស្តែងឲ្យឃើញ នូវការវិវត្តយ៉ាងខ្លាំងមួយ ដែលខុសពីក្រមរដ្ឋប្បវេណីចាស់ [១១៩]។ សហព័ទ្ធក្នុងនាមជាសន្តតិជនតាមច្បាប់ក៏ត្រូវទទួលបានផងដែរនូវយុត្តិធម៌ ក្នុងការទទួលបាននូវចំណែកមតិក ដែលត្រូវការពារដោយច្បាប់នេះ។

ដើម្បីការពារសហព័ទ្ធក្នុងករណី ដូចបានលើកឡើងខាងលើ ច្បាប់បានកំណត់នូវវិធានជាមូលដ្ឋានស្តីពីទម្រង់នៃការអនុវត្តសន្តតិកម្ម ក្នុងគោលដៅរក្សាឲ្យបាននូវសិទ្ធិរបស់សហព័ទ្ធ ដែលបានកំណត់នូវលំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម (១) យ៉ាងជាក់លាក់។

### ១. លំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម ជប៉ុន

ចំពោះសន្តតិកម្មតាមច្បាប់ លំដាប់សន្តតិកម្ម គឺជាការកំណត់អំពីសិទ្ធិអាទិភាពក្នុងការទទួលបាននូវមតិក។ មានន័យថា ក្នុងករណីដែលមតកជនមិនបានធ្វើមតកសាសន៍ ដើម្បីចាត់ចែងទ្រព្យសម្បត្តិជាមតិករបស់ខ្លួនទេនោះ សន្តតិជនតាមច្បាប់ដែលស្ថិតក្នុងលំដាប់មុនមានសិទ្ធិទទួលយកទ្រព្យសម្បត្តិមួយផ្នែក ឬ ទាំងអស់ក្នុងករណីដែលមានអត្ថិភាព ឬ នត្ថិភាពនៃសន្តតិជនផ្សេងទៀតតាមការកំណត់ជាមុនដោយច្បាប់។ ដូចបានលើកឡើងរួចមកហើយថា ក្នុងចំណោមសន្តតិជនទាំងអស់ សហព័ទ្ធក៏ជាសន្តតិជនម្នាក់ ដែលត្រូវបានកំណត់ដោយច្បាប់ផងដែរ។ លំដាប់នៃសន្តតិកម្មរបស់សហព័ទ្ធ ត្រូវបានកំណត់ទៅតាមស្ថានភាពសង្គមដែលប្រែប្រួល ពីសម័យកាលមួយទៅ

---

[១១៦] ក្រមរដ្ឋប្បវេណីថ្មីរបស់ជប៉ុន ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៧ ឧសភា ឆ្នាំ១៩៨០។

[១១៧] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៥០។

[១១៨] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៥ គន្ថីទី៧* ,(ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ១។

[១១៩] ក្រមរដ្ឋប្បវេណីចាស់មិនបានទទួលរាប់សហព័ទ្ធជាញាតិនោះទេ។

សម័យកាលមួយ។ ដូចនេះ យើងនឹងធ្វើការសិក្សាស្វែងយល់អំពី ការប្រែប្រួលនៃលំដាប់របស់សហព័ទ្ធ ក្នុងសន្តតិកម្មជប៉ុន (១.១) ឲ្យបានក្បោះក្បាយ។

### ១.១. ការប្រែប្រួលនៃលំដាប់របស់សហព័ទ្ធក្នុងសន្តតិកម្ម ជប៉ុន

នៅក្នុងប្រវត្តិនៃច្បាប់ស្តីពីសន្តតិកម្មរបស់ជប៉ុន ក៏ដូចនឹងកម្ពុជាដែរ គឺលំដាប់សន្តតិកម្មរបស់សហព័ទ្ធ ក៏មានការប្រែប្រួល បើប្រៀបធៀបរវាងក្រមរដ្ឋប្បវេណីចាស់ (១.១.១) និង នីតិវិជ្ជមាន (១.១.២) ដែលមានការប្រែប្រួល និង មានភាពខុសប្លែកគ្នាដូចម្តេច? ដើម្បីឲ្យមានភាពច្បាស់លាស់លើបញ្ហានេះ យើងនឹងធ្វើការបកស្រាយទៅតាមលំដាប់នីមួយៗជាបន្តបន្ទាប់ដូចខាងក្រោម៖

#### ១.១.១. លំដាប់សន្តតិកម្មរបស់សហព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីជប៉ុនចាស់

ក្នុងការអនុវត្តទម្រង់សន្តតិកម្មនៃប្រទេសជប៉ុន ដោយយោងតាមក្រមរដ្ឋប្បវេណីចាស់ បានស្តែងឲ្យឃើញថា គឺជាសម័យដែលបានទទួលយកនូវ ប្រព័ន្ធសន្តតិកម្មតាមរបបមេគ្រួសារនិយម នោះ គឺបានផ្តល់សិទ្ធិឲ្យសហព័ទ្ធដែលជាប្រពន្ធ ក្លាយជាសន្តតិជនលំដាប់ទី៣ ។ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធជា ប្រពន្ធដែលមិនមែនជាមេគ្រួសារវិញ គឺត្រូវបានផ្តល់សិទ្ធិឲ្យក្លាយជាសន្តតិជនលំដាប់ខ្ពស់ជាងបងប្អូនបង្កើត [១២០]។ ដោយឡែក ក្នុងករណីដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ទេ នោះសហព័ទ្ធជាប្រពន្ធនឹងត្រូវក្លាយជាសន្តតិជនលំដាប់ទី២[១២១]។ ដូចនេះ ករណីដែលមតកជនមានកូន និងចៅ នោះសហព័ទ្ធដែលនៅរស់នឹងមិនអាចក្លាយជាសន្តតិជនបានទេ។ សរុបមក សហព័ទ្ធនៅសម័យនោះ ជាពិសេសគឺសហព័ទ្ធដែលជាប្រពន្ធនោះ នឹងត្រូវក្លាយទៅជាសន្តតិជនបាន ក្នុងករណីលើកលែងមួយចំនួនតែប៉ុណ្ណោះ[១២២] និងអាចនិយាយបានថា សហព័ទ្ធជាសន្តតិជនដែលស្ថិតនៅក្នុងលំដាប់ក្រោយគេបង្អស់ [១២៣]។ ការកំណត់បែបនេះនៅតែមានបញ្ហាសម្រាប់សហព័ទ្ធ ទើបទាមទារឲ្យមានការ បង្កើតនូវច្បាប់ថ្មីដែលមានប្រសិទ្ធភាពជាងនេះ ពោលគឺ គួរតែផ្តល់សមភាពដល់បុរស និង ស្ត្រីឲ្យបានច្រើនជាងនេះ។ ក្នុងនោះដែរយើងសង្កេតឃើញថា នៅប្រទេសជប៉ុនបានធ្វើវិសោធនកម្មលើក្រមរដ្ឋប្បវេណីចាស់របស់ខ្លួន ជាច្រើនលើកច្រើនសារហេតុបានបង្កើតនូវក្រម

[១២០] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៨២។

[១២១] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៩៦, កថាខណ្ឌ១, ចំណុច១។

[១២២] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៧២, និង មាត្រា៩៨៩ បានបញ្ញត្តថា សហព័ទ្ធអាចក្លាយជាសន្តតិជន ក្នុងករណីលើកលែងតែប៉ុណ្ណោះ។ ឧទាហរណ៍៖ ករណីគ្មានបច្ឆាញាតិជាដើម។

[១២៣] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៩៦ បានបញ្ញត្តថា សហព័ទ្ធគឺជាសន្តតិជនដែលមានលំដាប់ក្រោយគេ។

រដ្ឋប្បវេណីថ្មី របស់ខ្លួនសារជាថ្មីនៅក្នុងឆ្នាំ ១៩៨០។ ដូចនេះយើងនឹងធ្វើការសិក្សាអំពីលំដាប់សន្តតិកម្មរបស់សហព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីថ្មី (១.១.២)។

### ១.១.២. លំដាប់សន្តតិកម្មរបស់សហព័ទ្ធផ្អែកតាមក្រមរដ្ឋប្បវេណីជប៉ុនថ្មី

ដូចបានរៀបរាប់ក្នុងចំណុច (១.១.១) ខាងលើ នៅក្នុងប្រទេសជប៉ុន ដំបូងឡើយទស្សនៈដែលចាត់ទុកថាសហព័ទ្ធត្រូវក្លាយទៅជាសន្តតិជននោះ គ្រាន់តែជាករណីលើកលែង គឺក្នុងករណីដែលមិនមានសន្តតិជនជាញាតិលោហិតតែប៉ុណ្ណោះ [១២៤] ទើបអាចមានសិទ្ធិចូលមកទទួលយកនូវចំណែកមត៌កបាន។ សហព័ទ្ធរបស់មតកជន មិនថាប្តី ឬ ប្រពន្ធ នឹងត្រូវក្លាយទៅជា "សន្តតិជនពិសេស" ហើយត្រូវចូលខ្លួនមកទទួលមត៌ក រួមគ្នាជាមួយនឹងសន្តតិជនដទៃទៀត ដែលមានវត្តមានដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីថ្មី របស់ប្រទេសជប៉ុន[១២៥]។ មានន័យថា ប្រសិនបើករណីដែលមាន ញាតិលោហិតដែលនឹងត្រូវក្លាយជាសន្តតិជនដែល នោះសហព័ទ្ធដែលនៅរស់នឹងធ្វើសន្តតិកម្មជាមួយគ្នានឹងសន្តតិជនដែលជាញាតិលោហិតនោះ។ ម្យ៉ាងវិញទៀត ក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ត្រូវបានទទួលស្គាល់ថា ជាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ។ អនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់មួយនេះ ទ្រព្យសម្បត្តិដែលមានតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងទទួលបានក្នុងនាមខ្លួនផ្ទាល់ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក[១២៦]។

ដូចបានរៀបរាប់នៅចំណុច ខាងលើ ក្រមរដ្ឋប្បវេណីជប៉ុន បានកំណត់ឲ្យសហព័ទ្ធក្លាយជាសន្តតិជនពិសេស ដូចនេះ យើងនឹងធ្វើការសិក្សាលម្អិតទៅលើអត្ថន័យនៃ សន្តតិជនពិសេសនេះក្នុងចំណុច ១.២ ដូចខាងក្រោម៖

[១២៤] ក្រមរដ្ឋប្បវេណីជប៉ុនចាស់, ២១ មិថុនា ឆ្នាំ១៨៩៨, មាត្រា៩៧២, និងមាត្រា៩៨៩ បានបញ្ញត្តថា សហព័ទ្ធអាចក្លាយជាសន្តតិជន ក្នុងករណីលើកលែងតែប៉ុណ្ណោះ។ ឧទាហរណ៍៖ ករណីគ្មានបច្ឆាញាតិជាដើម។

[១២៥] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩០។

[១២៦] សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍, *ច្បាប់រដ្ឋប្បវេណី* (ករណីប្រទេសជប៉ុន) (ភ្នំពេញ៖ សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និងមជ្ឈបណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍, ២០១០), ២៣៧ ដល់ ២៣៨។

### ១.២. អត្ថន័យនៃសន្តតិជនពិសេស

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន បានបញ្ញត្តថា សហព័ទ្ធគឺជាសន្តតិជនពិសេស[១២៧]។ អត្ថន័យនៃពាក្យថា "សន្តតិជនពិសេស" នេះគឺមិនខុសពីអត្ថន័យនៃពាក្យ "សន្តតិជនជានិច្ច" ដែលនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា កំពុងប្រើប្រាស់សព្វថ្ងៃនោះឡើយ។ ពោលគឺមានន័យថាគ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងទៀត ព្រមទាំងលំដាប់សន្តតិកម្មនោះទេ ឲ្យតែសហព័ទ្ធរបស់មតកជននៅមានជីវិតនាពេលចាប់ផ្ដើមសន្តតិកម្ម ហើយមិនត្រូវបានចាត់ទុកថាជាអភ័ព្វបុគ្គល សហព័ទ្ធនោះនឹងត្រូវចាត់ទុកជាសន្តតិជនពិសេស[១២៨]។ សន្តតិជនពិសេស នេះនឹងចូលខ្លួនមកទទួលយកចំណែកមតិកដែលមតកជនបានបន្សល់ទុកបានគ្រប់កាលៈទេសៈ។ ករណីពិសេស ប្រសិនបើមតកជនមានតែសហព័ទ្ធ តែពុំមានកូនចៅ ឬ សាច់ញាតិដទៃទៀត នោះមតិករបស់មតកជននោះ នឹងត្រូវធ្លាក់លើសហព័ទ្ធទាំងអស់តែម្ដង។ ការកំណត់បែបនេះ គឺជាវិវត្តនៃសិទ្ធិរបស់សហព័ទ្ធ ក្នុងរបបសន្តតិកម្មដោយច្បាប់ថ្មី ដែលបានផ្ដល់សិទ្ធិឲ្យសហព័ទ្ធទូលាយជាងក្រមសម័យចាស់ៗ។

ដោយឡែក យើងនិងធ្វើការសិក្សាបន្ថែមទៅលើ ចំណែកមតិករបស់សហព័ទ្ធដែលនឹងត្រូវទទួលបាន (២) ថាតើមានការកំណត់យ៉ាងដូចម្ដេចខ្លះ ក៏ដូចជាមានការប្រែប្រួលបែបណាខ្លះ បើប្រៀបធៀបទៅនឹងចំណែកមតិក ដែលបានកំណត់នៅក្រមរដ្ឋប្បវេណី ចាស់របស់ជប៉ុនសម័យមេជិ។

## ២. ចំណែកមត៌ករបស់សហព័ទ្ធ ករណីជប៉ុន

ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ទ្រព្យសម្បត្តិជាមតិករួមមាន៖ ទ្រព្យសម្បត្តិដោយឡែករបស់មតកជន និង ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ។ ដូច្នេះ នៅពេលចាប់ផ្ដើមសន្តតិកម្ម ទ្រព្យសម្បត្តិទាំងនោះនឹងក្លាយជាមតិក ហើយត្រូវបែងចែកឲ្យទៅសន្តតិជនរបស់មតកជន។ ដូចក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជាដែរ ក្រមរដ្ឋប្បវេណីរបស់ជប៉ុនបានទទួលស្គាល់សហព័ទ្ធជាសន្តតិជនជានិច្ច[១២៩] គ្រាន់តែគេប្រើពាក្យប្លែកពីយើង គឺគេប្រើពាក្យថា "សន្តតិជនពិសេស"។ ប៉ុន្តែ ចំពោះចំណែកមតិកដែល

[១២៧] តាកាហាសុីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្ដីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី៣០០។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、300 頁。

[១២៨] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៨៩០។

[១២៩] សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍, *ច្បាប់រដ្ឋប្បវេណី* (ករណីប្រទេសជប៉ុន) (ភ្នំពេញ៖ សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និងមជ្ឈបណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍, ២០១០), ២៣៧ ដល់ ២៦៣។

កំណត់ដោយច្បាប់ ករណីដែលសហាព័ទ្ធរបស់មតកជន និង សន្តតិជនផ្សេងទៀតនោះមានភាពខុសគ្នាធៀបទៅនឹងក្រមរដ្ឋប្បវេណីថ្មីរបស់ប្រទេសជប៉ុន។ ការទទួលស្គាល់សហាព័ទ្ធរបស់មតកជនជាសន្តតិជនពិសេស និង ការកំណត់ចំណែកមតិក គឺជាការវិវត្តយ៉ាងខ្លាំងមួយនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន។

ដើម្បីឲ្យកាន់តែយល់ច្បាស់ យើងនឹងធ្វើការសិក្សាទៅលើករណីនីមួយៗ ពោលគឺ ករណីដែលសហាព័ទ្ធ និងបច្ឆាញាតិរបស់មតកជនជាសន្តតិជន (២.១) និង ករណីសហាព័ទ្ធ និងឪពុកម្តាយ (២.២) ព្រមទាំង ករណីចុងក្រោយ គឺ សហាព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្តាយ (២.៣) ដោយភ្ជាប់ជាមួយនឹង ករណីសិក្សា ដូចដែលបានបង្ហាញនៅក្នុង ប្រព័ន្ធសន្តតិកម្មរបស់កម្ពុជាខាងលើ ក៏ដូចជាតារាងសង្ខេបអំពីចំណែកមតិកក្នុងករណីមានសហាព័ទ្ធផងដែរ។

### ២.១. សហាព័ទ្ធ និង បច្ឆាញាតិ

យោងតាមបញ្ញត្តមាត្រា ៩០០ (១) នៃក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៤៧ បានចែងថា "បើសហាព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហាព័ទ្ធ នឹងត្រូវទទួលបានចំណែកមតិក ១ ភាគ ២ និង កូននីមួយៗរបស់មតកជននោះនិងត្រូវទទួលចំណែកមតិក ១ ភាគ ២ ដែរ។

ឧទាហរណ៍៖ មតកជន មានសហាព័ទ្ធ កូនពីរនាក់ និង កូនសុំម្នាក់។ ក្នុងករណីនេះយើងសង្កេតឃើញថា មតកជនបានបន្សល់នូវសហាព័ទ្ធ និង កូននីមួយៗដែលជាបច្ឆាញាតិផ្ទាល់របស់ខ្លួន នោះសហាព័ទ្ធ ត្រូវទទួលចំណែក ១/២ ដោយស្វ័យប្រវត្តិ រីឯ ចំណែកមតិក ១/២ ដែលនៅសល់នឹងត្រូវបែងចែកបន្តទៅឲ្យបច្ឆាញាតិរបស់មតកជន ដែលមានកូន២នាក់ និង កូនសុំម្នាក់នោះ ហើយពួកត្រូវទទួលបានចំណែកមតិកស្មើៗគ្នា។ នោះចំណែករបស់សហាព័ទ្ធ គឺស្មើនឹង ១/២ (មួយភាគ២) រីឯចំណែកកូនទី១ ស្មើចំណែកកូនទី២ ស្មើចំណែកកូនសុំ គឺស្មើនឹង ១/៦ (មួយភាគប្រាំមួយ) នៃចំនួនមតិកសរុបទាំងអស់។



ក្នុងករណីនេះ សន្តតិកម្មជំនួសក៏ត្រូវបានអនុវត្តផងដែរ ដោយសន្តតិជនជំនួសមានសិទ្ធិមកចែកចំណែកដែលសន្តតិជននោះទទួលបាន។

ឧទាហរណ៍៖ មតកជន និង សហព័ទ្ធមានកូន៤នាក់។ យើងដឹងថានៅពេលចាប់ផ្តើមបើកសន្តតិកម្ម កូនទី១បានទទួលមរណភាព ចំណែកកូនទី២ បានក្លាយជាអភ័ព្វបុគ្គល រីឯកូនទី៣ត្រូវមតកជនផ្តាច់ចេញពីមតិក។ ករណីនេះ កូនទី១ ទី២ និង ទី៣មិនអាចទទួលបានចំណែកមតិកទេ។ ប៉ុន្តែ កូនទី១មានកូន ៣នាក់ គឺ ក$_{១}$ ក$_{២}$ និងក$_{៣}$ ចំណែកកូនទី២មានកូន១នាក់គឺ ខ$_{១}$ និង កូនទី៣មានកូន២នាក់គឺ គ$_{១}$ និង  គ$_{២}$។ ករណីនេះ ចំណែកមតិកត្រូវបែងចែងទៅឲ្យសហព័ទ្ធ ១/២ ហើយចំណែក១/២ ដែលនៅសល់នឹងបែងចែកជា ៤ចំណែកស្មើគ្នា ដោយ៖

- សហព័ទ្ធ ត្រូវបានចំណែកមតិក ១/២ (មួយភាគពីរ)
- កូនទី៤ ត្រូវបានចំណែកមតិក ១/៨(មួយភាគប្រាំបី)
- ចំណែមតិក ១/៨ របស់កូនទី១ ត្រូវចែកទៅកូន៣នាក់ គឺ ក$_{១}$ ក$_{២}$ និងក$_{៣}$ នោះ ក$_{១}$ ក$_{២}$ និង ក$_{៣}$ ត្រូវទទួលបានចំណែក ១/២៤ (មួយភាគម្ភៃបួន) ស្មើៗគ្នា
- ចំណែកមតិក ១/៨ (មួយភាគប្រាំបី)របស់កូនទី២ ត្រូវបានទៅកូនតែម្នាក់របស់គាត់គឺ ខ$_{១}$ ទាំងស្រុង នោះខ$_{១}$ ត្រូវទទួលបានចំណែក ១/៨ (មួយភាគប្រាំបី)
- ចំណែក១/៨ (មួយភាគប្រាំបី)របស់កូនទី៣ ត្រូវចែកទៅកូន២នាក់ គឺ គ$_{១}$ និងគ$_{២}$ នោះ គ$_{១}$ និង គ$_{២}$ នឹងត្រូវទទួលបានចំណែក ១/១៦ (មួយភាគដប់ប្រាំមួយ) ស្មើៗគ្នា។



### ២.២. សហព័ទ្ធ និង ឪពុកម្ដាយ

បើសហព័ទ្ធ និង ឪពុកម្ដាយរបស់មតកជនជាសន្តតិជន ចំណែកមតិករបស់សហព័ទ្ធត្រូវជា ២/៣ (ពីរភាគបី) ឯចំណែកមតិករបស់ឪពុកម្ដាយ ត្រូវជា ១/៣ (មួយភាគបី)។ ប៉ុន្តែ បើឪពុកម្ដាយរបស់មតកជនតែម្នាក់នៅរស់ ឪពុកម្ដាយនោះ និង សហព័ទ្ធត្រូវបានចំណែកមតិកស្មើគ្នា[១៣] គឺ១/២ (មួយភាគពីរ)។ ក្នុងករណីពិសេស ដែលមតកជនមានឪពុកម្ដាយច្រើន នោះចំណែកមតិករបស់សហព័ទ្ធត្រូវជា ២/៣ (ពីរភាគបី) ដដែល ឯចំណែករបស់ឪពុកម្ដាយត្រូវចែកនឹងចំណែកដែលនៅសល់ គឺ១/៣ (មួយភាគបី) ដោយម្ដាយឪពុកម្នាក់ៗត្រូវទទួលបានចំណែកស្មើៗគ្នា។

ឧបមាថា៖ មតកជនមានម្ដាយ ឪពុក និង ឪពុកចិញ្ចឹម ព្រមទាំងសហព័ទ្ធ។ នោះទ្រព្យសម្បត្តិរបស់មតកជននឹងត្រូវធ្វើការបែងចែកដូចតទៅ៖

- សហព័ទ្ធ ត្រូវទទួលបានចំណែកមតិក ២/៣ (ពីរភាគបី) ដោយស្វ័យប្រវត្តិ
- ចំណែកមតិក ១/៣ (មួយភាគបី) ដែលនៅសល់ត្រូវយកមកបែងចែកជា ៣ចំណែកស្មើគ្នាទៅឲ្យ ម្ដាយ ឪពុក និងឪពុកចិញ្ចឹម នោះចំណែកមតិករបស់ពួកគាត់នីមួយៗ ត្រូវស្មើនឹង ១/៩ (មួយភាគប្រាំបួន)។




ដោយឡែក ករណីដែលមតកជនមានតែម្ដាយម្នាក់គត់ដែលនៅរស់ ព្រមទាំងសហព័ទ្ធ។ នោះទ្រព្យសម្បត្តិរបស់មតកជននឹងត្រូវធ្វើការបែងចែកស្មើៗគ្នា ដូចតទៅ៖

- សហព័ទ្ធ ត្រូវទទួលបានចំណែកមតិក ១/២ (មួយភាគពីរ)
- ចំណែកមតិក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវយកមកបែងចែកទៅឲ្យម្ដាយរបស់មតកជន ដោយស្វ័យប្រវត្តិតែម្ដង។

[១៣] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៩០០, ចំណុចទី២។

- ដូចនេះទាំងសហព័ទ្ធ និង ម្តាយរបស់មតកជន ត្រូវទទួលបានចំណែក ១/២ (មួយភាគពីរ) ស្មើៗគ្នា។




## ២.៣. សហព័ទ្ធ និង បងប្អូនបង្កើត ឬ បុព្វញាតិក្រៅពីឪពុកម្តាយ

ក្នុងករណីដែលសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន នោះចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា៣/៤ (បីភាគបួន) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសត្រូវជា ១/៤ (មួយភាគបួន)។ មានន័យថាសហព័ទ្ធរបស់មតកជនត្រូវបានចំណែក ៣/៤ (បីភាគបួន) តែម្តង ហើយចំណែក ១/៤ (មួយភាគបួន) ដែលនៅសល់ត្រូវយកមកបែងចែកឲ្យសហសន្តតិជនផ្សេងៗទៀត[១៣២]។

ប្រសិនបើគ្មានម្តាយ ឬឪពុកទេ ជីដូនជីតាត្រូវចែកចំណែកជាមួយសហព័ទ្ធរបស់មតកជន នោះសហព័ទ្ធរបស់មតកជនត្រូវទទួលយកបានចំណែកមត៌កស្មើនឹង ១/២ (មួយភាគពីរ) ឯចំណែកដែលនៅសល់ត្រូវយកមកចែកឲ្យជីដូនជីតាដោយម្នាក់ៗទទួលបានចំណែកស្មើៗគ្នា។

ឧបមាថា៖ បើម្តាយ និង ឪពុករបស់មតកជនបានទទួលមរណភាព តែនៅមានជីដូនជីតានោះ សហព័ទ្ធរបស់មតកជន ត្រូវចែកចំណែកជាមួយ ជីដូនជីតាទាំងសងខាងដែលមាន ដោយធ្វើការបែងចែកចំណែកមត៌កដូចខាងក្រោម៖

- សហព័ទ្ធ ត្រូវទទួលបានចំណែកមត៌ក ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ

[១៣២] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៩០០, ចំណុចទី៣។

- ចំណែកមតិក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវយកមកបែងចែកជា ៤ចំណែកឲ្យទៅជីដូនជីតាទាំងសងខាង នោះចំណែកមតិកដែលពួកគាត់ម្នាក់ៗត្រូវទទួលបាន ស្មើនឹង ១/៨ (មួយភាគប្រាំបី)។




ដោយឡែកករណីដែលសហាព័ទ្ធរបស់មតកជន ជាមួយនឹង បងប្អូនបង្កើតរបស់មតកជនជាសន្តតិជន នោះចំណែកមតិករបស់សហាព័ទ្ធត្រូវជា ១/២ (មួយភាគពីរ) ដោយស្វ័យប្រវត្តិ រីឯចំណែកមតិក ១/២ (មួយភាគពីរ) ដែលនៅសល់ត្រូវចែកឲ្យបងប្អូនបង្កើតរបស់មតកជនស្មើៗគ្នា។

ឧទាហរណ៍៖ មតកជន មានបងប្អូនបង្កើត២នាក់ និង បងប្អូនរួមឪពុក១នាក់ ព្រមទាំងសហាព័ទ្ធ និង ស្រីកំណាន់ម្នាក់។ នោះទ្រព្យសម្បត្តិរបស់មតកជន នឹងត្រូវបែងចែកដូចខាងក្រោម៖

- សហាព័ទ្ធ ត្រូវទទួលបានចំណែកមតិក ៣/៤ (បីភាគបួន) ដោយស្វ័យប្រវត្តិ
- ចំណែក ១/៤ (មួយភាគបួន) ដែលនៅសល់ត្រូវបែងចែកឲ្យ បងទី១ បងទី២ និងបងប្អូនរួមឪពុករបស់មតកជន គឺប្អូនទី៤។ ប៉ុន្តែ ប្អូនទី៤ ជាបងប្អូនរួមតែឪពុកជាមួយមតកជន នោះប្អូនទី៤ ត្រូវទទួលបានចំណែកពាក់កណ្តាល នៃចំណែកដែល បងទី១ និងបងទី២ត្រូវទទួលបានតែប៉ុណ្ណោះ[១៣២]។ ដូចនេះ បងទី១ និង បងទី២ ត្រូវទទួលបានចំណែកមតិក ១/៨ (មួយភាគប្រាំបី) ស្មើគ្នាហើយប្អូនទី៤ត្រូវទទួលបានចំណែក ១/១៦(មួយភាគដប់ប្រាំមួយ)។

[១៣២] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា៩០០, ចំណុចទី៤, វាក្យខ័ណ្ឌ២ បានបញ្ញត្តថា ចំណែកមតិករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១/២ (មួយភាគពីរ) នៃចំណែកមតិករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា។

- ដោយឡែក ស្រីកំណាន់ដែលជាម្តាយរបស់ប្អូនទី៤ គឺពុំមានសិទ្ធិមកទទួលចំណែកមត៌ករបស់មតកជនបានឡើយ សូម្បីតែមួយភាគ លើកលែងតែមានលិខិតបណ្តាំ។




នៅក្នុងករណីសន្តតិកម្មជំនួស ត្រូវអនុវត្តដូចគ្នាផងដែរ ដោយសន្តតិជនជំនួសមានសិទ្ធិមកចែកចំណែកដែលសន្តតិជននោះទទួលបានតែប៉ុណ្ណោះ។

តាមរយៈគំនូសតាងខាងក្រោម យើងដឹងថាម្តាយ និងឪពុករបស់មតកជនបានស្លាប់។ ហើយមតកជនមានបងប្អូនរួមម្តាយឪពុក ២នាក់ និងបងប្អូនរួមតែឪពុកម្នាក់ ព្រមទាំងសហាព័ទ្ធ ។ ដូចនេះ ទ្រព្យសម្បត្តិរបស់មតកជន នឹងត្រូវបែងចែកទៅឲ្យ សហាព័ទ្ធ និងបងប្អូនទាំង៣របស់មតកជន។ ប៉ុន្តែ នៅថ្ងៃបើកសន្តតិកម្ម យើងបានដឹងថា បងទី១របស់មតកជនបានទទួលមរណភាព ដោយមាន កូន២នាក់ ទន្ទឹមនឹងនេះដែរ ប្អូនទី៤របស់មតកជន ត្រូវបានក្លាយជាអភ័ព្វបុគ្គលដោយមានកូន២នាក់ដែរ។ ដូចនេះ ការបែងចែកទ្រព្យសម្បត្តិរបស់មតកជន នឹងត្រូវគណនាដូចខាងក្រោម៖

- សហាព័ទ្ធ ត្រូវទទួលបានចំណែកមត៌ក ៣/៤ (បីភាគបួន) ដោយស្វ័យប្រវត្តិ
- ចំណែកមត៌ក ១/៤ (មួយភាគបួន) ដែលនៅសល់ត្រូវបែងចែកទៅឲ្យ បងទី១ បងទី២ និងប្អូនទី៤។ ប៉ុន្តែ ដោយសារតែ បងទី១បានទទួលមរណភាព ឯប្អូនទី៤បានក្លាយជាអភ័ព្វបុគ្គលដូចនេះ ពួកគេទាំងពីរពុំមានសិទ្ធិមកទទួលចំណែកមត៌កបានទេ ដោយចំណែកមត៌ក របស់ពួកគេត្រូវផ្ទេរទៅឲ្យសន្តតិជនជំនួស គឺ $ក_{១}$ $ក_{២}$ $ខ_{១}$ និង $ខ_{២}$ ដែលត្រូវជាកូនរបស់ពួកគាត់។ ដូចនេះចំណែកមត៌ករបស់ បងទី២ $ក_{១}$ $ក_{២}$$ខ_{១}$ និង $ខ_{២}$ នឹងត្រូវបែងចែកដូចខាងក្រោម៖
    - ចំណែកមត៌ករបស់បងទី២ ត្រូវទទួលបានត្រូវជា ១/៨ (មួយភាគប្រាំ)

- ក១ និង ក២ ជាសន្តតិជនជំនួសដែលត្រូវទទួលចំណែក ១/៨ (មួយភាគប្រាំ) របស់បងទី១ នោះចំណែករបស់ពួកគេនីមួយៗ ត្រូវជា ១/១៦ (មួយភាគដប់ប្រាំមួយ) ស្មើៗគ្នាៗ
- ខ១ និងខ២ ជាសន្តតិជនជំនួសដែលត្រូវទទួលចំណែក ១/១៦ (មួយភាគដប់ប្រាំមួយ) របស់បងទី១ នោះចំណែករបស់ពួកគេនីមួយៗ ត្រូវជា ១/៣២ (មួយភាគសាមសិបពីរ) ស្មើៗគ្នា។




***ខាងក្រោមនេះជាតារាងសង្ខេបនៃចំណែកមត៌កក្នុងករណីមានសហព័ទ្ធជាសន្តតិជន៖***

| សហព័ទ្ធ និង កូន | | សហព័ទ្ធ និង បុព្វញាតិផ្ទាល់ | | | | សហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយ ឬ បងប្អូនបង្កើត ឬសន្តតិជនជំនួសបងប្អូនបង្កើត | |
|---|---|---|---|---|---|---|---|
| | | សហព័ទ្ធ និងឪពុកម្ដាយ | | សហព័ទ្ធ និងឪពុកឬ ម្ដាយ | | | |
| សហព័ទ្ធ | កូន | សហព័ទ្ធ | ឪពុកម្ដាយ | សហព័ទ្ធ | ឪពុក/ម្ដាយ | សហព័ទ្ធ | សន្តតិជនផ្សេងទៀត |
| ១ភាគ២ | ១ភាគ២ | ២ ភាគ ៣ | ១ ភាគ ៣ | ១ ភាគ ២ | ១ ភាគ ២ | ៣ ភាគ ៤ | ១ ភាគ ៤ |

ក្រោយពីសិក្សាលម្អិតពី ចំណែកមត៌ករបស់សហព័ទ្ធ រួចមក យើងនឹងធ្វើការសិក្សាបន្តទៅលើសិទ្ធិរបស់សហព័ទ្ធលើភាគបម្រុង ដែលនឹងត្រូវបកស្រាយក្នុងចំណុចទី៣ ខាងក្រោមនេះ៖

### ៣. សិទ្ធិរបស់សហព័ទ្ធលើភាគបម្រុង ករណីជប៉ុន

ក្រមរដ្ឋប្បវេណីបង្កើតប្រព័ន្ធភាគបម្រុង ដែលធ្វើឲ្យមានការរឹតត្បិតមួយផ្នែក នូវសេរីភាពនៃការធ្វើមតកសាសន៍។ ប្រសិនបើផ្អែក ទៅលើការគោរពឆន្ទៈរបស់បុគ្គលម្នាក់ៗ គេគប្បីទទួលស្គាល់នូវសេរីភាពរបស់បុគ្គល ក្នុងការចាត់ចែងទ្រព្យសម្បត្តិទាំងពេលនៅរស់ ទាំងក្រោយពេលទទួលមរណភាព ប៉ុន្តែគេក៏គួរតែផ្តល់កិច្ចការពារផងដែរ ចំពោះគ្រួសារដែលធ្លាប់ទទួលការឧបត្ថម្ភពីមរណជន និង ចំពោះសេចក្តីសង្ឃឹមរបស់សន្តតិជនតាមច្បាប់ ដែលរំពឹងថា ខ្លួននឹងបានទទួលបន្តទ្រព្យសម្បត្តិនោះ។ ហេតុដូច្នេះ ហើយមតិកមួយផ្នែកជាក់លាក់ ត្រូវទុកជាភាគបម្រុង ដើម្បីធានាចំពោះសន្តតិជននូវការ ទទួលបានមតិក។ ទោះបីជាត្រូវធានាឲ្យ មានភាគបម្រុងក៏ដោយ ក៏មិនមានន័យថា ករណីនៃអច្ច័យទានលើទ្រព្យសម្បត្តិទាំងអស់ ឬ ប្រទានកម្មដែលបុគ្គលបានធ្វើមុននឹងទទួលមរណភាពត្រូវអស់សុពលភាពភ្លាមៗដែរនោះទេ។ ចំពោះភាគបម្រុង ដែលត្រូវបានបំពាន អ្នកមានសិទ្ធិលើភាគបម្រុងនោះ អាចទាមទារឲ្យធ្វើការកាត់បន្ថយនូវ អច្ច័យទាន និង ទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្ម ត្រឹមកម្រិតដែលចាំបាច់ដើម្បីបង្គ្រប់ភាគបម្រុង នោះ សំដៅប្រមូលមតិកមកវិញ ដោយយោងតាមការអនុវត្ត សិទ្ធិនៃការទាមទារឲ្យកាត់បន្ថយ ដើម្បី បង្គ្រប់ភាគបម្រុង[១៣៣]។

ចំណុចដែលត្រូវចាប់អារម្មណ៍នៅកន្លែងនេះ គឺទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង រួមបញ្ចូលនូវទ្រព្យដែលបានបង្វែរចេញដោយសារ ប្រទានកម្ម ដែលបានធ្វើក្នុងអំឡុងពេលមួយឆ្នាំ នៅមុនពេលចាប់ផ្តើមធ្វើសន្តតិកម្ម (ចំពោះប្រទានកម្មដែលត្រូវបានធ្វើឡើងដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង ទោះបីជាបានធ្វើលើសមួយឆ្នាំក៏ដោយ ក៏ត្រូវគិតបញ្ចូលដែរ)[១៣៤] ។ ពីព្រោះថា បើមិនធ្វើដូច្នេះទេ នឹងបើកឲ្យមានឱកាសអាចបំផ្លាញ ប្រព័ន្ធភាគបម្រុង ដោយសារប្រទានកម្មដែលធ្វើមុនពេលមតកជនទទួលមរណភាពបាន។ តាមរយៈការដែលធ្វើបែបនេះ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងអាចត្រូវបានកំណត់ឡើង ដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលទទួល មរណភាព (នៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម) មកបូកបន្ថែមទ្រព្យសម្បត្តិមួយចំណែកជាក់លាក់ដែលបាន ធ្វើប្រទានកម្មមុននោះ រួចហើយដកនូវចំនួនប្រាក់សរុបនៃបំណុលចេញ[១៣៥]។

[១៣៣] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០៣១។

[១៣៤] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០៣០។

[១៣៥] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០២៩, កថាខណ្ឌទី១។

ម្យ៉ាងវិញទៀត ចំពោះសិទ្ធិនៃការទាមទារឲ្យកាត់បន្ថយភាគបម្រុង នឹងត្រូវរលត់ តាមរយៈអាជ្ញាយុកាល ប្រសិនបើជាមិនមានអនុវត្តសិទ្ធិទាមទារនោះទេ ក្នុងអំឡុងពេលមួយឆ្នាំ គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង អំពីអច្ច័យទាន ឬ ប្រទានកម្ម ដែលត្រូវកាត់បន្ថយនោះមក។ សិទ្ធិទាមទារឲ្យកាត់បន្ថយនេះ គឺនឹងត្រូវរលត់ដោយអាជ្ញាយុកាលផងដែរ បើអំឡុងពេល ១០ ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម[១៣៦]។

ខាងក្រោមនេះ គឺជា គោលគំនិតដែលច្បាប់កម្ពុជាផ្តល់ឲ្យសហព័ទ្ធទទួលបាននូវសិទ្ធិលើភាគបម្រុង ដែលនឹងត្រូវបកស្រាយក្នុងចំណុច ៣.១ ។

### ៣.១. គោលគំនិតដែលផ្តល់ឲ្យសហព័ទ្ធទទួលបានសិទ្ធិលើភាគបម្រុង

ដូចដែលបានបកស្រាយនៅក្នុងចំណុច ៣ ខាងលើ ភាគបម្រុងគឺជារបបមួយដែលគេបង្កើតឡើងក្នុងគោលបំណង ដើម្បីធានានូវចំណែកមត៌កកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់។ ដោយយោងតាមច្បាប់រដ្ឋប្បវេណីរបស់ជប៉ុន ក៏មិនខុសពីច្បាប់នៃប្រទេសកម្ពុជាយើងដែរ ពោលគឺ បានកំណត់ឲ្យ បុព្វញាតិផ្ទាល់ និង បច្ឆាញាតិផ្ទាល់នៃមតកជនក្លាយជាសន្តតិជនដែលមានសិទ្ធិលើភាគបម្រុងដែរ។ នៅក្នុងនោះដែរ សហព័ទ្ធរបស់មតកជន ក៏ត្រូវបានច្បាប់ផ្តល់ឲ្យមានសិទ្ធិលើភាពបម្រុងផងដែរ [១៣៧] ។ ចំពោះគោលគំនិតដែលផ្តល់ឲ្យសហព័ទ្ធទទួលបាននូវសិទ្ធិលើភាគបម្រុងនេះ គឺយើងអាចធ្វើការវិភាគទៅលើស្ថានភាពជាក់ស្តែងនិងស្ថានភាពច្បាប់។ បើយើងគិតតាមស្ថានភាពជាក់ស្តែង យើងអាចសន្និដ្ឋានបានថា ដោយសារតែសហព័ទ្ធ គឺជាបុគ្គលដែលតែងតែនៅ ជិតដិតនឹងមតកជនបំផុត ហើយក៏ជាបុគ្គលដែលតែងតែ មើលថែរក្សាមតកជនពេលដែលនៅរស់។ ដូចនេះ វាពិតជា សមហេតុផលណាស់ ដែលច្បាប់គួរតែផ្តល់ឲ្យបុគ្គលដែលជាសហព័ទ្ធ មានសិទ្ធិលើភាគបម្រុង។ និយាយជារួមមក សហព័ទ្ធគឺជាបុគ្គលដែលត្រូវទទួលបានការការពារពីសំណាក់ច្បាប់។ ដោយឡែក ប្រសិនបើយើងវិភាគតាម ច្បាប់បច្ចុប្បន្នវិញ ពោលគឺ ក្រមរដ្ឋប្បវេណីកម្ពុជា នោះគឺ យោងតាមបញ្ញត្តិមាត្រា ៨៩០ គឺសហព័ទ្ធត្រូវបានផ្តល់ឲ្យក្លាយជាសន្តតិជនពិសេស នោះយើងអាចសន្និដ្ឋានបានថា ដោយសារតែសហព័ទ្ធ គឺជាសន្តតិជនពិសេស ដូចនេះ ការរំពឹងថានឹងបានទទួលនូវសន្តតិកម្ម គឺមានភាគរយច្រើនសំរាបគាត់ ដែលជាសន្តតិជនពិសេសនេះ ដូចនេះ សហព័ទ្ធគួរតែទទួលបានសិទ្ធិក្នុងការទាមទារនូវភាគបម្រុង តាមសមាមាត្រដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីជប៉ុននេះ។

---

[១៣៦] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០៤២។

[១៣៧] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០២៨។

ដោយឡែក ខាងក្រោមនេះយើងនឹងសិក្សាបន្ត ថា តើសហាព័ទ្ធអាចទទួលបាន នូវភាគបម្រុង ក្នុងកម្រិតណា? (៣.២) ហើយមានភាពខុសប្លែកគ្នាយ៉ាង បើប្រៀបធៀបទៅនឹងកម្រិតដែលសន្តតិជនផ្សេងទៀតត្រូវទទួលបាន? ក្នុងនោះដែរយើងនឹងបកស្រាយប្រៀបធៀបទៅនឹង ច្បាប់ជប៉ុនចាស់ផងដែរ ដើម្បីឲ្យកាន់តែយល់ច្បាស់ ពីកម្រិតភាគបម្រុងរបស់សហាព័ទ្ធ មានការវិវត្តទៅជាយ៉ាងណា? ដោយភ្ជាប់ជាមួយនឹងតារាងសង្ខេបផងដែរ។

### ៣.២. កម្រិតនៃភាគបម្រុងដែលសហាព័ទ្ធទទួលបាន

នៅក្នុងរបបភាគបម្រុងរបស់ប្រទេសជប៉ុន អ្នកដែលមានសិទ្ធិលើភាគបម្រុង ដែលត្រូវបានទទួលស្គាល់ថា អាចទទួលភាគបម្រុង គឺ សន្តតិជនតាមច្បាប់ទាំងអស់ លើកលែងបងប្អូនបង្កើតរបស់មតកជនចេញ ពោលគឺ សហាព័ទ្ធ និងបុព្វញាតិផ្ទាល់របស់មតកជន និងបច្ឆាញាតិផ្ទាល់របស់មតកជនតែប៉ុណ្ណោះ[១៣៨]។ ចំពោះសមាមាត្រនៃភាគបម្រុង ក្នុងករណីដែលមានតែបុព្វញាតិផ្ទាល់របស់មតកជនជា សន្តតិជន នោះ កម្រិតភាគបម្រុងដែលនឹងត្រូវទទួលបាន គឺស្មើនឹង ១ ភាគ ៣។ រីឯក្នុងករណីផ្សេងទៀត (ករណីមានសហាព័ទ្ធ ឬក៏ កូនជាសន្តតិជន) គឺត្រូវទទួលបានសមាមាត្រនៃភាគបម្រុង ១ ភាគ ២[១៣៩]។ មុនការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ ១៩៨០ គឺកម្រិតនៃភាគបម្រុងដែលបុព្វញាតិផ្ទាល់នឹងទទួលបានស្មើនឹង ១ ភាគ ២ ក្នុងករណីមានតែបុព្វញាតិផ្ទាល់ជាសន្តតិជន រីឯករណីផ្សេងទៀត (ករណីមានសហាព័ទ្ធ ឬក៏កូនជាសន្តតិជន) ស្មើនឹង ១ ភាគ ៣[១៤០]។ ដូចនេះ ការធ្វើវិសោធនកម្មក្រមជប៉ុននៅឆ្នាំ ១៩៨០នេះ គឺបានបន្ថយនូវកម្រិតនៃភាគបម្រុង ចំពោះសហាព័ទ្ធទៅវិញ។

ក្នុងករណីដែលសន្តតិជន មានសិទ្ធិលើភាគបម្រុង មានទាំងសហាព័ទ្ធ និង សន្តតិជននៃភាគបម្រុងផ្សេងទៀតនោះ ការកំណត់ចំណែកភាគបម្រុង គឺ ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន ហើយត្រូវធ្វើការបែងចែក ដូចក្នុងករណីបែងចែកចំណែកមតិកដែរ។

ឧទាហរណ៍ថា ក្នុងករណីដែលសហាព័ទ្ធ និង កូនពីរនាក់គឺជាអ្នកដែលមានសិទ្ធិលើភាគបម្រុង។ ជាដំបូងបង្អស់ភាគបម្រុងទាំងមូលគឺ ត្រូវជា ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន។ បន្ទាប់មក សហាព័ទ្ធត្រូវទទួលបានចំណែក ១ ភាគ ៤ នៃភាគបម្រុងទាំងមូលនោះ រីឯចំណែក

---

[១៣៨] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, ចាប់ពីមាត្រា១០២៨។

[១៣៩] ក្រមរដ្ឋប្បវេណីជប៉ុន,១៧ ឧសភា ឆ្នាំ១៩៨០, មាត្រា១០២៨។

[១៤០] តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឹហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី៣៩០។ 高橋朋子『 民法 7 親族・相続』第 2 版 (有斐閣、2009 年)、390 頁。

១ ភាគ ៤ ទៀតបានទៅលើកូនទាំងពីរនាក់។ បន្តមកទៀតកូនទាំងពីរនាក់នោះ ម្នាក់ៗត្រូវទទួលបានចំណែក ១ ភាគ ៨ នៃ ចំណែករួមរបស់ខ្លួនគេទាំងពីរ[១៩១]។

***ខាងក្រោមនេះគឺជាតារាងសង្ខេបកម្រិតនៃភាគបម្រុងធៀបនឹងមត៌កក្នុងករណីមាន និង គ្មានសហព័ទ្ធ៖***

| សន្តតិជន | វត្តមានសហព័ទ្ធ | អវត្តមានសហព័ទ្ធ |
|---|---|---|
| កូន | សហព័ទ្ធ = ១ ភាគ ៤<br>កូន = ១ ភាគ ៤ | កូន = ១ ភាគ ២ |
| ឪពុក និង ម្តាយ | សហព័ទ្ធ = ១ ភាគ ៣<br>ឪពុក និង ម្តាយ = ១ ភាគ ៦ | ឪពុក និង ម្តាយ = ១ ភាគ ៣ |
| ឪពុក ឬ ម្តាយ | សហព័ទ្ធ = ១ ភាគ ៤<br>ឪពុក ឬ ម្តាយ = ១ ភាគ ៤ | ឪពុក ឬ ម្តាយ = ១ ភាគ ៣ |
| ជីដូន ជីតា | សហព័ទ្ធ = ៣ ភាគ ៨<br>ជីដូន ជីតា = ១ ភាគ ៨ | ជីដូន ជីតា = ១ ភាគ ៣ |
| បងប្អូនបង្កើត | សហព័ទ្ធ = ១ ភាគ ២<br>បងប្អូនបង្កើត = 0 | បងប្អូនបង្កើត = 0 |

[១៩១] តាកាហាស៊ីតូម្កុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឺ, ឆ្នាំ ២០០៩), ទំព័រទី៣៩១។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）、391 頁。

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និង បកស្រាយយ៉ាងលម្អិតទាក់ទងទៅនឹងប្រធានបទ "ប្រៀបធៀបសន្តតិកម្មរបស់សហព័ទ្ធ (ករណីកម្ពុជា-ជប៉ុន)" ដោយផ្អែកសំខាន់ទៅលើក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជា និងក្រមរដ្ឋប្បវេណីថ្មីនៃប្រទេសជប៉ុន ព្រមទាំងបានធ្វើការប្រៀបធៀបទៅនឹងក្រមរដ្ឋប្បវេណីចាស់នៃប្រទេសទាំងពីរ យើងខ្ញុំសង្កេតឃើញថា ចំពោះការផ្តល់សិទ្ធិឲ្យសហព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជា និងជប៉ុន មានភាពស្រដៀងគ្នាច្រើន គួរឲ្យកត់សម្គាល់។ ពោលគឺ របបសន្តតិកម្មរបស់សហព័ទ្ធ នៅកម្ពុជា និងជប៉ុន បច្ចុប្បន្នមានការវិវត្តយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងក្រមរដ្ឋប្បវេណីសម័យចាស់នៃប្រទេសទាំងពីរ គឺមានការផ្តល់សិទ្ធិឲ្យសន្តតិជនជាសហព័ទ្ធចូលរួមក្នុងរបបសន្តតិកម្មបានច្រើនជាងមុន គឺដោយយោងតាម ការផ្តល់ឲ្យសហព័ទ្ធក្លាយជាសន្តតិជនជានិច្ច (ក្រមរដ្ឋប្បវេណីកម្ពុជា) ក៏ដូចជា សន្តតិជនពិសេស (ក្រមរដ្ឋប្បវេណីជប៉ុន) ដែលជាហេតុនាំឲ្យសហព័ទ្ធរបស់មតកជន ដែលនៅរស់ អាចក្លាយជាសន្តតិជនដែលអាចទទួលសន្តតិកម្មបានគ្រប់កាលៈទេសៈ ព្រមទាំងទទួលបានសិទ្ធិលើភាគបម្រុងផងដែរ។ ដែលនេះគឺជាការវិវត្តនៃសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្មមួយគួរឲ្យកត់សម្គាល់។ ផ្ទុយទៅវិញ រវាងរបបសន្តតិកម្មរបស់សហព័ទ្ធនៅកម្ពុជា និងជប៉ុន ក៏មានលក្ខណៈខុសគ្នាមួយចំនួនផងដែរ ពោលគឺ កម្រិតនៃចំណែកមតិករបស់សហព័ទ្ធ ដោយក្នុងនោះយើងសង្កេតថា ចំណែកមតិករបស់សហព័ទ្ធនៅជប៉ុន ច្រើនជាងចំណែកមតិករបស់សហព័ទ្ធនៅកម្ពុជា។ ដូចនេះយើងអាចសន្និដ្ឋានបានថា ការការពារសិទ្ធិរបស់សហព័ទ្ធក្នុងរបបសន្តតិកម្ម កម្ពុជាគឺពុំទាន់មានភាពល្អប្រសើរនៅឡើយទេ បើប្រៀបធៀបទៅនឹងប្រទេសជប៉ុន។

ដូចបានលើកឡើងខាងលើ របបសន្តតិកម្មរបស់សហព័ទ្ធនៅកម្ពុជា មានការវិវត្តយ៉ាងខ្លាំងពីសម័យកាលមួយ ទៅសម័យកាលមួយក៏ពិតមែន ក៏ប៉ុន្តែបញ្ហានៅជុំវិញរបបសន្តតិកម្មប្រភេទនេះ ក៏នៅតែអាចកើតមានឡើងដដែល។ តាមរយៈការស្រាវជ្រាវនេះ យើងខ្ញុំសង្កេតឃើញមានបញ្ហាមួយចំនួនដែលមានភាពមិនស្របច្បាស់លាស់ និងមិនគ្រប់ជ្រុងជ្រោយ ក្នុងការផ្តល់សិទ្ធិ និងកិច្ចការពារចំពោះសហព័ទ្ធ រួមមាន៖

ស្ថានភាពអនីតិសង្វាសនៅក្នុងសង្គម គឺជាបញ្ហាដែលគួរតែយកចិត្តទុកដាក់ផងដែរ។ ថ្វីត្បិតតែ អនីតិសង្វាស មិនបានគោរពនូវនីតិវិធីស្របច្បាប់ក៏ដោយ តែការមិនទទួលស្គាល់ស្ថានភាពនេះនឹងបង្កនូវវិបត្តិយ៉ាងធ្ងន់ធ្ងរដល់គ្រួសារ និងសង្គមជាតិ។ ក្នុងវិស័យសន្តតិកម្ម ការមិនទទួលស្គាល់ប្តីប្រពន្ធ អនីតិសង្វាសជាសន្តតិជន អាចបង្កជាភាពស្មុគស្មាញមួយ គឺក្នុងករណី ដែលប្រពន្ធជា

អនីតិសង្វាស បានបំពេញនូវតួនាទីនានា ក្នុងនាមជាភរិយាស្របច្បាប់ ហើយមិនអាចប្រកបរបររកស៊ីខាងក្រៅបាន។ ដូចនេះ ការមិនទទួលស្គាល់ការងារដែលស្ត្រីនោះធ្វើជាគេហកិច្ច និងការមិនទទួលស្គាល់ស្ត្រីនោះជាសន្តតិជន ព្រោះតែមិនបានបំពេញទម្រង់អាពាហ៍ពិពាហ៍ និងនាំឲ្យមានភាពអយុត្តិធម៌យ៉ាងខ្លាំង។

ក្រៅពីនេះ ទោះបីជាក្រមរដ្ឋប្បវេណីបានទទួលស្គាល់សហព័ទ្ធជាសន្តតិជនជានិច្ច ក៏ដោយ ក៏ការពារទាំងនេះនៅតែមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយដែរ ដូចជាក្នុងករណីដែលមតិកមានតែចំណែកពាក់កណ្តាល នៃលំនៅឋានរួម បើទោះបីជាសហព័ទ្ធត្រូវបានច្បាប់ផ្តល់សិទ្ធអាទិភាពក្នុងការទទួលបានចំណែកនៃលំនៅឋានរួម រហូតដល់គ្រប់ចំណែកមតិករបស់ខ្លួនក៏ដោយ ករណីដែលចំណែកមតិកដែលខ្លួនមាន មានតម្លៃតែមួយភាគ ឬ ខ្លួនគ្មានលទ្ធភាពទិញយកនូវចំណែកដែលនៅសល់នោះ សហព័ទ្ធនៅតែគ្មានការការពារណាផ្សេង ដើម្បីអាចរក្សាបាននូវលំនៅឋានរួមដែលជាទីអនុស្សាវរីយ៍រវាងខ្លួន និងមតកជននោះបានដែរ។

ចំពោះបញ្ហាដូចដែលយើងខ្ញុំ បានលើកឡើងខាងលើ គឺជាបញ្ហាដែលកម្ពុជាយើងគួរតែយកចិត្តទុកដាក់ ក្នុងការដោះស្រាយ ដើម្បីផ្តល់ឲ្យសន្តតិជនជាសហព័ទ្ធទទួលបាននូវសិទ្ធិគ្រប់គ្រាន់ និងពេញលេញ តាមរយៈការការពារពីសំណាក់ច្បាប់ ដោយស្របតាមរដ្ឋធម្មនុញ្ញដែលប្រកាន់ខ្ជាប់នូវ គោលការណ៍ការពារ សិទ្ធិស្ត្រី សិទ្ធកុមារ ក៏ដូចជាសមភាពរវាងបុរស និងស្ត្រីផងដែរ។

# អនុសាសន៍

ដើម្បីឆ្លើយតបទៅនឹង បញ្ហាដែលកំពុងតែកើតមានឡើង ក្នុងរបបសន្តតិកម្មរបស់សហព័ទ្ធនៅកម្ពុជា ដូចដែលបានលើកឡើង មានដូចជា បញ្ហាអនីតិសង្វាស និងបញ្ហាសិទ្ធិលើលំនៅឋានរួមរបស់សហព័ទ្ធនេះ ក្នុងនាមយើងខ្ញុំជាប្រជាពលរដ្ឋខ្មែរ ក៏ដូចជា និស្សិតច្បាប់ សូមធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ គោរពឲ្យបាននូវគោលការណ៍ និងលក្ខខណ្ឌ ផ្សេងៗក្នុងច្បាប់ ជាពិសេស លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់ ព្រោះការមិនគោរពនូវលក្ខខណ្ឌទាំងនោះ នឹងបង្កនូវភាពស្មុគស្មាញ និងផលលំបាកជាច្រើននៅក្នុងទំនាក់ទំនង ទ្រព្យសម្បត្តិ ពិសេសនៅពេលចាប់ផ្ដើមសន្តតិកម្ម។

ម្យ៉ាងវិញទៀត យើងខ្ញុំក៏សូមសំណូមពរផងដែរ ចំពោះ នីតិនិពន្ធ និង មន្ត្រីអនុវត្តច្បាប់ សូមយកចិត្តទុកដាក់បន្ថែមទៀត ចំពោះសិទ្ធិរបស់សហព័ទ្ធក្នុងទំនាក់ទំនងគ្រួសារ និងសន្តតិកម្ម ដើម្បីធានាឲ្យបាននូវ សមភាពក្នុងគ្រួសារ ស្របតាមស្ថានភាពសង្គមដែលកំពុងមានការអភិវឌ្ឍន៍ទៅមុខជានិរន្ត និង ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញដែលទទួលស្គាល់ និង គោរពនូវ គោលការណ៍ សិទ្ធមនុស្ស សិទ្ធស្ត្រី សិទ្ធកុមារ និង ធានានូវសមភាពរវាង បុរស និង ស្ត្រីលើគ្រប់វិស័យ ជាពិសេស គឺវិស័យអាពាហ៍ពិពាហ៍ និង គ្រួសារ ក៏ដូចជាវិស័យសន្តតិកម្មផងដែរ។

លើសពីនេះ ក៏សូមអំពាវនាវដល់អ្នកច្បាប់ បញ្ញាវន្តគ្រប់រូប ជាពិសេសរាជរដ្ឋាភិបាលនិងមន្ត្រីថ្នាក់មូលដ្ឋាន សូមយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយ បង្កលក្ខណៈងាយស្រួល ដើម្បីឲ្យប្រជាពលរដ្ឋឆាប់ទទួលបានពត៌មាន ព្រមទាំងការប្រឹក្សាយោបល់ពីអ្នកជំនាញ ការស្វែងយល់អំពីបញ្ហានានាដែលទាក់ទងទៅនឹងច្បាប់ ព្រោះក្នុងសង្គមអភិវឌ្ឍមួយ ត្រូវការជាចាំបាច់នោះ គឺចំណេះដឹង និង ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រោះប្រជាពលរដ្ឋគឺជាកំលាំងស្នូលដើម្បីជំរុញការកសាងមាតុភូមិកម្ពុជា ឈានទៅរកការអភិវឌ្ឍយ៉ាងខ្លាំងក្លាបំផុត នៅក្នុងឆាកអន្តរជាតិ។

# ឯកសារយោង

## ➢ ច្បាប់ និង បទបញ្ញត្តិផ្សេង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៨ កញ្ញា ១៩៩៣។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ០៨ ធ្នូ ២០០៧។
- ក្រមរដ្ឋប្បវេណីចាស់នៃព្រះរាជាណាចក្រកម្ពុជា, ២៥ កុម្ភៈ ១៩២០។
- ក្រមមតិកនៃព្រះរាជាណាចក្រកម្ពុជា, ១៨៩១។
- ក្រមទោសភរិយា, ១៨៥៣។
- ច្បាប់ស្តីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,៣១ ឧសភា ២០១១។
- ច្បាប់ភូមិបាល, ៣០ កុម្ភៈ ២០០១។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, ២០ កក្កដា ១៩៨៩។
- ច្បាប់ស្តីពីអន្តោប្រវេសន៍, ១៩៩៤។
- ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន, ១៧ ឧសភា ១៩៨០។
- ក្រមរដ្ឋប្បវេណីចាស់សម័យមេជិនៃប្រទេសជប៉ុន, ២១ មិថុនា ១៨៩៨។
- ច្បាប់ស្តីពីអគ្រានុកូលដ្ឋានជប៉ុន, ២២ ធ្នូ ១៩៤៧។


## ➢ សៀវភៅ និង ឯកសារផ្សេង


- ក្រសួងយុត្តិធម៌, ២០០៩, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ គន្ថីទី១-ទី៣*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០១០, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៣ គន្ថីទី៥*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០១០, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៥ គន្ថីទី៧*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០១០, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៦ គន្ថីទី៨-ទី៩*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌, ២០១១, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និង មជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍, ២០១០, *ច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន)*, ភ្នំពេញ៖សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា និង មជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍។

- ហៃល ចំរើន, ២០១៦, *កម្រងច្បាប់ខ្មែរពីបុរាណ*, ភ្នំពេញ។
- មេធាវី អ៊ីវ ប៉ូលី, ២០១១, *នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប)*, ភ្នំពេញ។
- ណូមឺរ៉ា តូយ៉ូហ៊ិរ៉ុ, ២០១២, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, ភ្នំពេញ។
- ស្រី វណ្ណធី, ២០១២។, នីតិបេតិកភណ្ឌគ្រួសារ, ភ្នំពេញ។
- ចាំង ស៊ីណាត, ២០០៥, នីតិបេតិកភណ្ឌគ្រួសារ, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។
- ចាំង ស៊ីណាត, ២០០៥, នីតិមត៌កនិងទិដ្ឋភាពអន្តរជាតិនៃនីតិមត៌ក, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។
- មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៥, *ប្រវត្តិសាស្រ្តប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក*, ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា។
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ, ២០០៩, *ជំរឿនទូទៅនូវប្រជារាស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ*, ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។
- ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, *វចនានុក្រមសម្តេចសង្ឃរាជជួនណាត ភាគទី១ ទី២* , ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ។
- ពុទ្ធសាសនបណ្ឌិត្យ, ២០០៥, *ច្បាប់ក្រមង៉ុយ*, ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ។
- ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧, *សន្ទានុក្រមផ្នែករដ្ឋប្បវេណីដកស្រង់ពី សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី*, ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី។
- ជ័យ រិទ្ធី, ២០១៥, *លក្ខខណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់*, ភ្នំពេញ។
- តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី២, (រោងពុម្ព យឺហិកាគឹ, ឆ្នាំ២០០៩), ទំព័រទី៣៩០។ 高橋朋子『 民法 7 親族・相続』第 2 版 （有斐閣、2009 年）。
- អ៊ីតូហ្គីហ៊ិកុ, *នីតិរដ្ឋប្បវេណី ភាគទី៤ ស្តីពី ញាតិនិងសន្តតិកម្ម*, បោះពុម្ពលើកទី៣, (រោងពុម្ព យឺហិកាគឹ, ឆ្នាំ២០១១), ទំព័រ១៣០។ 伊藤義彦『 民法 4 親族・相続』第 3 版 （有斐閣、2011 年）。

## ➢ គេហទំព័រ

- http://www.supremecourt.gov.kh/index.php/km/judgements/civil-judgements
- http://www.cas.go.jp/jp/seisaku/hourei/data/CC4_2.pdf